# អរិយសច្ចកថា

រៀបរៀង

ដោយលោកគ្រូ ឧត្តមមុនី អ៊ុម-ស៊ូរ

តាមលំនាំឯកសារ

ព្រះមហាវិមលធម្ម នាមដើម ថោង

ចាងហ្វាងសាលាបាលីជាន់ខ្ពស់

១-ទុក្ខសច្ច

២-សមុទយសច្ច

៣-និរោធសច្ច

៤-មគ្គសច្ច

អរិយសច្ចជាអន្លង់ សំរាប់ទូងឱ្យឮច្បាស់

បត្តលោកលោកអុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។

២៨៣.
២៣

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥០០០ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្មៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥០០០ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage.  This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.
**www.budinst.gov.kh        www.elibraryofcambodia.org**

២៤៣.២៣

# អរិយសច្ចកថា

រៀបរៀង

ដោយលោកគ្រូ ឧត្តមមុនី អ៊ុម-ស៊ូរ

តាមលំនាំឯកសារ

## ព្រះមហាវិមលធម្ម នាមដើម ថោង

*ចាងហ្វាងសាលាបាលីជាន់ខ្ពស់*

១-ទុក្ខសច្ច

២-សមុទយសច្ច

៣-និរោធសច្ច

៤-មគ្គសច្ច

BUDDHIST INSTITUTE
បណ្ណាល័យ
LIBRARY
២៤៣/២៣

អរិយសច្ចជាអន្លង់ សំរាប់ទូងឱ្យព្រួច្បាស់
សត្វលោកងោកងុយណាស់ ឮស្គរដាស់ក្រោកឡើងបាន ។

www.budinst.gov.kh www.elibraryofcambodia.org

## មាតិកាធម៌

ទំព័រ


### ទុក្ខអរិយសច្ច ..........១

សំដែងអំពីជាតិទុក្ខ ..........២

សំដែងអំពីជរាទុក្ខ ..........៥

សំដែងអំពីព្យាធិទុក្ខ ..........៧

សំដែងអំពីមរណទុក្ខ ..........៧

សំដែងអំពីសោកទុក្ខ ..........៨

សំដែងអំពីបរិទេវទុក្ខ ..........៩

សំដែងអំពីទុក្ខទុក្ខ ..........៩

សំដែងអំពីទោមនស្សទុក្ខ ..........១០

សំដែងអំពីឧបាយសទុក្ខ ..........១០

សំដែងអំពីអប្បិយេហិសម្បយោគទុក្ខ ..........១០

សំដែងអំពីបិយេហិសម្បយោគទុក្ខ ..........១០

សំដែងអំពីយម្បិច្ឆំនលភតិទុក្ខ ..........១១

សំដែងអំពីបញ្ចុបាទានខន្ធទុក្ខ ..........១១

អត្ថនៃទុក្ខសច្ច ..........១៤

### សមុទយសច្ច ..........១៦

សំដែងអំពីតណ្ហា ១០៨ ..........២០

អត្ថនៃសមុទយសច្ច ..........២២

### ទុក្ខនិរោធអរិយសច្ច ..........២៤

អាយតនៈ ១២ ជាទីប្រជុំនៃតណ្ហា ..........២៦

ពាក្យបុច្ឆាអំពីនិព្វាន ..........២៧

អត្ថនៃនិរោធសច្ច ..........៥៩


www.budinst.gov.kh www.elibraryofcambodia.org

មគ្គសច្ច ....................................................................៦១

អង្គអរិយមគ្គទី ១ ....................................................................៦៤

អង្គអរិយមគ្គទី ២ ....................................................................៦៤

អង្គអរិយមគ្គទី ៣ ....................................................................៦៤

អង្គអរិយមគ្គទី ៤ ....................................................................៦៥

អង្គអរិយមគ្គទី ៥ ....................................................................៦៥

អង្គអរិយមគ្គទី ៦ ....................................................................៦៦

អង្គអរិយមគ្គទី ៧ ....................................................................៦៦

អង្គអរិយមគ្គទី ៨ ....................................................................៦៧

សំដែងដោយសមាធិ ៣ ....................................................................៦៧

អត្ថនៃមគ្គសច្ច ....................................................................៧៥

សម្មាទិដ្ឋិជាលោកិយ ....................................................................៧៨

សម្មាសង្កប្បជាលោកិយ ....................................................................៨២

សម្មាវាចាជាលោកិយ ....................................................................៨៤

ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនារឿងភរិយា ៧ ចំពូក ....................................................................៨៥

សម្មាកម្មន្តជាលោកិយ និង វិរត្តិ ៣ ....................................................................៨៩

សម្មាអាជីវជាលោកិយ និង វាណិជ្ជ ៥....................................................................៩៣

សម្មាវាយាមជាលោកិយ ....................................................................៩៣

សម្មាសតិជាលោកិយ ....................................................................១០០

សម្មាសមាធិជាលោកិយ ....................................................................១០១

ធម្មចក្កមានប្របភេទ ២ ....................................................................១០២


www.budinst.gov.kh www.elibraryofcambodia.org

# អរិយសច្ចកថា

គ្រានេះនឹងបានវិសជ្ជនាក្នុងចតុរារិយសច្ចទាំង៤គឺ

## ១ - ទុក្ខអរិយសច្ច ២ - សមុទយអរិយសច្ច

## ៣ - និរោធអរិយសច្ច ៤ - មគ្គអរិយសច្ច

តាមលំអានផានដែលអង្គ សម្ដេចព្រះសព្វញ្ញូសម្មាសម្ពុទ្ធជាម្ចាស់ ត្រាស់ទេសនាប្រោសបញ្ចវគ្គិយភិក្ខុទាំង៥អង្គ មានព្រះអញ្ញាតកោណ្ឌញ្ញជាប្រធានមួយអន្លើនឹងពពួកព្រហ្មទាំង១៨កោដិ ឰដ៏ព្រៃឥសិបតនមិគទាយវន ទៀបក្រុងពារាណសីរាជធានី នឹងសំដែងជានិទ្ទេសវារ ។

កាលអង្គសម្ដេចព្រះភគវន្តមុនី ទ្រង់ត្រាស់ទេសនោះជាកថេតុកម្យ-តាបុប្ពូច្ចេះថា **តត្ថកតមា ជាតិបិទុក្ខា ជរាបិទុក្ខា ព្យាធិបិទុក្ខា មរណម្បិ-ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិទុក្ខា អប្បិយេហិសម្បយោ-គោទុក្ខោ បិយេហិវិប្បយោគោទុក្ខោ អម្បិច្ឆំនលភតិ តម្បិទុក្ខំ សំខិត្តេន បញ្ចុបាទានក្ខន្ធាបិទុក្ខា** អធិប្បាយសេចក្ដីក្នុងនិទ្ទេសវារថា **តត្ថ** ម្នាល-ភិក្ខុទាំងឡាយ កងទុក្ខដែលតថាគតសំដែងថាវេមេងបៀតបៀនសត្វឱ្យលំបាក វេទនាជានិច្ចជានិរន្តរមិនចេះដាច់ មិនចេះឈប់ មិនចេះល្ហែនេះ តើគឺទុក្ខដូចម្ដេចខ្លះ **តត្ថ** ម្នាលភិក្ខុទាំងឡាយទុក្ខមាន១៣កង គឺជាតិទុក្ខកងទី១ ជរាទុក្ខកងទី២ ព្យាធិទុក្ខកងទី៣ មរណទុក្ខកងទី៤ សោកទុក្ខកងទី៥ បរិទេវទុក្ខកងទី៦ ទុក្ខទុក្ខកងទី៧ ទោមនស្សទុក្ខកងទី៨ ឧបាយាសទុក្ខកងទី៩ អប្បិយេ-

www.budinst.gov.kh www.elibraryofcambodia.org

ហិសម្បយោគទុក្ខកងទី១០ បិយេហិវិប្បយោគទុក្ខកងទី១១ យម្បិច្ឆំនលភតិ ទុក្ខកងទី ១២ បញ្ចុបាទានក្ខន្ធទុក្ខកងទី១៣ ។

ឯជាតិទុក្ខនោះ គឺទុក្ខដែលកើតដល់សត្វទាំងឡាយទាំងពួង តាំងពីបដិសន្ធិក្នុងកំណើតទាំង៤ គឺអណ្ឌជកំណើត តាំងប្តើមបដិសន្ធិក្នុងពងជាមុនហើយទើបបានញាស់ចេញជាកូនខ្ចីក្រោយ២ ជលាម្ពុជកំណើត តាំងបដិសន្ធិក្នុងគតិមាតាដូចយើងរាល់គ្នា៣ សំសេទជកំណើតកើតអំពីចំហាយញើសក្អែលដូចយ៉ាងសត្វកណ្តូបកណ្តៀរ សង្កើចមុសជាដើម៤ ឧបបាតិកកំណើត បានដូចទេពកំណើត គឺកំណើតទេវតា តាំងបដិសន្ធិកើតឡើងស្រាប់តែធំតែម្តងប្រមាណវ័យវឌ្ឍនាការប្រហែលមនុស្សមានអាយុ ១៦ឆ្នាំ មានគ្រឿងអាភរណប្រដាប់ប្រដាដ៏បរិបូណ៌ ក៏ឧបបាតិកកំណើតនេះ មិនតែទេវតាទេទុកជាមនុស្សក៏មានខ្លះដែរ ដូចយ៉ាងនាងអម្ពបាលិកា ជាស្រីពេស្យាផ្កាមាស នឹងព្រហ្មណ៍ឈ្មោះបោក្ខរសាតិ ជាតិទុក្ខនេះមានគ្រប់រូបសត្វ បៀតបៀនសត្វឱ្យបានសេចក្តីទុក្ខវេទនាមិនបើសមុខ ថារូបណាជារូបណាសឹងដូចគ្នាទាំងអស់ ជាហេតុឱ្យវិលទៅវិលមក យកកំណើតក្នុងវដ្តសំសារមិនចេះចប់ មិនចេះផុត មិនចេះឈប់ឈរ សព្វជាតិសត្វភព នឹងគណនារាប់មិនបាន ហេតុដូច្នោះបានជាគាត់ឱ្យឈ្មោះថាជាតិទុក្ខសត្វដែលចាប់បដិសន្ធិក្នុងគភ៌នោះ មានអាយតនបរិបូណ៌ខ្លះ មិនបរិបូណ៌ខ្លះ សត្វដែលជាសំសេទជ បដិសន្ធិអំពីចំហាយញើសក្អែលនោះក្តី សត្វដែលយកបដិសន្ធិជាឧបបាតិកក្តី ក៏សោយជាតិទុក្ខដ៏លើសលុបដូចគ្នាទាំងអស់ សត្វដែលកើតជាជលាម្ពុជដែលបដិសន្ធិក្នុងគភ៌មាតានោះ ក៏រមែងរសាយនូវជាតិទុក្ខច្រើនជាចម្ងតា ដូចមានព្រះបាលីថា

www.budinst.gov.kh www.elibraryofcambodia.org

**បឋមំ កលលំ ហោតិ កលលា ហោតិ អព្ពុទំ**
**អព្ពុទា ជាយតេ បេសី បេសិយា ជាយតេ ឃនោ**
**ឃនា ជាយន្តិ សាខាបិ កេសា លោមា នខាបិ ច**

សត្វទាំងឡាយដែលយកបដិសន្ធិក្នុងគភ៌មាតានោះ កាលដម្បូងជាកលលនៅតូចឆ្មារក្រៃលែងឆ្មារ មានប្រមាណប៉ុនដម្កក់ប្រេងល្ងយ៉ាងឆ្មារ ល្អិតជាបរិមាណ្ឌ ដែលជាប់នៅចុងរោមទ្រាយចាមរី មានពណ៌ដ៏ថ្លាដូចសប្បិរស់នៅបាន ៧ ថ្ងៃទី ១ ។ ក៏ប្រែជាអព្ពុទ គឺមានពណ៌ដូចទឹកលាងសាច់ នៅបាន ៧ ថ្ងៃទី ២ ។ ទើបកើតជាដុំសាច់នៅបាន ៧ ថ្ងៃ ទី ៣ ។ ក៏ប្រែហាប់ណែនជាផ្ទាំងរឹងមានសណ្ឋានដូចជាពងមាន់ក្នុងផ្ទៃមេមាន់ នៅបាន ៧ ថ្ងៃទី ៤ ។ ក៏បែកចេញជាបញ្ចសាខា គឺមែក ៥ ក្បាល ១ ដៃ ២ ជើង ២ នៅបាន ៧ ថ្ងៃទី ៥ ។ ទើបកើតសករោមក្រចកស្បែកតទៅ **តគោ បដ្ឋាយ** ចាប់ផ្ដើមតាំងអំពីកាលនោះមក ក៏តាំងតែសោយទុក្ខវេទនានៅក្នុងឧទរមាតានោះពន់ពេកក្រៃ រកអ្វីនឹងឧបមាមិនបាន អង្គុយសង្កត់លើអាហារចាស់ ក្បាលទូលអាហារថ្មីនៃមាតា អង្គុយច្រហោងដៃទាំង២ ឱបជង្គង់ផ្ទប់ចង្កា បែរខ្នងទៅខាងផ្ទៃមាតា បែរមុខទៅខាងឆ្អឹងខ្នងមាតា ដូចជាស្វាអង្គុយនៅក្នុងប្រហោងឈើ នៅវេលាដែលមានភ្លៀងធំនោះឯង ក្រពះសុករុមហ៊ុមកាយទារកវិត្យុតមិនអាចសណ្ដូកលាតដៃលាតជើងចេញបាន សោយទុក្ខវេទនានៅក្នុងឧទរប្រទេសនៃមាតា ធ្ងន់ពន់ប្រមាណណាស់ ទុក្ខស្មើនឹងសត្វដែលសោយទុក្ខនៅក្នុងស្ថាននរកដ៏ងងឹតងងល់ទុក្ខវេទនា មានតែក្លិនអសុភអាប់អួរនៅក្នុងផ្ទៃមាតា គួរគប្បីខ្ពើមរអើម [illegible]

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខវេទនាជាទម្ងន់យ៉ាងនេះ ដូចគ្នាទាំងអស់ សេចក្តីទុក្ខយ៉ាងនេះឈ្មោះថា គព្ភោក្កន្តិកមូលកទុក្ខ ចាត់ជាជាតិទុក្ខជាបឋមប្រការ១ ដោយប្រការដូច្នេះ ។

មួយវិញទៀត បើមាតាដើរទៅហើយភ្លាត់ដួលចុះក្តី ប្រែឡប់ខ្លួន ក្រោកឡើងអង្គុយចុះក្តី សត្វដែលនៅក្នុងគភ៌នោះ ភ្ញាក់តក់ស្លុតរន្ធត់ខ្លាំងសោយទុក្ខវេទនាជាកំឡាំងណាស់ ទុក្ខយ៉ាងនេះឈ្មោះថា គព្ភបរិហារមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ២ ។

មួយទៀតទុក្ខឯណាកាលដែលសត្វនៅក្នុងគភ៌មាតា ដេកទទឹងក្នុងផ្ទៃមាតាសម្រាលចេញមិនរួច សោយទុក្ខវេទនាជាទម្ងន់ពន់ប្រមាណ ទុក្ខយ៉ាងនេះឈ្មោះថា គព្ភវិបត្តិមូលកទុក្ខ ចាត់ជាជាតិទុក្ខគំរប់ ៣ ។

មួយនីសោតកាលបើខ្យល់កម្មជវា បក់ត្រឡប់សត្វក្នុងផ្ទៃឱ្យមានជើងឡើងលើ ក្បាលចុះខាងក្រោម ធ្លាក់ចុះទៅតាមទ្វារ កំណើតដូចជាបុគ្គលធ្លាក់ចុះទៅក្នុងជ្រោះភ្នំដ៏ជ្រៅពន្លឹក ត្រូវខ្លាចត្រូវតក់ស្លុតរន្ធត់ខ្លាំង កាលដែលចេញពីទ្វារយោនីនោះក៏សែនទុក្ខសែនលំបាកវេទនាខ្លាំង ដូចជាដំរីសារចេញពីប្រហោងតាល ទុក្ខយ៉ាងនេះឈ្មោះថា គព្ភជាយិកមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៤ ។

មួយទៀតកាលបើទារកសម្រាលចេញពីផ្ទៃមាតាមកហើយ បុគ្គលទទួលយកទៅជំរះមន្ទិលជុសលាងឈើផ្សារហាក់ដូចជាចាក់ដោយម្ជុល ទឹងឆ្លូតដោយមុខកំបិតដែលមុត ឈឺផ្សារសព្វសរីររាងកាយ ទុក្ខនេះឈ្មោះថា គព្ភនិក្ខមនមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៥ ។

មួយទៀតចាប់ដើម តាំងពីទារកនោះកើតចំរើនវ័យវឌ្ឍនាការឡើង រួចកាលបុព្វកម្មអំពើដើមឯណាមួយជិតដោយតាមមកឱ្យផលឱ្យដល់នូវទោស

www.budinst.gov.kh www.elibraryofcambodia.org

ទុក្ខ ត្រូវជាអាជ្ញាចាប់ចងត្រូវពិន័យវាយដំត្រូវគុកត្រូវច្រវាក់ខ្នោះឃ្នាងគាងរាំងក៏មាន ត្រូវទោសដល់ជីវិតក៏មាន ចួនកាលសម្លាប់ខ្លួនឯងក៏សឹងមានទុក្ខយ៉ាងនេះឈ្មោះថា អត្តូបក្កមមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៦ ។

មួយទៀតទុក្ខឯណា ដែលកើតមកជាមនុស្សហើយៗត្រូវគ្រឿងសាស្ត្រាវុធអ្នកដទៃប្រហារក្តី ត្រូវរបួសដោយធនូស្នាក្តី ទុក្ខយ៉ាងនេះឈ្មោះចាបរូបក្កមមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៧ ។

មួយទៀតបណ្តាទុក្ខទាំងពួងដែលកើតមានដល់បុគ្គល ដែលកើតមកក្នុងលោកសព្វសត្វគ្រប់រូប អាស្រ័យនឹងមានជាតិជាបច្ច័យ ទុកជាសត្វនរកសោយទុក្ខវេទនាផ្សេងៗ មានភ្លើងឆេះខ្លោចរំលាយនោះ ក៏ព្រោះតែមានជាតិជាបច្ច័យឱ្យបដិសន្ធិឈ្មោះថា អត្តូបក្កមមូលកទុក្ខ ចាត់ជាជាតិទុក្ខជាគំរប់ ៨ ។

មួយទៀតសត្វទាំងឡាយ ទុកជាសត្វតិរច្ឆាននោះក្តីដែលសោយទុក្ខវេទនាលំបាកដោយបុគ្គលដទៃទៀតបៀតបៀត មានវាយដំចាក់កាប់សម្លាប់ជីវិតជាដើមនោះ ក៏ព្រោះតែជាតិជាបច្ច័យឱ្យបដិសន្ធិក្នុងតិរច្ឆានកំណើត ក៏ចាត់ជាជាតិទុក្ខជាគំរប់ ៩ ។

មួយទៀតសត្វដែលកើតក្នុងប្រេតវិសយនោះៗក្តី ដែលសោយទុក្ខវេទនាអត់សេចក្តីស្រេកឃ្លានទ្រាំខ្យល់ ទ្រាំកំដៅជាដើម ក៏ចាត់ជាជាតិទុក្ខជាគំរប់ ១០ ។ ជាតិទុក្ខសំដែងតាមពុទ្ធាធិប្បាយមានប៉ុណ្ណេះ ។

ឯជរាទុក្ខនោះព្រះអង្គទ្រង់សំដែងជានិទ្ទេសវារថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ជរាឯណាដែលព្រះតថាគតទេសនាទុកក្នុងឧទ្ទេសវារ ជរានោះមានសភាពដូម្តេច ។ ជរាឯណាដែលមានសភាពធ្វើឱ្យឥន្ទ្រិយគ្រាំគ្រា វិកលវិការវិបរិតប្រែប្រួលទៅផ្សេងៗ មានធ្មេញបាក់ សក់ស្កូវ ធ្លាល់ផត សាក់ស្បែកជ្រួញ

www.budinst.gov.kh www.elibraryofcambodia.org

រូបញយុលយារស្វិត ក្អែកងងិត ត្រចៀកថ្លង់ជាដើម គួរនឹងសង្វេគរូបកាយនេះ ជរានោះព្រះតថាគតហៅ ជរាទុក្ខ ជរានេះបុគ្គលទាំងឡាយមិនអាចនឹងប្រមើល មើលឃើញដោយមំសចក្ខុទេ លុះតែបុគ្គលដែលប្រកបដោយបញ្ញាចក្ខុនោះ ទើបនឹងសំឡឹងឃើញច្បាស់ប្រាកដពិតបាន ជរានេះប្រៀបគួរនាដូចភ្លើងឆេះ ព្រៃហើយរលត់ទៅ ភ្លើងនោះក៏មិនបានប្រាកដកាលដែលឆេះ ស្រាប់តែនៅតែ ផេះនឹងធ្យូងទើបប្រាកដដល់ជនទាំងឡាយ នេះមានឧបមាដូចម្ដេចវិញ ជរា ទុក្ខនេះក៏មិនបានប្រាកដដល់ជនទាំងឡាយដូច្នេះឯង បុគ្គលបានឃើញអ្នក ឯណាធ្មេញបាក់ សក់ស្កូវ ផ្ទាល់ផតក្ដី ឃើញសាច់ស្បែកស្វិតជ្រួញរួញយុល យារក្អែកងងិត ត្រចៀកថ្លង់ក្ដី ទើបដឹងថាសេចក្ដីជរាមកដល់ប្រាកដ ពុំនោះ សោតសេចក្ដីជរានេះដូចជាជាងជម្បាញ ក៏ស្រីអ្នកត្បាញជម្បាញនោះ ត្វាយ ត្រល់ទៅមកម្ដងមួយសរសៃៗ ។ ខាងមុខកាន់តែតិចទៅៗ ខាងក្រោយកាន់តែ ច្រើនឡើងៗ នោះមកឧបមាដូចម្ដេចវិញ ជរាដែលលេបអាយុសត្វបន្តិចៗរាល់ កាលរាល់វេលាមិនចេះឈប់មិនចេះបង្អង់ពេលណាខណៈណាសោះនោះ ក៏មាន ឧបមាមេយ្យដូច្នោះឯង អធិប្បាយថាអ្នកដែលកើតមកជាមនុស្សមានអាយុខ័យ កំណត់ ១០០ឆ្នាំ លុះកន្លងថ្ងៃ ១ ទៅក៏ខ្វះអំពីកំណត់ ១០០ឆ្នាំ ១ ថ្ងៃ នៅតែ ៩៩ ឆ្នាំ ១១ ខែ ២៩ ថ្ងៃ លុះកន្លងទៅបាន ១ ខែ ក៏ខ្វះអំពី ១០០ឆ្នាំ ១ ខែ នៅតែ ៩៩ ឆ្នាំ ១១ ខែ លុះកន្លងទៅបាន ១ឆ្នាំ ក៏ខ្វះអំពី ១០០ឆ្នាំ នៅតែ ៩៩ឆ្នាំ ក៏សេចក្ដី ជរាបណ្ដេញបំបរអាយុសត្វឡើងបញ្ចូលទៅរកសេចក្ដីមរណជានិច្ច សព្វថ្ងៃ សព្វរាត្រីពុំដែលដាច់ ១ ទៀត ជរានោះរមែងតែធ្វើឥន្ទ្រិយទាំង៦ មានចក្ខុន្ទ្រិយ ជាដើម ឱ្យសៅហ្មងចុះល្អក់គ្រាំគ្រារាល់វេលា អាការ ៣២ មានសក់ជាដើម នោះសោតក៏វិកលវិការវិបត្តិប្រែប្រួលទៅផ្សេងៗ រូបកាយក៏កាន់តែស្វិតជ្រួញ

www.budinst.gov.kh www.elibraryofcambodia.org

ឃុលយារចុះរាល់កាលរាល់វេលា មើលទៅគួរនឹងខ្ពើមរអើម គួរនឹងសង្វេគ អាណិតអាណោចអចិច្ចរូបកាយយើង តែរាល់រូបដូចគ្នាទាំងអស់ក្នុងត្រៃភព រូបកាយយើងរាល់គ្នានេះមានតណ្ហាជានាយជាងតាក់តែង សង់ធ្វើបង្កើតឡើង ដូចជានាយជាងធ្វើផ្ទះ កាលបើមានខ្យល់ព្យុះ ពោលគឺជរាមកបៀតបៀន រឿយៗ ផ្ទះគឺអត្តភាពនេះក៏មិនអាចនឹងទប់ទល់ទ្រាំទ្រស្ថិតនៅបានក៏កាន់តែគ្រាំគ្រាទុព្វលភាពចុះទៅរាល់វេលា ឥរិយាបថទាំង៤ក៏កាន់តែថយចុះ នឹងក្រោក នឹងអង្គុយក៏កម្រ នឹងដើរនឹងឈរនឹងឈានជើងដើរទៅ ក៏ពិបាកថ្ងូរបណ្តើរ ដកដង្ហើមធំបណ្តើរ សោយទុក្ខវេទនារាល់កាលរាល់វេលាមិនមានល្ហែ **តេន ទុច្ចតិ ជរា** ហេតុដូច្នោះព្រះតថាគតពោលថា ទុក្ខនេះឈ្មោះថា ជរាទុក្ខ ។

ឯព្យាធិទុក្ខនោះព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ព្យាធិដែលកើតឡើងក្នុងរូបកាយនៃសត្វទាំងឡាយ ក៏ព្រោះតែធាតុប្រែប្រួល គឺថាជួនកាលត្រជាក់ ជួនកាលក្តៅរោលរាលធ្វើឱ្យរសាប់រសល់ ព្យាធិសេចក្តីឈឺចាប់មានរោគគ្រុនរោគឈឺក្បាលវិលមុខ ឈឺពោះជាដើម ព្យាធិនេះបៀតបៀនសត្វឱ្យដល់នូវសេចក្តីទុក្ខច្រើន ប្រការណាស់ ហេតុដូច្នោះ ទុក្ខនេះព្រះតថាគតអោយឈ្មោះថា ព្យាធិទុក្ខ ។

មរណទុក្ខព្រះដ៏មានបុណ្យទ្រង់ត្រាស់ទេសនាថា **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយគឺចុតិរលត់ចិត្តនៃសត្វក្តី ទំលាយខន្ធនៃសត្វក្តី ចោលសាកអសុភនៃសត្វក្តី ផ្តាច់បង់ជីវិតនៃសត្វក្តី ធម៌ទាំងនេះព្រះតថាគតហៅថា មរណធម៌ទាំងអស់ ព្រោះថាសត្វទាំងឡាយកាលបើជិតដល់មរណកាល តេជោធាតុក្នុងសរីរកាយនោះបង្កើតក្តៅក្លាខ្លាំងឡើង ធ្វើឱ្យក្តៅរោលរាលរសាប់រសល់សព្វសរីរកាយ ដូចជាគប់ភ្លើងគឺបុគ្គលយកទៅដុតលល់ទុក្ខក្នុងទីជិត ទុក្ខ

www.budinst.gov.kh www.elibraryofcambodia.org

ព្រស្វាត់ ស្រាប់តែសត្រូវដែលជាគំរប់ ២ ស្ទុះចេញមកចាប់បុរសនោះវាយដំច្រំផាក់ជាទម្ងន់ សត្រូវជាគំរប់ ៣ ស្ទុះចេញមកជួយគ្នាវាយដំបន្ថែមទៀតជាទម្ងន់ក្រៃលែង សត្រូវជាគំរប់ ៤ ក៏ស្ទុះទៅកាន់ក្បាលបុរសនោះដោយដាវដ៏មុតដាច់ក្បាលបុរសនោះក្ស័យជីវិតទៅក្នុងខណៈនោះ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ជាតិទុក្ខនោះប្រៀបដូចសត្រូវជម្លងដែលជាអ្នកលួងបញ្ឆោតយើងរាល់គ្នាឱ្យបដិសន្ធិប្រកបដោយបញ្ចខន្ធ ថាជាទីសុខទីសប្បាយ ជរាទុក្ខនោះដូចជាសត្រូវជាគំរប់ ២ ជាអ្នកស្ទុះចេញមកវាយដំច្រំផាក់ធ្វើឱ្យថមថយកំឡាំង ធ្វើឱ្យធ្មេញបាក់សក់ស្កូវជាដើម ព្យាធិទុក្ខដូចជាសត្រូវគំរប់៣ ជាអ្នកជួយបន្ថែមវាយដំឱ្យដល់ទុក្ខជាទម្ងន់ក្រៃលែងថែមទៀត ទើបមរណទុក្ខដូចជាសត្រូវជាគំរប់ ៤ កាន់ដាវស្ទុះចេញមកកាប់កផ្ដាច់ជីវិតតែម្ដង ក៏ទុក្ខទាំង៤ ប្រការនេះព្រះតថាគតហៅថា អជ្ឈត្តិកទុក្ខ គឺទុក្ខប្រព្រឹត្តទៅខាងក្នុងសន្ដាននៃសត្វទាំងឡាយក្នុងភពទាំង៣ ។

ទើបព្រះដ៏មានបុណ្យទ្រង់សម្ដែង សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខនោះតទៅថា **ភិក្ខវេ** ម្នាលភិក្ខុផងទាំងឡាយ សេចក្ដីសោកនោះ មានសភាវធ្វើចិត្តនៃសត្វឱ្យក្ដៅក្រហាយរសាប់រសាយ រីងស្ងួត ទឹងដេកដើរឈរអង្គុយក៏មិនសុខ ទឹងបរិភោគអាហារក៏មិនស្លូវបាន យ៉ាងនេះឈ្មោះថា សោកទុក្ខ ។

បរិទេវទុក្ខនោះ ក៏មានលក្ខណៈធ្វើឱ្យខ្សឹកខ្សួលអួលអាក់ទឹកភ្នែកហូរចេញសស្រាក់ ដោយហេតុដែលមាតាបិតាបុត្រភរិយាញាតិមិត្តធ្វើកាលកិរិយាក្ស័យជីវិតទៅ យ៉ាងនេះឈ្មោះថា បរិទេវទុក្ខ ។

ទុក្ខទុក្ខនោះ គឺជាទុក្ខឯណាធ្វើឱ្យចិត្តស្អុតស្ងួញរាងកជង្ហើមធំតុះទញ់

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងនេះហៅថា មរណទុក្ខ ១ ។

មួយទៀតសត្វទាំងឡាយដែលបានធ្វើកម្មលាមកអាក្រក់ដោយកាយ វាចា ឥតមានមេត្តាករុណា លុះកាលជិតនឹងដល់នូវមរណភាព គតិនិមិត្តឬទុក្ខនិមិត្តក៏ប្រាកដឡើង គឺឱ្យឃើញភ្លើងក្នុងទីនរកខ្លះ ចួនកាលឱ្យឃើញនាយនិរយបាលកាន់គ្រឿងសាស្ត្រាវុធចោមរោមកំហែងកំហៀញ គំរាមធ្វើទុក្ខ ចួនកាលក៏ឃើញជាច្រូលច្រវាក់ ជួនកាលក៏ឃើញសត្វក្អែក ត្មាតមកចោមរោមក៏សឹងមានខ្លះ ម្ល៉ោះហើយក៏ភ្ញាក់ស្លុតរន្ធត់ស្ដាយជីវិតក្រនឹងរលត់ចិត្តទៅកាន់ភពថ្មីទៀត ខ្លះក៏ស្រែកបម្រះអន្ទះអន្ទែងទៅមករកខ្យល់គ្មានសតិអារម្មណ៍ ខ្លះក៏ស្លាប់ដោយគេប្រហារជីវិតក៏មាន ទុក្ខយ៉ាងនេះហៅថា មរណទុក្ខប្រការ១ ។

ឯសត្វទាំងនេះខ្លាចសេចក្ដីស្លាប់ជាបំផុតខ្លាច នេះហើយយើងរាល់គ្នាកើតមកជាសត្វ ជាបុគ្គលមានជីវិត កាលបើចិត្តនឹងចេញចោលរាងកាយស្ដាយជីវិតរកទីបំផុតគ្មាន វៀរលែងតែលោកដែលមានបញ្ញាភិនិហារលោកមិនសូវខ្លាចពេក ហេតុដូច្នោះព្រះតថាគតពោលថា ទុក្ខនេះឈ្មោះថាមរណទុក្ខប្រការ១ អ្នកប្រាជ្ញមានប្រាជ្ញាគប្បីពិចារណាមើលចុះ ទុក្ខទាំង៤ ប្រការគឺជាតិទុក្ខ ១ ជរាទុក្ខ ១ ព្យាធិទុក្ខ ១ មរណទុក្ខ ១ ដូចសត្រូវ ៤ នាក់ ឯខ្លួនយើងទាំងពួងនេះប្រៀបដូចមនុស្សអ្នកមានពៀរសត្រូវ៤នាក់ នោះតាំងតែស្វែងរកឧបាយនឹងសម្លាប់មនុស្សដែលមានពៀរនោះចេញ សត្រូវមួយនាក់ចូលទៅរកមនុស្សនេះ ធ្វើជាមិត្តស្និទ្ធស្នាល និយាយប្រលោមលួងបញ្ឆោតទាយអាយ ធ្វើឱ្យបុរសនោះទុកចិត្តស្និទ្ធមេត្រី បុរសនោះក៏មិនដឹងខ្លួនសោះថាជាសត្រូវមកលួងលោមធ្វើឧបាយកល លុះដោយអំណាចសត្រូវជាជាមិត្តប្រាកដមែន ក៏ឆោតជឿតាមពាក្យសំដីសត្រូវនោះៗ ក៏ដឹកនាំបបួលបុរសនោះដើរចូលទៅក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ធុញតំនិតតិតមិនធ្លុះធ្លាយដោយនូវហេតុមានរាជទណ្ឌបៀតបៀនជាដើម ទុ
យ៉ាងនេះឈ្មោះថា ទុក្ខទុក្ខ ។

ទោមនស្សទុក្ខនោះ គឺទុក្ខឯណាដែលប្រកបទៅក្នុងចិត្ត ធ្វើចិត្តនៃ
សត្វឱ្យខឹងក្រោធច្រលោតតានតឹងក្នុងនិវ៉ា ឱ្យតូចចិត្តអន់ចិត្ត ទុក្ខយ៉ាងនេះ
ព្រះតថាគតឱ្យឈ្មោះថា ទោមទស្សទុក្ខ ។

ឧបាយាសទុក្ខនោះ គឺថាទុកឯណាដែលកើតផ្ទុកផ្ទើសក្នុងហឫទ័យ
អាល័យអាឡោះចង្អៀតចង្អល់ខ្វក់ខ្វល់លំបាកក្នុងចិត្ត យ៉ាងនេះឈ្មោះថាឧបាយ
សទុក្ខ ។

លំដាប់នោះ ព្រះអង្គទ្រង់សំដែងទុក្ខ៤ប្រការ គឺអប្បិយេហិសម្ប
យោគទុក្ខ១ បិយេហិវិប្បយោគទុក្ខ ១ យម្បិច្ឆំនូនលភតិតម្បិទុក្ខ១ បញ្ចុបាទា
នក្ខន្ធទុក១តទៅទៀត ។

អប្បិយេហិសម្បយោគទុក្ខនោះ សេចក្តីថាអារម្មណ៍ទាំង៥គឺរូបា-
រម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ ១ ផោដ្ឋព្វារម្មណ៍ ១ ដែល
មិនជាទីប្រាថ្នា បើបុគ្គលឯណាបានសេពគប់ភពប្រសប់សមាគមផងហើយ
ក៏មានចិត្តជាទុក្ខកើតទៅជាខ្ចើម ទៅជារអើមស្អប់មិនចង់អង្គុយជិតដេកជិត
ឈរជិត ចង់តែគេចវេះវៀរចេញឱ្យផុត ព្រោះចិត្តនោះមិនស្រឡាញ់មិនប្រាថ្នា
ហើយស្រាប់តែមកជួបប្រទះ ទុក្ខនេះព្រះ តថាគតឱ្យឈ្មោះថា អប្បិយេហិ-
សម្បយោគទុក្ខប្រការ១ ។

បិយេហិវិប្បយោគទុក្ខនោះថា រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍
រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ក្តី ដែលជាទីប្រាថ្នាមានចំណង់ចងសេពគប់សមាគម
ផង ហើយរបស់ទាំងនោះព្រាត់ឃ្លាតទៅ មិនសមតាមសេចក្តីប្រាថ្នា ទុក្ខយ៉ាង

www.budinst.gov.kh www.elibraryofcambodia.org

នេះក៏ចាត់ជាបិយេហិវិប្បយោគទុក្ខប្រការ១ ។ អធិប្បាយជាបុគ្គលទាំងឡាយក្នុងលោកនេះ បើព្រាត់ប្រាសឃ្លាតចាកមាតាបិតា ឬបុត្រភរិយាបងប្អូនញាតិសាលោហិតជាដើម ដែលជាទីស្រឡាញ់ ពេញចិត្តនោះហើយក៏កើតទុក្ខ ទុក្ខយ៉ាងនេះក៏បានឈ្មោះថា បិយេហិវិប្បយោគទុក្ខដែរ បុគ្គលព្រាត់ព្រាកចាកទ្រព្យសម្បត្តិគ្រឿងឧបភោគ ឬព្រាត់ព្រាកចាកទី ចាកស្ថានហើយទុក្ខក៏កើតមានឡើង យ៉ាងនេះក៏ឈ្មោះថា បិយេហិវិប្បយោគទុក្ខដូចគ្នា បុគ្គលដែលធ្លាប់មានយស មានសក្តិមានបរិវារ ហើយថ្លស់ធ្លាក់ចាកយសសក្តិ បរិវារនេះ យ៉ាងនេះក៏ឈ្មោះថា បិយេហិវិប្បយោគទុក្ខដូចគ្នា ។

យម្បិច្ឆំនលភតិតម្បិទុក្ខនោះ គឺទុក្ខដែលកើតឡើងព្រោះសេចក្តីប្រាថ្នា ហើយមិនសម្រេចដូចសេចក្តីប្រាថ្នា អធិប្បាយថា បុគ្គលប្រាថ្នាចង់បានត្រង់ណា ហើយមិនបានត្រង់នោះដូចសេចក្តីប្រាថ្នាក៏កើតទុក្ខ ពីព្រោះមិនបានដូចសេចក្តីប្រាថ្នា ក៏ធម្មតាសត្វដែលកើតមកក្នុងលោកទាំងអស់ រមែងតែងមានសេចក្តីប្រាថ្នារាល់រូប វៀរលែងតែលោកដែលជាអង្គព្រះអរហន្ត ទុក្ខយ៉ាងនេះឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខប្រការ១ ។

បញ្ចុបាទានក្ខន្ធទុក្ខនោះ គឺទុក្ខកើតពីព្រោះឧបាទានក្ខន្ធ៥រូបក្ខន្ធនោះក៏ជាអារម្មណ៍នៃឧបាទាន វេទនាក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន សញ្ញាក្ខន្ធក៏ជាអារម្មណ៍នៃឧបាទាន វិញ្ញាណក្ខន្ធ ក៏ជាអារម្មណ៍នៃឧបាទាន ពីព្រោះថាខន្ធទាំង៥ នោះនៅជាលោកិយនៅឡើយ ទើបបានឈ្មោះថាឧបាទានក្ខន្ធ ឧបាទាននោះប្រែថាសេចក្តីប្រកាន់មាំ ប្រែថាជាចំណីនៃតណ្ហា ឯខន្ធរបស់ព្រះអរិយបុគ្គលដែលនឹងនៅជាលោកិយក៏តែរូបក្ខន្ធ១ប៉ុណ្ណោះ ត្រង់វេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធទាំង៤នោះក៏តាំងនៅជាលោកុត្តរ នឹងបានឈ្មោះថាឧបាទាន

www.budinst.gov.kh www.elibraryofcambodia.org

ក៏ទេ ខន្ធទាំង៥ដែលជាលោកិយនោះ ព្រះតថាគតឱ្យឈ្មោះថា **សំខិត្តេន-បញ្ចុបាទានក្ខន្ធ** ប្រការ១ ព្រោះជាទីកើតនៃកងទុក្ខទាំងពួងមានជាតិទុក្ខជាដើម មានយម្បីច្ឆំនលភតិតម្បិទុក្ខជាបរិយោសាន អ្នកប្រាជ្ញមានប្រាជ្ញាប្រាថ្នានឹងចង់ត្រាស់ដឹងនូវទុក្ខអរិយសច្ច ក៏គប្បីពិចារណាតាមន័យដែលពណ៌នាមកក្នុងខាងក្រោយនោះចុះ ។

ពីនេះនឹងបានអធិប្បាយក្នុងអត្ថនៃឧបាទានក្ខន្ធតទៅ តាមអដ្ឋកថាវិភង្គនឹងគម្ពីរព្រះវិសុទ្ធិមគ្គនោះឱ្យច្បាស់ថា ព្រះយោគាវចរកុលបុត្រអ្នកមានប្រាជ្ញា ប្រាថ្នានូវអរិយសច្ចភាវនា ក៏គប្បីដឹងថា ឧបាទានក្ខន្ធទាំង៥ប្រការនេះ ជាទីកើតនៃទុក្ខអរិយសច្ច១២ប្រការនេះ មានជាតិទុក្ខជាដើមមានយម្បិច្ឆំនលភតិតម្បិទុក្ខ ជាបរិយោសានព្រោះឧបាទានក្ខន្ធ ជាទីកើតនៃកងទុក្ខទាំងពួងគួរនាដូចជាផែនដីជាទីកើតនៃរុក្ខជាតិនឹងវល្លិ៍ជាតិទាំងពួង មួយទៀត កងទុក្ខទាំងពួងតែងបៀតបៀនឧបាទានក្ខន្ធទាំង៥ នេះជានិច្ចនិរន្តរមិនមានដាច់ ឧបាទានក្ខន្ធទាំង៥នេះ នឹងចុតិបដិសន្ធិក្នុងភពឯណាៗក្តី កងទុក្ខទាំង១២ប្រការនេះក៏ជិតដោយជាប់តាមបៀតបៀនទៅក្នុងភពនោះៗជានិច្ចនិរន្តរមិនវៀរបង់ឡើយ បីដូចស្រមោលអន្ទោលតាមសរីរនៃបុគ្គល ទោះបីបុគ្គលនឹងបណ្តេញបំបរដេញពោលដូចម្តេចៗក្តី ស្រមោលមិនចេះស្ងប់ ចេះតែប្រព្រឹត្តតាមជាធម្មតា យថាមានឧបមាដូចម្តេចមិញ កងទុក្ខដែលជិតដោយឱ្យផលតាមបៀបបៀនបុគ្គលនោះ តថា ក៏មានឧបមេយ្យដូចជាស្រមោលតាមសរីរនោះឯង ព្រះយោគាវចរកុលបុត្រ ជាពុទ្ធជិនោរស មានប្រាជ្ញាប្រាថ្នានឹងគេចចៀសឱ្យផុតចាកកងទុក្ខដូចជាពណ៌នាមកនេះ គួរកុំមានចិត្តត្រេកអរនឹងឧបាទានទាំង៥ប្រការនេះឡើយ គប្បីពិចារណាឱ្យឃើញទោសក្នុងឧបាទានក្ខន្ធនោះ ថាវារមែងតែប្រកបដោយ

www.budinst.gov.kh www.elibraryofcambodia.org

កងទុក្ខជរាបតាំងពីជាតិទុក្ខជាដើម ។ ឯឧបាទានក្ខន្ធនោះ លោកចាត់ជាធម៌២ ប្រការ គឺរូបធម៌ប្រការ១ នាមធម៌ប្រការ១ រូបក្ខន្ធនោះឈ្មោះថារូបធម៌ ដោយអត្ថថាតែងវិនាសដោយវិរោធិបច្ច័យមានត្រជាក់នឹងក្តៅជាដើម វេទនាខន្ធ សញ្ញាខន្ធ សំខារខន្ធ វិញ្ញាណខន្ធទាំង៤ នោះឈ្មោះថានាមធម៌ ដោយអត្ថថា ចេះតែបង្អោនទៅក្នុងអារម្មណ៍ទាំងពួង មានរូបារម្មណ៍ជាដើម ព្រះយោគាវចរ-កុលបុត្រអ្នកមានប្រាជ្ញា លុះដឹងច្បាស់ក្នុងរូបធម៌នាមធម៌ជាអារម្មណ៍ ចំរើនទុក្ខាបនុបស្សនាភាវនាបរិកម្មថា **(នាម រូបំទុក្ខំ)** ថាកើតមកជានាមធម៌រូបធម៌នេះ រមែងតែងប្រកបដោយជរាទុក្ខព្យាធិទុក្ខមរណទុក្ខជាដើមយ៉ាងនេះ មិនលះវៀរបុគ្គលណាមួយឡើយ មួយវិញទៀតបុគ្គលដែលជាបុថុជ្ជនមិនស្តាប់គ្រាប់គ្រងព្រះធម៌ទេសនានោះ កាលបើទុក្ខមកដល់ខ្លួនហើយ ក៏តក់ស្លុតភិតភ័យសោកខ្សឹកខ្សួល រន្ធត់ខ្លាំង ឯបុគ្គលជាអរិយសាវកបានស្តាប់ធម៌ទេសនានៃព្រះតថាគតហើយ កាលបើទុក្ខទាំងពួងនោះមកដល់ ក៏អាចនឹងរម្ងាប់រំលត់ទុក្ខនោះបាន ដោយតាំងប្រាជ្ញាចុះពិចារណាឃើញថា សត្វទាំងឡាយកើតមកក្នុងលោកនេះទុកជា មានប្ញទ្ធានុភាពច្រើនដូចម្តេចៗក្តី ឬមានទ្រព្យធនធានប្រាក់មាសកែវកងប៉ុន្មានៗក្តី ឬមានឥស្សរិយយសបរិវារយសធំយ៉ាងណាៗក្តីទុក្ខទាំងនេះនឹងបាន ញញើតកោតក្រែងខ្លាចស្បើម ឬនឹងបើសមុខយល់មុខថាអ្នកនេះគួរដល់នូវសេចក្តីទុក្ខ អ្នកនោះមិនគួរនោះក៏ឥតអង្គីមានឡើយ ទុក្ខតែងត្រូវគ្រប់រូបសត្វទាំងអស់ ហេតុដូច្នោះព្រះតថាគតត្រាស់ទេសនាថា ទុក្ខអរិយសច្ចព្រះអរិយបុគ្គលទាំងឡាយនោះ លោកឃើញកងទុក្ខជាក់ច្បាស់ដោយពិត ជារបស់ពិតរបស់អរិយបុគ្គល ព្រះសម្មាសម្ពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី លោកតែងត្រាស់ដឹងនូវទុក្ខអរិយសច្ចដោយសយម្ភូញ្ញាណ គឺឃើញដោយប្រាជ្ញារបស់ព្រះអង្គឯង តែ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះអគ្គសាវកក្តី ព្រះអសីតិសាវកក្តី ព្រះបកតិសាវក្តី លោកបានដឹងបាន ឃើញកងទុក្ខទាំងនេះដោយសុតមយញាណ ព្រោះបានស្តាប់ព្រះធម្មទេសនា ទើបបានដឹងបានឃើញដោយពិតប្រាកដ ហេតុដូច្នោះឯង ទើយសម្តេចព្រះ ទសពលញាណ ទ្រង់ប្រទានធម្មទេសនាឈ្មោះទុក្ខអរិយសច្ច ជារបស់ពិត របស់ព្រះអរិយបុគ្គល ដូចន័យដែលបានពណនាមកនេះ ។

ទុក្ខអរិយសច្ចនេះមានអត្ថ៤ប្រការគឺ :

១- **បីឡនដ្ឋោ** មានអត្ថថាបៀតបៀន

២- **សំខតដ្ឋោ** មានអត្ថថាបច្ច័យប្រជុំគ្នាតាក់តែង

៣- **សន្តាបដ្ឋោ** មានអត្ថថាក្តៅក្រហាយ

៤- **វិបរិណាមដ្ឋោ** មានអត្ថថាប្រែប្រួល

អត្ថខាងដើមគឺ **បីឡនដ្ឋោ** នោះជាលក្ខណៈនៃខ្លួន គឺជាលក្ខណៈ នៃទុក្ខអរិយសច្ចពិត សំដែងអត្ថថា **បីឡនដ្ឋោ**ៗនោះ សំដៅឱ្យឃើញសេចក្តី ថាកងទុក្ខទាំង១២ប្រការ គឺជាតិទុក្ខៗដែលកើតមានដល់សត្វដែលឧប្បត្តិកើត មកយកកំណើតនៅក្នុងវដ្តសំសារនេះក្តី ជរាទុក្ខៗដែលមានលក្ខណៈធ្វើឱ្យមាន ឥន្ទ្រីយគ្រាំគ្រាវិកលការវិបត្តិប្រែប្រួលនោះក្តី ព្យាធិទុក្ខៗដែលមានលក្ខណៈធ្វើ ឱ្យឈឺចាប់ លំបាកវេទនាមានប្រការផ្សេងៗនោះក្តី មរណទុក្ខៗដែលមាន លក្ខណៈកាត់បង់នូវជីវិតន្ទ្រីយ៍នោះក្តី សោតទុក្ខៗដែលមានលក្ខណៈឱ្យក្តៅ ក្រហាយស្ងួតស្ងប់សញ្ជប់រសាប់រសល់ក្នុងចិត្តនោះក្តី បរិទេវទុក្ខៗដែលមាន លក្ខណៈធ្វើឱ្យខ្សឹកខ្សួលអួលអាក់ មានទឹកភ្នែកដ៏ហូរចេញពេញពោរសស្រាក់ នោះក្តី ទុក្ខទុក្ខៗ ដែលមានលក្ខណៈធ្វើឱ្យចិត្តតុះទញ់រញ្ជរាធុញថប់ តឹងទ្រូងដក ដង្ហើមធំនោះក្តី ទោមនស្សទុក្ខៗដែលមានលក្ខណៈធ្វើឱ្យតូចចិត្តថ្ងៃថ្នាក់អន់

www.budinst.gov.kh www.elibraryofcambodia.org

អាក់ក្នុងចិត្តនោះក្តីឧបាយាសទុក្ខៗដែលមានលក្ខណៈធ្វើឱ្យក្តួលផ្ទុកផ្ទើះអាល័យអាលោះនោះក្តី អប្បិយេហិសម្បយោគទុក្ខៗដែលមានលក្ខណៈធ្វើអោយទើសទាល់ទាស់ស្ទួប ពីព្រោះនៅប្រកបដោយសត្វនឹងសំខារដែលមិនគាប់ចិត្តមិនជាទីស្រឡាញ់នោះក្តី បិយេហិវិប្បយោគទុក្ខៗដែលមានលក្ខណៈធ្វើឱ្យស្តាយស្រណោះ ពីព្រោះប្រាស់ព្រាត់ចាកសត្វនឹងសំខារដែលជាទីស្រឡាញ់នោះក្តី យម្បីច្ឆំនលភតិតម្បិទុក្ខៗដែលមានលក្ខណៈធ្វើឱ្យខ្វល់ខ្វាក់ល្អក់ចិត្ត ក្នុងកាលដែលប្រាថ្នាចង់បានសម្រេចដូចប្រាថ្នានោះក្តី កងទុក្ខទាំង១២ប្រការនេះ រមែងបៀតបៀនសត្វឱ្យបានសេចក្តីលំបាកទុក្ខវេទនា កើតមកជាសត្វមានជីវិតហើយក៏ទៀងតែថាទុក្ខនឹងបៀតបៀនជាធម្មតា ដែលនឹងចៀសឱ្យផុតរត់ឱ្យរួចពីទុក្ខនោះគ្មានសោះឡើយ ទុកជាអង្គព្រះអរហន្ត មានអង្គព្រះសម្មាសម្ពុទ្ធជាដើមក្តី ក៏គង់ចៀសមិនផុតសេចក្តីទុក្ខវេទនា ដ៏ប្រព្រឹត្តទៅក្នុងកាយនោះបាន លុះតែដល់សិវស្ថាន ពោលគឺព្រះនិព្វាននោះ ទើបនឹងផុតអំពីសេចក្តីទុក្ខវេទនានោះបាន ហេតុដូច្នោះ ទើបសម្តេចព្រះអនាវរញ្ញាណទ្រង់សម្តែងអត្ថរបស់ព្រះអរិយសច្ច **ពីឡនដ្ឋោ** ជាលក្ខណៈនៃខ្លួន ឯអត្ថជាគំរប់២នោះគឺ **សំខតដ្ឋោ**ៗនោះមានអត្ថាធិប្បាយយោលរហូតដល់សមុទយសច្ច នឹងឱ្យឃើញសេចក្តីថាកងទុក្ខនេះកើតមានឡើងពីព្រោះតណ្ហាៗនេះជាបច្ច័យប្រជុំតាក់តែងឱ្យកើតទុក្ខ តាក់តែងទុក្ខឱ្យដល់សត្វដូចតណ្ហានេះមិនមាន បានជាព្រះអង្គទ្រង់សន្តោសនឹងឱ្យឃើញសេចក្តីរហូតដល់សមុទយសច្ចដូច្នេះទើបសំដែងអត្ថ **សំខតដ្ឋោ** នោះជាអត្ថនៃទុក្ខអរិយសច្ចជាគំរប់២ ឯអត្ថជាគំរប់៣គឺ **សន្តាបដ្ឋោ**ៗនោះមានអត្ថាធិប្បាយយោលរហូតដល់មគ្គអរិយសច្ច ដើម្បីនឹងឱ្យឃើញសេចក្តីថា កងទុក្ខទាំងពួងនឹងធ្វើឱ្យសត្វក្តៅក្រហាយ រសាប់រសល់ខ្វល់ខ្វាក់ ព្រោះហេតុថាសត្វ

www.budinst.gov.kh www.elibraryofcambodia.org

ទាំងឡាយស្រវឹងវង្វេងទៅដោយសេចក្តីប្រមាទភ្លាត់ភ្លាំង មិនមានឧស្សាហ៍បដិបត្តិតាមមគ្គសច្ចដ៏ប្រកបតាមអង្គ៨ប្រការ មានសម្មាទិដ្ឋិជាដើម មានសម្មាសមាធិជាទីបំផុត បើសត្វទាំងឡាយឧស្សាហ៍បដិបត្តិតាមមគ្គសច្ចហើយ កងទុក្ខទាំងពួងក៏នឹងមិនបានកើតមាន កងទុក្ខក៏នឹងមិនបានធ្វើឱ្យក្តៅក្រហាយរសាប់រសល់ឡើយ ព្រោះហេតុនោះហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងឱ្យឃើញជាក់ច្បាស់រហូតដល់មគ្គសច្ចដូច្នេះ ទើបបានសម្តែងនូវអត្ថគឺ **សន្តាបត្ថោ** ជាអត្ថនៃទុក្ខអរិយសច្ចជាគំរប់ ៣ ឯអត្ថជាគំរប់ ៤ គឺ **វិបរិណាមត្ថោ** នោះ មានអត្ថាធិប្បាយយោលរហូតដល់និរោធសច្ច ព្រោះនឹងឱ្យឃើញសេចក្តីច្បាស់ថាកងទុក្ខទាំងពួងមានជាតិជាដើមនោះ នឹងធ្វើសត្វលោកឱ្យដល់នូវសេចក្តីវិបត្តិផ្សេងៗនោះ ក៏ព្រោះតែថាមិនទាន់បានសម្រេចនូវនិរោធសច្ច គឺព្រះនិព្វានលោកអ្នកដែលមានវាសនាបារមីមានប្រាជ្ញាចាស់ភ្លៀវក្លាបានសម្រេចព្រះអរិយមគ្គ អរិយផល ធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន បានព្រះនិព្វានជាអារម្មណ៍កាលណាហើយ កងទុក្ខទាំងពួងក៏នឹងផុតរលត់សូន្យ នឹងជាសុខទៀងទាត់មិនភ្លាត់ប្រែប្រួល ដែលនឹងប្រែប្រួលវិបរិត្តភ្លាត់នូវក្នុងអំណាចទុក្ខនោះ ព្រោះតែមិនបាន ធ្វើឱ្យជាក់ច្បាស់នូវនិរោធសច្ច ព្រះពុទ្ធអង្គទ្រង់សំដែងឱ្យឃើញច្បាស់រហូតដល់និរោធសច្ចដូច្នេះ បានជាទ្រង់សំដែងអត្ថ **គឺវិបរិណាមត្ថោ** ជាអត្ថនៃទុក្ខអរិយសច្ចជាគំរប់ ៤ សិរិបញ្ចលក្ខណត្រូវជាអត្ថនៃទុក្ខអរិយសច្ច៤ប្រការ ។

**«តត្ថកតមំទុក្ខសមុទយោ អរិយសច្ចំយាយំតណ្ហាបោនោព្ភវិកានន្ទិរាគសហគតាតត្រតត្រាភិនន្ទិនីសេយ្យថីទំកាមតណ្ហា ភវតណ្ហា វិភវតណ្ហា ឥទំវោចតភិក្ខវេ ទុក្ខសមុទយោអរិយសច្ចន្តិ »**

ពីនេះនឹងវិសជ្ជនាក្នុងសមុទយអរិយសច្ចតទៅ ទើបព្រះសម្មាសម្ពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់សម្តែងធាតុកថេតុកម្យតាបុច្ឆាថា**ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ សមុទយអរិយសច្ចនោះតើដូចម្តេច ទ្រង់វិសជ្ជនាព្រះអង្គឯងថា តណ្ហាឯណាដែលនឹងធ្វើឱ្យសត្វទាំងឡាយ យកបដិសន្ធិយកកំណើតកើតក្នុងភពថ្មីទៀត តណ្ហានេះគឺសេចក្តីស្រេកឃ្លាន ឬចំណង់ស្រើបស្រាលត្រេកត្រអាលក្នុងវដ្តសំសារ សត្វទាំងពួងកើតក្នុងភពឯណាៗ សេចក្តីចំណង់ស្រើបស្រាលត្រេកត្រអាលក៏មានក្នុងភពនោះៗ មិនចៀសវៀរវាងមិនរសាយសោះឡើយ សេចក្តីចំណង់ក្នុងរូបារម្មណ៍ ក្នុងសទ្ទារម្មណ៍ ក្នុងគន្ធារម្មណ៍ ក្នុងរសារម្មណ៍ ក្នុងផោដ្ឋព្វារម្មណ៍ វិតរូតក្រៀកខ្ជាប់មាំមួនទៅក្នុងសន្តានសត្វចងត្របែងទុក្ខឱ្យត្រេចរង្គាត់ក្នុងវដ្តសំសារ វិលស្លាប់វិលកើតវិលយកកំណើតក្នុងភពតូចភពធំ សោយទុក្ខវេទនា ពីព្រោះកងទុក្ខ គឺជរាព្យាធិតាមបៀតបៀនញាំញីឈ្លីឈ្លច មរណនោះក៏តយតន់រំពេចាំផ្តាច់ផ្តិលជីវិតិន្ទ្រិយឱ្យដាច់ ឧបមាដូចនាយពេជឃាដកាត់កផ្តាច់ជីវិតដោយដាវដ៏មុតថ្លាសែនទុក្ខ សែនលំបាក ស្លាប់ពីនេះទៅកើតឯណោះស្លាប់ពីឯណោះទៅកើតឯណោះតៗទៅ ស្លាប់ពីឯណោះត្រឡប់ វិលមកកើតទីនេះវិញ ក៏មានចេះតែវិលត្រឡាប់ស្លាប់កើតយកកំណើតក្នុងភពតូចភពធំ មិនចេះផុតមិនចេះចប់ត្រឡប់ត្រឡិនដោយខ្សែ គឺតណ្ហា វាចងត្របែងវិតរូតដឹកនាំមិនឱ្យរំលៀកចេញរួចបាន ឯតណ្ហានោះមានពប្រការ គឺ **កាមតណ្ហា**ប្រការ១ **ភវតណ្ហា** ប្រការ១ **វិភវតណ្ហា** ប្រការ១ កាមតណ្ហានោះបានខាងឯលោភចិត្ត ប្រាថ្នាក្នុងបញ្ចកាមគុណ នឹងប្រាថ្នាកំណើតក្នុងមនុស្សសុគតិនឹងឆកាមាវចរ៦ស្ថាន អធិប្បាយថា បុគ្គលទាំងឡាយធ្វើទានរក្សាសីល សាងកងការកុសលផ្សេងៗ ព្រោះតែប្រាថ្នាចង់បានមនុស្សសម្បត្តិ នឹងទេវសម្បត្តិក្នុងជាន់ឆកាមាវចរនោះ ឈ្មោះថា កាមតណ្ហា ឯតណ្ហានោះបានខាងឯលោភចិត្តនៃលោកជាព្រះ-

www.budinst.gov.kh www.elibraryofcambodia.org

យោគាវចរ ដ៏ប្រកបដោយសស្សតទិដ្ឋិ ឃើញថាបើបង្កើតក្នុងរូបព្រហ្មក្តី អរូបព្រហ្មក្តី នឹងបានមានសេចក្តីចាស់ជរាមរណនោះក៏ឥតអត្ថិ មានចូលចិត្តជឿច្បាស់យ៉ាងនេះ ហើយចំរើនឈាន សមាបត្តិដោយលោភចិត្ត ប្រាថ្នានឹងទៅកើតក្នុងរូបព្រហ្មនោះ ទើបបានឈ្មោះថា ភវតណ្ហា ឯវិភវតណ្ហានោះ គឺលោភចិត្តដ៏ប្រកបដោយឧច្ឆេទទិដ្ឋិ ត្រេកអរក្នុងឈានសមាបត្តិ ដោយសញ្ញាសំគាល់ថាបានទៅកើតក្នុងព្រហ្មលោកហើយ នឹងបានវិលត្រឡប់មកកើតក្នុងមនុស្សលោកនេះវិញក៏ឥតអត្ថិមានឡើយ នឹងរលត់សំខារធម៌ដាច់ចូល ថ្កានសិវស្ថានគឺព្រះនិព្វានក្នុងព្រហ្មលោកនោះ លោកដែលជាព្រះយោគាវចរ ពួកមួយប្រកាន់ឧច្ឆេទទិដ្ឋិយ៉ាងនេះ ហើយមានលោភចិត្តត្រេកអរប្រាថ្នានឹងទៅ កើតក្នុងអរូបភពនោះ ឈ្មោះថាវិភវតណ្ហាអ្នកប្រាជ្ញមានប្រាជ្ញាគប្បីសន្និដ្ឋាន ចូលចិត្តចុះថាតណ្ហាទាំង៣ប្រការនេះ ឈ្មោះថាសមុទយអរិយសច្ច ដោយអត្ថ ថាជាហេតុជាបច្ច័យឱ្យកើតកងទុក្ខមានជាតិទុក្ខជាដើម ដែលពោលមកហើយ កាមតណ្ហាដែលប្រាថ្នានូវបញ្ចកាមគុណនោះជាហេតុជាបច្ច័យឱ្យកើតកងទុក្ខ ក្នុងកាមភព ភវតណ្ហានឹងវិភវតណ្ហា នោះក៏ជាបច្ច័យឱ្យកើតកងទុក្ខមានជាតិ ទុក្ខជាដើមក្នុងរូបភព នឹងអរូបភព ហេតុដូច្នោះបានជាលោកតែអត្ថនៃសមុទយនោះថាបណ្តាកងទុក្ខទាំងពួងមានជាតិទុក្ខជាដើមនោះ នឹងបានកើតមកអំពីទីដទៃក៏ឥតអត្ថិមាន កើតតែអំពីតណ្ហាម្យ៉ាងនេះឯង បើវៀរតែតណ្ហានេះ ចេញហើយ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខដាក់ជាមិនមានសោះតែម្តង អ្នកប្រាជ្ញមានប្រាជ្ញាគួរនឹងពិចារណាចុះថាតណ្ហាតែម្យ៉ាងនេះឯង ដឹកនាំសត្វឱ្យហែលវិលវល់ខ្វល់នៅក្នុងសមុទ្រ គឺវដ្តសំសារអស់កាលយូរលង់នឹងរាប់ភពរាប់ជាតិមិនបាន មិនឃើញទីជុំនាក់ពុំនឹងពឹង អាស្រ័យមិនឃើញកោះឃើញ ត្រើយ

ដែលនឹងឈប់សម្រាកបង្អង់សោះឡើយ ហេតុដូច្នោះទើបព្រះតថាគត ពោលថា តណ្ហាឈ្មោះថាសមុទយ ព្រោះតណ្ហាជាហេតុជាបច្ច័យឱ្យកើតកងទុក្ខទាំងពួង ព្រះអរិយបុគ្គលឃើញហេតុច្បាស់ដូច្នេះ បានជាបញ្ញត្តឈ្មោះថាសមុទ-អរិយសច្ច សម្តេចព្រះសរពេជ្ញសព្វញ្ញូទ្រង់សម្តែងប្រភេទនៃសមុទអរិយសច្ចា ប្រការដូច្នេះហើយ ទើបទ្រង់សម្តែងហេតុតណ្ហាដ៏ ប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេងៗនោះទៀត ជាកថេតុកម្បុយបុច្ឆាជាតិ **ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ តណ្ហានេះ កាលបើនឹងកើតឡើង តើកើតក្នុងស្ថានទីឯណា កាលបើនឹងផ្សាយតើផ្សាយទៅក្នុងស្ថានទីឯណា ទើបទ្រង់វិសជ្ជនាដោះស្រាយ ព្រះអង្គឯងថា ធម្មជាតិអ្វីជាទី ស្រឡាញ់ជាទីគាប់ចិត្តចំរើនចិត្តជាទីត្រេកត្រអាលចិត្តហើយ តណ្ហាក៏កើតឡើងក្នុងធម្មជាតិនោះ ផ្សាយទៅក្នុងធម្មជាតិនោះឯង ឯតណ្ហានោះមានដល់១០៨ប្រការ ចែកក្នុងកាមភព ៣៦ប្រការជាកាមតណ្ហាក្នុងរូបភាព ៣៦ប្រការ ជាភវតណ្ហា ក្នុងអរូបភាព៣៦ប្រការជាវិភវតណ្ហា ទើបត្រូវជាតណ្ហា១០៨ប្រការ ដូច្នេះ ។

ក៏កាមតណ្ហា៣៦នោះ គឺតណ្ហាប្រព្រឹត្តទៅក្នុងអតីតកាល១២ ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នបកាល១២ ប្រព្រឹត្តទៅក្នុងអនាគតកាល១២ ត្រូវជាកាមតណ្ហា ៣៦ប្រការ គឺតណ្ហាកើតឡើងក្នុងអាយតនខាងក្នុង ៦ប្រការ កើតឡើងក្នុងអាយតនខាងក្រៅ៦ប្រការ ត្រូវជាតណ្ហា១២ប្រការ តណ្ហាខាងក្នុង៦ប្រការនោះ គឺចក្ខាយតន១សោតាយតន១ ឃានាយតន១ ជិវ្ហាយតន ១ កាយាយតន ១ មនាយតន១ ត្រូវជាតណ្ហាខាងក្នុង៦ប្រការដូច្នេះ តណ្ហាខាងក្រៅ៦នោះ គឺរូបា-តន១ សទ្ទាយតន ១ គន្ធាយតន ១ រសាយតន ១ ផោដ្ឋព្វាយតន ១ ធម្មា-យតន ១ ត្រូវជាតណ្ហាខាងក្រៅ ៦ ប្រការដូច្នេះ នឹងអធិប្បាយតណ្ហាខាងក្នុង

www.budinst.gov.kh www.elibraryofcambodia.org

៦ប្រការនោះ គឺថាកាលណាបើបុគ្គលយកកញ្ចក់មកផ្ទះមើលស្រមោល មុខរបស់ខ្លួន ឃើញភ្នែក ច្រមុះ ត្រចៀក ច្រមោះ អណ្ដាត រូបកាយរបស់ខ្លួនហើយ កើតសេចក្ដីស្រឡាញ់ពេញចិត្តគាប់ចិត្តចំរើនចិត្តត្រេកអរក្នុងចិត្តខ្លួនថា ភ្នែកអញល្អ ត្រចៀកអញល្អ ប្រមោះអញល្អ អណ្ដាតអញល្អ រូបកាយអញល្អ សឹងដ៏ល្អគ្រប់កន្លែង ស្រឡាញ់ពេញចិត្តរបស់ខ្លួនយ៉ាងនេះ ឈ្មោះថា តណ្ហាកើតក្នុងអាយ-តនខាងក្នុង៦ប្រការ តណ្ហាដែលកើតខាងក្រៅ៦នោះ អធិប្បាយថាកាលបើបុគ្គលឃើញរូបអ្វីៗទាំងពួង រូបមានវិញ្ញាណក្ដី រូបឥតវិញ្ញាណក្ដី ដែលប្រពៃល្អឱ្យកើតសេចក្ដីស្រឡាញ់ឡើង មានចំណង់ចង់បានរូបនោះ បានស្ដាប់សំឡេងអ្វីដែលពីរោះៗ ហើយកើតសេចក្ដីត្រេកអររីករាយចូលចិត្ត បានហិតក្លិនអ្វីធុំក្លិនក្រអូប ក៏មានចិត្តត្រេកអរប្រាថ្នាចង់បាន បានលិលភ្លក់ក្រេបផឹករសអ្វីឆ្ងាញ់ពីសារហើយកើតសេចក្ដីប្រាថ្នាចង់បានចងបរិភោគ បានសម្ផស្សពាល់ត្រូវវត្ថុអ្វីៗដែលមានសាច់ល្អិតសាច់ទន់មានសម្ពត់អាវជាដើម ហើយស្រឡាញ់ចូលចិត្តចង់បានស្លៀកដណ្ដប់ជាដើម បាននិះគិតដល់ធម៌ឯណាជាទីគាប់ចិត្តចូលចិត្ត ក៏កើតសេចក្ដីរីករាយប្រាថ្នានូវអារម្មណ៍នោះ ឯតណ្ហាប្រាថ្នាចង់បាននូវរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍នោះព្រះតថាគតពោលថាតណ្ហាកើតខាងក្នុង៦ប្រការ ដូច្នេះតណ្ហាខាងក្រៅ៦ប្រការដែលបានពណ៌នាមកហើយ ផ្សំគ្នាទើបត្រូវជាកាមតណ្ហា១២ប្រការចាត់ជាអតីត១២ បច្ចុប្បន្ន១២ អនាគត ១២ សិរិបញ្ចូលផងគ្នាត្រូវជាកាមតណ្ហា៣៦ដូច្នេះ ។

មួយទៀតតណ្ហាទាំងនេះបើកើតអំពីលោភចិត្តខាងអកុសល ក៏សុទ្ធតែជាបាបទាំងអស់ ឯភវតណ្ហានឹងវិភវតណ្ហាក៏ចែកចេញជា៣៦ៗដូចគ្នា ត្រូវជា

www.budinst.gov.kh www.elibraryofcambodia.org

តណ្ហា ១០៨ប្រការ លោកចែកម្យ៉ាងទៀតថា តណ្ហានុសយដ៏ប្រកបដោយទ្វារទាំង៦ គឺចក្ខុទ្វារ សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ មនោទ្វារ នោះចាត់ជាអជ្ឈត្តិកតណ្ហាខាងក្នុង១៨ ជាពាហិរតណ្ហាខាងក្រៅ ១៨ដូចគ្នា បណ្ឌិតគប្បីសន្និដ្ឋានចុះ គឺថាយកតណ្ហា៣ប្រការ គឺកាមតណ្ហា ភវតណ្ហា វិភវតណ្ហានោះមកតាំងទុក្ខ ហើយយកអាយតនខាងក្នុង៦ប្រការ គឺចក្ខាយតនជាដើមមកគុណនឹងតណ្ហាទាំង៣នោះ ជា ៦បីដង ត្រូវជា ១៨ ឈ្មោះថា អជ្ឈត្តិកតណ្ហា ហើយយកអាយតនខាងក្រៅ ៦ គឺរូបារម្មណ៍ជាដើមមកគុណនឹងតណ្ហាទាំង៣នោះទៀត ជា ៦ បីដងត្រូវជា ១៨ ឈ្មោះថាពាហិរតណ្ហា យកអជ្ឈត្តិកតណ្ហា ១៨ នឹងពាហិរតណ្ហា ១៨ មកបញ្ចូលគ្នាត្រូវជាតណ្ហា ៣៦ ហើយយកតណ្ហា ៣៦ នោះមកតាំងឡើង យកកាលទាំង៣ គឺអតីតកាល អនាគតកាល បច្ចុប្បន្នកាលគុណទៀតគឺ ៣៦ បីដង ត្រូវជាតណ្ហា ១០៨ ប្រការ អ្នកប្រាជ្ញមានប្រាជ្ញាគប្បីសន្និដ្ឋានក្នុងអត្ថាធិប្បាយចុះ ជាតណ្ហាដ៏មានលក្ខណៈឱ្យប្រាថ្នាកិលេសកាមវត្ថុកាម នោះបើប្រាសចាកសស្សតទិដ្ឋិនឹងឧច្ឆេទទិដ្ឋិ ហើយក៏ចាត់ជាកាមតណ្ហាតណ្ហានោះ កាលបើប្រកបដោយសស្សតទិដ្ឋិប្រកាន់ថាសត្វទៀងលោកទៀងឃើញថាកើតមកជាសត្វហើយទៀត អ្នកឯណាធ្លាប់កើតជាអ្វីដល់ស្លាប់ទៅកើតម្តងទៀតក៏ជាយ៉ាងនោះ តណ្ហាប្រកបដោយសស្សតទិដ្ឋិយ៉ាងនេះ ឈ្មោះថាភវតណ្ហា តណ្ហាដែលប្រកបដោយឧច្ឆេទទិដ្ឋិ ឃើញថាសត្វទាំងឡាយស្លាប់ហើយក៏សូន្យទៅមិនកើតទៀត តណ្ហាប្រកបដោយឧច្ឆេទទិដ្ឋិយ៉ាង នេះឈ្មោះថាវិភវតណ្ហា ដែលចេញឈ្មោះថាតណ្ហា សេចក្តីប្រាថ្នាកាមគុណ ស្វែងរកកិលេសកាមវត្ថុកាមត្រឹមនេះ ហើយក៏មុខជានឹងមានតែសេចក្តីទុក្ខ សេចក្តីសោកខ្សឹកខ្សួលអួលអាល័យភ័យឧបទ្រវគ្គរាយផ្សេងៗ ហេតុដូច្នេះបុគ្គលដែល

www.budinst.gov.kh www.elibraryofcambodia.org

មានប្រាថ្នាឧស្សាហ៍ទូន្មាន កាយទូន្មានចិត្តឱ្យស្ងើងឱ្យស្រោលចាកសេចក្តីប្រាថ្នាក្នុងកាមគុណ កាលបើសន្តានមិនបានខ្វល់ខ្វាយក្នុងកិលេសកាមវត្ថុកាមហើយ សេចក្តីសោកខ្សឹកខ្សួលអួលអាល័យទុក្ខភ័យទាំងពួង ក៏នឹងរលត់សាបសូន្យសោះទៅដោយពិតប្រាកដ ព្រះអរិយបុគ្គលមានអង្គព្រះសម្មាសម្ពុទ្ធជាដើម លោកអំណាចលះបង់កងតណ្ហានេះបានដាច់ស្រេលះពីសន្តាន មិនមានសល់ខាន សូម្បីតែបន្តិចបន្តួចក៏ឥតអង្គីមានឡើយ ហេតុដូច្នេះសម្តេចព្រះសព្វពេជ្ញពុទ្ធសព្វញ្ញុទ្រង់ប្រទានធម្មទេសនាឈ្មោះសមុទយអរិយសច្ច ជារបស់ពិតរបស់ព្រះអរិយបុគ្គល ដូចន័យដែលបានពណ៌នាមកនេះ ។

សមុទអរិយសច្ចនេះមានអត្ថ ៤ ប្រការដូចគ្នា គឺ**អាយូហនត្ថោ** មានអត្ថថាប្រមូលប្រការ ១ **និទានត្ថោ** មានអត្ថាថាជាហេតុប្រការ១ **សំយោគត្ថោ** មានអត្ថថាប្រកបព្រមប្រការ១ **បលិពោធត្ថោ** មានអត្ថថាកង្វល់វល់ប្រការ១ ត្រូវជា ៤ ប្រការ អត្ថជាបឋម គឺអាយុហនត្ថោៗ នោះជាលក្ខណៈនៃសមុទយអរិយសច្ច **អាយូហន**នោះប្រែថាប្រមូលមកអធិប្បាយថា តណ្ហានោះជាមេកងមេពួងធំ មុខងារជាអ្នកតាំងតែកងទុក្ខឱ្យសត្វទាំងពួង ប្រមូលមកនូវកងទុក្ខឱ្យដល់សត្វឥតមានបើសមុខ តណ្ហានោះមាន ២ ប្រការ គឺអត្តត្ថតណ្ហាប្រការ ១ បរត្ថតណ្ហា ប្រការ ១ អត្តត្ថតណ្ហានេះ គឺប្រាថ្នានឹងឱ្យជាប្រយោជន៍ដល់ខ្លួនឯង គឺថានឹងឱ្យបានភោគសម្បត្តិបរិវារសម្បត្តិទាំងពួងមកជារបស់ខ្លួនឯងបរត្ថតណ្ហានោះគឺប្រាថ្នានូវប្រយោជន៍ដល់បុគ្គលដទៃ ជួយទំនុកបំរុងបុគ្គលដទៃបណ្តាដែលខ្លួនស្រឡាញ់ពេញចិត្តមានទាំងប៉ុន្មាន មានបុត្រភរិយាជាប្រធាន សេចក្តីប្រាថ្នាទាំងពីរប្រកាសនេះ បើមិនសម្រេចមិនសមដូចចិត្តបំណងកាលណាហើយក៏កើតទុក្ខរឿយៗមិនចេះដាច់មិនចេះភ្លេច បើទុកជាបាន

www.budinst.gov.kh www.elibraryofcambodia.org

តែថាមិនដោយឆាប់ដោយរហ័សឱ្យទាន់ចិត្តទាន់គំនិត ក៏កើតទុក្ខសៅហ្មងចិត្តក្នុងអារម្មណ៍នោះៗដែរ សូម្បីដោយហោចទៅទុកជាសត្វតូចៗ ស្ទួចផ្ទារដូចជាមូស សង្កើច ស្រមោចស្រមើលក៏តង់កើតទុក្ខព្រោះសេចក្ដីប្រាថ្នាតាមវិស័យខ្លួនដែលជាសត្វតូចល្អិត ឈ្មោះថាប្រកបដោយតណ្ហាហើយក៏ទៀងតែនឹងប្រកបដោយទុក្ខភ័យអន្តរាយផ្សេងៗជាធម្មតា សម្ដេចព្រះបរមសាស្ដាចារ្យព្រះអង្គនឹងឱ្យឃើញលក្ខណៈនៃសមុទសច្ចយ៉ាងនេះ បានជាទ្រង់សម្ដែងអត្ថជាបឋម គឺអាយុហានត្ថោ ជាលក្ខណៈនៃសមុទយសច្ចដោយប្រការដូច្នេះ ឯអត្ថជាគំរប់ ២ គឺ **និទានត្ថោ** នោះមានអធិប្បាយឆ្លុះរហូតដល់ទុក្ខអរិយសច្ច ដើម្បីនឹងឱ្យឃើញសេចក្ដីច្បាស់ថា កងទុក្ខដែលនឹងកើតដល់សត្វទាំងពួងនោះ ក៏អាស្រ័យនឹងតណ្ហានេះជាហេតុសម្រាប់តែនឹងឱ្យកើតផល ពោលគឺកងទុក្ខទាំងពួងមានជាតិទុក្ខជាដើម ឯអត្ថជាគំរប់៣គឺ **សំយោគត្ថោ** នោះមានអធិប្បាយឆ្លុះរហូតដល់និរោធអរិយសច្ច ដើម្បីនឹងឱ្យឃើញសេចក្ដីថាដំណើរដែលតណ្ហានឹងប្រកបសត្វទុក្ខនៅក្នុងវដ្តសំសារនោះ ក៏ព្រោះតែហេតុដែលសត្វមិនទាន់បានធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន សន្តាននោះនៅងងឹតដោយ រាគ ទោស មោហ ព្រះអង្គឆ្លោះនឹងឱ្យឃើញរហូតដល់ និរោធអរិយសច្ចដូច្នេះ ឯអត្ថជាគំរប់៤ គឺ **បលិពោធត្ថោ** នោះមានអត្ថាធិប្បាយឆ្លុះរហូតដល់មគ្គអរិយសច្ច ដើម្បីនឹងឱ្យឃើញច្បាស់ថា សត្វទាំងឡាយមានធុរៈវល់កង្វល់ដោយកិលេសកាមនឹងវត្ថុកាមនោះ ព្រោះតែមិនប្រតិបត្តិតាមមគ្គអរិយសច្ច បើឧស្សាហ៍ប្រតិបត្តិតាមមគ្គអរិយសច្ច ហើយក៏អាចរលាស់ខ្លួនដោះខ្លួនចេញផុតចាកធុរៈកង្វល់ទាំងពួងបាន ព្រោះតែមិនបានងាកប្រែបែរចេញចាកគន្លងផ្លូវប្រតិបត្តិតាមមគ្គអរិយសច្ច ព្រះអង្គទ្រង់ឆ្លោះនឹងឱ្យឃើញសេចក្ដីច្បាស់ឆ្លុះរហូតដល់មគ្គអរិយ

www.budinst.gov.kh www.elibraryofcambodia.org

សច្ចដូច្នេះ ទើបទ្រង់សម្តែងអត្ថ គឺ **បលិពោធត្ថោ** ជាអត្ថនៃសមុទយសច្ច ជាគំរប់៤ដូច្នេះ ។

«**តត្ថកតមំទុក្ខនិរោធោអរិយសច្ចំ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ អយំវុច្ចតិភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ** »

ពីនេះនឹងបានវិសជ្ជនាក្នុងនិរោធអរិយសច្ចតទៅ សេចក្តីជាសម្តេចព្រះមហាករុណា កាលបើនឹងត្រាស់ទេសនានិរោធអរិយសច្ចនោះ ទ្រង់សម្តែងជាកថេតុកម្យតាបុច្ឆាថា**ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ និរោធគឺធម៌ជាគ្រឿងរំលត់ទុក្ខ ដែលព្រះអរិយបុគ្គលឃើញនោះ តើដូចម្តេច ទើបទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា វី កិរិយារំលត់បង់នូវតណ្ហា ១០៨ នោះដោយអរិយមគ្គដ៏មិនបានសេសសល់ឯណាក្តី វីកិរិយាលះបង់នូវតណ្ហា ១០៨ នោះ ដោយព្រះអរិយមគ្គឯណាក្តី នឹងកិរិយារួចផុតអំពីតណ្ហា ១០៨ នោះរកអាលោះអាល័យគ្មានឯណាក្តី ក៏កិរិយារំលត់នឹងលះបង់នឹងរួចផុតអំពីតណ្ហា ១០៨ រកអាលោះអាល័យគ្មាននោះៗ ព្រះតថាគតពោលថានិរោធអរិយសច្ច ទើបអាចារ្យចោទឲ្យស៊កចូលមកថា អើព្រះដ៏មានបុណ្យទ្រង់សម្តែងនិរោធអរិយសច្ចនោះ ដោយចំណែកខាងកំលត់ទុក្ខផ្សេងទេតើ ក៏ហេតុដូចម្តេចបានជាព្រះអង្គទេសនាថាដោយរំលត់តណ្ហា១០៨នោះវិញ ព្រះអដ្ឋកថាចារ្យមានពាក្យវិសជ្ជនាដោះថា ពិតមែនហើយក្នុងទុក្ខនិរោធនេះ ប្រែថារំលត់បង់នូវកងទុក្ខទាំងពួង មានជាតិទុក្ខជាដើមនោះក៏មែនដែរ តែថាបើព្រះអង្គទ្រង់សម្តែងដោយរំលត់បង់នូវតណ្ហា ១០៨ ប្រការឱ្យរកសេសសល់គ្មានដោយអរិយមគ្គនោះហើយ ក៏ឈ្មោះថារំលត់បង់នូវកងទុក្ខដែរ ពីព្រោះថាកងទុក្ខទាំងពួងមានជាតិទុក្ខជាដើម ជាដើមដងមែកធាង

www.budinst.gov.kh www.elibraryofcambodia.org

របស់តណ្ហាៗ ជាឫសជាគល់ កាលបើតណ្ហាមិនទាន់រលត់អស់ស្រេចដរាបណា កងទុក្ខទាំងពួងក៏នៅតែកើតមានទាល់តែដរាបនោះប្រៀបដូចជាដើមឈើដែលបុគ្គលកាប់ៗតែដើមតែមែកធាង ត្រង់ឫសគល់មិនជីកគាស់រំលើងចេញ ដើមឈើនោះក៏គង់តែនឹងដុះចំរើនធំឡើង ដូចដែលបើបុគ្គលជីកគាស់រំលើងឫសគល់អស់កាលណា ដើមឈើនោះក៏មិនអាចដុះឡើងវិញបាន ហេតុដូច្នោះទើបសម្ដេចព្រះមហាករុណាទ្រង់ត្រាស់ទេសនាថារំលត់បង់នូវតណ្ហា១០៨ ឱ្យរកសេសសល់គ្មាន ឈ្មោល ទុក្ខនិរោធ គឺរំលត់បង់នូវកងទុក្ខទាំងពួង តណ្ហានោះជាហេតុជាបច្ច័យកងទុក្ខទាំងពួងមានជាតិទុក្ខជាដើមនោះជាផល ព្រះយោគាវចរប្រាថ្នានឹងធ្វើឱ្យផុតទុក្ខភ័យក្នុងវដ្តសំសារ ក៏គប្បីឧស្សាហ៍លះបង់នូវតណ្ហាដ៏ជាហេតុនៃកងទុក្ខនោះៗឱ្យដាច់ស្រលះចេញចាកសន្តានកាលឯណា កងទុក្ខដ៏ជាផលដែលនឹងកើតមានតទៅក្នុងខាងមុខនោះក៏នឹងមិនមានប្រាកដ ក្នុងកាលនោះ ឯកិរិយាដែលប្រតិបត្តិដើម្បីនឹងលះបង់នូវតណ្ហានេះ ជាកិច្ចនៃព្រះសម្មាសម្ពុទ្ធគ្រប់ៗ ព្រះអង្គទ្រង់ប្រតិបត្តិដូចស្ដេចម្រឹគកេសរសីហ ឯពួកតិរ្ថិយទាំងពួងនោះប្រតិបត្តិដូចយ៉ាងសុខធម្មតា សុនខនោះថាបើឃើញកំណាត់ឈើដុំដីគឺបុគ្គលចោលទៅនោះ ក៏ស្ទុះទៅត្របាក់ពាំនាំមក ឯខ្លួនមនុស្សអ្នកចោលនោះសុនខមិនបានទាំពានេះ មានឧបមាដូចម្ដេចមិញ ពួកតិរ្ថិយទាំងពួងក៏ប្រតិបត្តិដូចយ៉ាងសុនខនោះឯង ពួកតិរ្ថិយប្រតិបត្តិប្រាថ្នានឹងឱ្យបង្កើតទុកក្នុងខាងមុខ ពួកខ្លះប្រព្រឹត្តប្រតិបត្តិដេកលើផែនដី ពួកខ្លះប្រព្រឹត្តប្រតិបត្តិដេកក្នុងបន្លា ពួកខ្លះប្រតិបត្តិធ្វើកាយឱ្យក្ដៅទាំង៤អន្លើ គឺដុតគំនរភ្លើងទាំង៤ទិស ហើយអង្គុយក្នុងទីកណ្ដាលងើយមុខឡើងមើលព្រះអាទិត្យដរាបអស្តង្គតទៅ ប្រតិបត្តិយ៉ាងនេះជាដើម ដោយធ្វើទុកក្នុងចិត្តថា ប្រតិបត្តិយ៉ាងនេះអាចនឹងនាំខ្លួនឱ្យ

www.budinst.gov.kh www.elibraryofcambodia.org

ផុតចាកទុក្ខក្នុងវដ្តសំសារ ពួកតិរ្ថិយទាំងឡាយរមែងប្រកាន់មិច្ឆាទិដ្ឋិប្រតិបត្តិយ៉ាងនេះជាដើម . ដោយស្មានក្នុងចិត្តថា នឹងឱ្យរួចចាកទុក្ខ មិនដឹងថាឱ្យកើតក្នុងវដ្តសំសារ ប្រតិបត្តិយ៉ាងនេះគួរនាដូចសុនខត្រូវបាក់ខាំពាំយកកំណាត់ឈើនឹងដុំដីដែលគេចោល ទៅប៉ុណ្ណោះ មិននាំពាត្រង់មនុស្សដែលចោលទៅនោះឯង ប្រការ១វិញទៀត ព្រះយោគាវចរកុលបុត្រក្នុងបវរពុទ្ធសាសនាប្រកបដោយប្រាជ្ញា នឹងព្យាយាម ប្រតិបត្តិកាត់បង់ដកចេញនូវតណ្ហាឱ្យផុតអស់រលីងចាកសន្តានក៏គប្បីកាន់ យកនូវផ្លូវប្រតិបត្តិដូចយ៉ាងបុរសអ្នកធ្វើចម្ការនោះជាអារម្មណ៍ចុះធម្មតា បុរសអ្នកធ្វើចម្ការ កាលបើឃើញវល្លិ៍ឃ្លោកល្វីងដុះឡើងក្នុងទីចម្ការខ្លួនហើយ ក៏ស្រាវទងដងដើមវល្លិ៍នោះទាល់តែដល់គល់ ហើយដកល្បើកអស់ទាំងឫសមិនឱ្យសេសល់ ហើយចោលទៅឆ្ងាយដើម្បីនឹងមិនឱ្យដុះឡើងទៀតបាននោះមាន ឧបមាដូចម្ដេចមិញ ព្រះយោគាវចរកុលបុត្រមានព្យាយាម ក៏គប្បីប្រតិបត្តិកំចាត់បង់នូវឫសកែវ គឺតណ្ហាកុំឱ្យដុះកើតឡើងទៀតបានមានឧបមេយ្យដូច្នោះ បុរសដែលធ្វើចម្ការនោះប្រៀបដូច ព្រះយោគាវចរ ទីដីចម្ការនោះប្រៀបដូច អាយតន ១២ប្រការ មានចក្ខាយតនជាដើម អាយតនទាំង១២ នេះជាទីប្រជុំកើត នៃតណ្ហាជាអណ្ដូងកើតនៃតណ្ហា ហេតុដូច្នោះទើបសម្ដេចព្រះមហាករុណា ត្រាស់ទេសនាថាតណ្ហានោះជាឫសជាគល់នៃកងទុក្ខទាំងពួង បើរលត់តណ្ហាបានអស់ចាកសន្តានហើយ ទុក្ខទាំងឡាយមានជាតិទុក្ខជាដើមក៏រលត់អស់ជាមួយគ្នា សម្ដេចព្រះវិជិតមារទ្រង់ត្រាស់ទេសនាថា **សាខោចនេសាតិក្វាចេតណ្ហា** ដូច្នេះជាដើមថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានោះដែលបុគ្គល នឹងលះបង់បាន លះបង់បានក្នុងទីដូចម្ដេចរលត់បានក្នុងទីដូចម្ដេចទ្រង់ វិសជ្ជនា ដោយព្រះអង្គឯងថា សភាវធម៌ឯណា

www.budinst.gov.kh www.elibraryofcambodia.org

ដែលជាទីគួរគប្បីស្រឡាញ់ នឹងមាន សភាវជាទីត្រេកអរនៅក្នុងលោកតណ្ហា នោះកាលបើបុគ្គលនឹងលះបង់បាន ក៏លះបង់បានក្នុងសភាវធមិដែលជាទីគួរគប្បីស្រឡាញ់ នឹងជាទីត្រេកអរនោះឯង ដែលនឹងរលត់សោតក៏រលត់ក្នុងសភាវធមិដែលជាទីគួរគប្បីស្រឡាញ់ នឹងជាទីត្រេកនោះឯងដែរ នេះឯងហើយបានឈ្មោះថានិរោធអរិយសច្ច កាលសម្តេចព្រះសរពេជ្ញទ្រង់ទ្រាស់ទេសនាទុក្ខនិរោធអរិយសច្ចនោះ ព្រះអង្គលើកយកដើម ហេតុជាកិច្ចដែលរំលត់តណ្ហាលះបង់តណ្ហាបាន មិនអើពើអាលោះអាល័យក្នុង កាមគុណនោះមកសម្តែងជានិរោធអរិយសច្ចដោយប្រការដូច្នេះ អ្នកប្រាជ្ញគប្បីចូលចិត្តចុះ ថាការដែលព្រះអង្គលើកយកសមុទយនិរោធ គឺរំលត់តណ្ហាមក សម្តែងជាឈ្មោះនៃនិរោធសច្ចនោះប្រាថ្នានឹងឱ្យជាប្រយោជន៍ជាគុណ ដែលនឹងឱ្យពិចារណាឃើញមូលហេតុគឺតណ្ហា ដូចបានពណ៌នាមកដូច្នេះ ពីនេះនឹង សម្តែងអត្ថជា **ចុនចិចេះណនិយ** នឹងប្រែក្នុងអត្ថនៃព្រះបាឡីដែលព្រះអង្គទ្រង់ ប្រោសប្រទានព្រះសទ្ធម្មទេសនា ដែលទ្រង់សម្តែងថា អសេសវិរាគនិរោធោ នោះបើនឹងចែកចេញជាបីបទ អសេស បទ ១ វិរាគ បទ ១ និរោធ បទ ១ អសេស នោះប្រែថាមិនមានសេសសល់ វិរាគនោះ ប្រែថាអរិយមគ្គ និរោធ នោះប្រែថារលត់ហេតុដូចម្តេចបានជា វិរាគសព្ទ ប្រែថាអរិយមគ្គ នឹងមានអត្ថាធិប្បាយយ៉ាងណា ។

ដែលថាវិរាគសព្ទប្រែថាអរិយមគ្គនោះ ដោយអំណាចនឹងឱ្យឃើញអត្ថាធិប្បាយថា កាលបើព្រះអរិយមគ្គទាំង៤ មានព្រះសោតាមគ្គជាដើម មានព្រះអរហត្តមគ្គជាបរិយាសាន ធ្វើព្រះនិព្វានជាអារម្មណ៍ កើតឡើងក្នុងសន្តានហើយនោះ ព្រះសោតាមគ្គក៏លះបង់បាននូវ **ទិដ្ឋិសម្បយុត្ត ៤ វិចិកិច្ឆាសម្ប-**

www.budinst.gov.kh www.elibraryofcambodia.org

**យុត្តា** ជា ៥ ចិត្តព្រះសកិទាគាមមិគម្គនោះធ្វើនូវកាមរាគនឹងព្យាបាទដែល តគ្រោតៗនោះឱ្យសាបសូន្យថា **អនុប្បត្តិនិរោធ** ព្រះអនាគាមមិគ្គនោះលះបង់ បាននូវកាមរោគនឹងព្យាបាទ ដែលយ៉ាងល្អិតនឹងទោសចិត្តដាច់ចេញអស់ទាំង ពីរចិត្ត ព្រះអរហត្តមគ្គនោះលះបង់នូវ **ទិដ្ឋិចិប្បយុត្ត** ទាំង៤ចិត្តនឹង **ឧទ្ធច្ច-សម្បយុត្តា** ឱ្យសាបសូន្យជាសមុច្ឆេទ នឹងបានសេចក្តីត្រេកអរនៅក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វ កាមគុណឯណានីមួយក៏ឥតអង្គីមាន តណ្ហាដែលជា ភ្នាក់ងារជាអ្នកតាក់តែងនូវផ្ទះគឺកាយ មានប្រតីធ្វើឱ្យវិលទៅរកភពខាងមុខ ដែលចំណែកចែកចេញទៅជាកាមតណ្ហា ភវតណ្ហា វិភវតណ្ហាា នោះក៏រលត់ សូន្យ ចាកសន្តាននោះៗមិនបានត្រេកអរក្នុងភព មិនបានត្រេកអរក្នុងកាមគុណ ឯណា នីមួយមិនបានវង្វេងក្នុងអំណាចនៃតណ្ហា អាស្រ័យហេតុដែលនឹងឱ្យ ឃើញ អធិប្បាយយ៉ាងនេះ វិរាគសព្ទ ដែលប្រែថាប្រាសចាកត្រេកអរនោះ ក៏ញែកចេញជាអធិប្បាយជាព្រះអរិយមគ្គ ប្រែតាមអត្ថាធិប្បាយថាព្រះអរិយមគ្គ នេះសមនឹងឧទាហរណ៍ថា **វិរាគាវិមុច្ចតិ** ប្រែថាបុគ្គលរួចចាកតណ្ហាព្រោះ បានសម្រេចនូវអរិយមគ្គ តណ្ហាដែលនឹងប្រាសឃ្លាតចេញពីសន្តាននៃព្រះអរិយ បុគ្គលនោះ ក៏អាស្រ័យហេតុដែលព្រះអរិយមគ្គឈោងតោងយកព្រះនិព្វានជា អារម្មណ៍ ព្រះអរិយមគ្គទាំង៤ មានសោតាបត្តិមគ្គជាដើម មានព្រះអរហត្តមគ្គ ជាទីបំផុតនោះ ក៏អាស្រ័យហេតុដែលបានព្រះនិព្វានជាឧបនិស្ស័យបានព្រះ និព្វានជាអារម្មណ៍បច្ច័យហើយព្រះសោតាបត្តិមគ្គ នឹងព្រះសកិទាគាមិមគ្គអនា-គាមិមគ្គ ក៏លះបង់បាននូវកិលេសធម៌ទាំងពួងតាមមុខងាររបស់ខ្លួនៗដូចបាន ពណ៌នាមកហើយ ពួដ៏ខាងក្រោយឯព្រះអរហត្តមគ្គនោះក៏កំចាត់បង់នូវតណ្ហា ឱ្យវិបត្តិខ្ទាត់ចេញចាកសន្តានបានអស់ជាស្រេចជាសមុច្ឆេទបហាន ដែលជា

www.budinst.gov.kh www.elibraryofcambodia.org

សន្តាន នឹងប្រាសចាកសង្គិលេស នឹងប្រាសចាកតណ្ហា នឹងប្រាសចាកតណ្ហា នឹងប្រាសចាកសេចក្តីស្នេហា នឹងប្រាសចាកសេចក្តីត្រេកអរក្នុងកាមគុណនោះ អាស្រ័យហេតុដែលថាព្រះអរិយមគ្គទាំង៤ប្រការ បានព្រះនិព្វានជាអារម្មណ៍បច្ច័យ ហេតុដូច្នេះវិរាគសព្ទដែលប្រែថាប្រាសចាកត្រេកអរនោះ គឺប្រែជាសេចក្តីអធិប្បាយថា ព្រះនិព្វាន ឯនិរោធសព្ទដែលប្រែថា ព្រះនិព្វាននោះ ក៏មានអត្ថាធិប្បាយថា កាលបើព្រះអរិយមគ្គទាំង៤ ធ្វើឱ្យច្បាស់នូវព្រះនិព្វានឈោងតោងយកព្រះនិព្វានមកជាអារម្មណ៍បានហើយក្នុងកាលឯណា សំកិលេសតណ្ហាក៏រម្ងាប់សូន្យអន្តរធានអំពីសន្តានដោយលំដាប់ៗ គ្នាក្នុងកាលនោះស្រេចតែថាសំកិលេសនឹងតណ្ហារលត់ ជាហេតុដោយព្រះអរិយមគ្គទាំង៤ប្រការហ៊កធ្វើព្រះនិព្វានជាអារម្មណ៍បាន អាស្រ័យហេតុដូច្នេះ និរោធសព្ទនោះបានជាលោកប្រែតាមអធិប្បាយថា ព្រះនិព្វាន ឯពាក្យដែលថា ចាគសព្ទនឹងបដិនិស្សគ្គសព្ទ មុត្តិសព្ទ អនាលយសព្ទ ប្រែថាព្រះនិព្វាននោះសោតក៏មានអត្ថាធិប្បាយថា ក៏បើព្រះអរិយមគ្គទាំង៤លះបង់បាននូវសំកិលេសនឹងតណ្ហា ផុតអំពីអំណាចនៃសំកិលេសនឹងតណ្ហា មិនបានអើពើអាល័យនៅដោយកាមគុណនោះនឹងអាស្រ័យអារម្មណ៍ដទៃនោះ ឥតអង្គិមានឡើយព្រះនិព្វាននោះឯងហើយជាអារម្មណ៍ កាលបើឈោងតោងយកព្រះនិព្វានជាអារម្មណ៍បានក្នុងកាលឯណាហើយ ក៏លះបង់បាននូវតណ្ហាផុតចាកអំណាចនៃតណ្ហា មិនបានអើពើអាលោះអាល័យទៅដោយកាមគុណក្នុងកាលនោះ ហេតុដូច្នោះចាគសព្ទនឹងបដិនិស្សគ្គសព្ទ មុត្តិសព្ទ អនាលយសព្ទទាំង៤សព្ទនេះ បានជាប្រែតាមអធិប្បាយថាព្រះនិព្វានបាន បើនឹងពោលដោយលក្ខណ ព្រះនិព្វាននោះមានលក្ខណៈរម្ងាប់សភាវជាបច្ច័យឱ្យរម្ងាប់បង់នូវលោភ ទោស មោហ រម្ងាប់បង់នូវអវិជ្ជា

www.budinst.gov.kh www.elibraryofcambodia.org

នឹងតណ្ហា រម្ងាប់បង់នូវសំកិលេសទាំងពួងដែលធ្វើឱ្យស្មៅហ្មង ឱ្យវិលស្លាបវិល កើតវិលយកកំណើតក្នុងវដ្តសង្សារ នេះឯងជាលក្ខណៈនៃព្រះនិព្វាន បើនឹងពោលដោយកិច្ច ព្រះនិព្វានមានកិច្ចមិនបានចុតិ មិនដូចសំខារធម៌ទាំងឡាយ គឺនាមនឹងរូប ដែលកុសលនឹងអកុសលប្រជុំគ្នាតាក់តែងនោះរមែងដល់នូវសភាវបង្កើតនឹងទំលាយ ហេតុដូច្នេះឯង បានជាថាកិច្ចដែលមិនបានចុតិនេះជាកិច្ចព្រះនិព្វាន អធិប្បាយតាមពាក្យដីកាចារ្យថា ព្រះនិព្វាននោះមានអាការដូចជានឹងប្រលោមចិត្តអរិយបុគ្គល ដែលមានសន្តានទៀយណាយចាកសង្សារទុក្ខ ដែលមានសេចក្ដីត្រេកត្រអាលឱ្យប្រាសចាក សេចក្ដីត្រេកត្រអាលឱ្យស្បើយទុក្ខ ស្បើយក្ដៅក្រហាយ ឱ្យរីករាយនូវក្នុងសន្តាន បើនឹងពោលដោយផលនៃព្រះនិព្វាន តាមអធិប្បាយនៃចុល្លដីកាចារ្យនោះថា ព្រះនិព្វាននេះប្រាសចាកសង្ខតនិមិត្តជាផល អធិប្បាយថា សង្ខតនិមិត្តគឺកុសលនឹង អកុសលនឹងអកុសល ដែលជាហេតុជាបច្ច័យប្រជុំតាក់តែងនាមនឹងរូបឱ្យវិល កើតយកកំណើតក្នុងភពទាំងបី គឺកាមភព រូបភព អរូបភពនោះ នឹងបានមានក្នុងព្រះនិព្វានធម៌នោះឥតអត្ថិមាន បបញ្ចធម៌ទាំងពួងមានរាគបបញ្ចជាដើម ដែលធ្វើឱ្យសត្វទាំងឡាយយឺតយូរនៅក្នុងវដ្តសង្សារនោះសោត ក៏មិនដែលមានក្នុងព្រះនិព្វានៗនេះជាបច្ច័យឱ្យរលត់បង់នូវរាគាទិបបញ្ច ហេតុដូច្នេះបានជាពោលថា ព្រះនិព្វានធម៌នោះមានសភាវប្រាសចាកសង្ខតនិមិត្តជាផល មានសភាវជាហេតុឱ្យរំលត់បង់នូវបបញ្ចធម៌ មានរាគជាដើមជាផលដោយប្រការដូច្នេះ ព្រះអដ្ឋកថាចារ្យកាលបើសម្ដែងលក្ខណៈនឹងកិច្ចផលនៃព្រះនិព្វានដូចន័យផ្សេងៗ ដែលបានពណ៌នាមកហើយក្នុងខាងក្រោយ ក៏លោកពិចារណាឃើញថា អំណើសតទៅខាងមុខប្រាជ្ញកុលបុត្រនឹងថយចុះរាល់ជាន់រាល់ថ្នាក់

www.budinst.gov.kh www.elibraryofcambodia.org

នឹងចូលចិត្តជឿប្រកាន់ថាព្រះនិព្វាននោះមាននៅ ខ្លះក៏នឹងឃើញថាព្រះនិព្វាននោះមិនមាន អ្នកដែលជឿប្រកាន់ថាព្រះនិព្វានមាននៅនោះសោតក៏នឹងចូលចិត្តនោះផ្សេងៗ គ្នាអ្នកខ្លះនឹងចូលចិត្តថា អតីតអនាគតក្ខន្ធ ដែលមិនមានក្នុងបច្ចុប្បន្ននោះជាព្រះនិព្វាន អ្នកខ្លះក៏នឹងចូលចិត្តថាដែលមិនមានបច្ចុប្បន្នក្ខន្ធនោះជាព្រះនិព្វាន អ្នកខ្លះក៏នឹងចូលចិត្តថាសភាវមិនមានកិលេសក្នុងខណៈដែលព្រះអរិយមគ្គកើតនោះជាព្រះនិព្វាន អ្នកខ្លះក៏ចូលចិត្តថាសភាវ អស់ទៅនៃរាគទោសមោហនោះជាព្រះនិព្វាន នឹងចូលចិត្តផ្សេងៗគ្នាយ៉ាងនោះជាដើម ហើយក៏នឹងវិវាទជជែកដណ្តើមត្រូវរាល់គ្នាមិនដាច់ស្រេចទៅខាងណារកអ្នកវិនិច្ឆ័យកាត់សេចក្តីមិនបាន ក៏នឹងកើតជាចម្រូងចម្រាស់ក្នុងព្រះពុទ្ធសាសនា ព្រះអដ្ឋកថាចារ្យពិចារណាឃើញហេតុយ៉ាងនេះ ទើបតាំងជាពាក្យបុច្ឆា វិសជ្ជនាទុកដើម្បីនឹងឱ្យកាត់សេចក្តីសង្ស័យនៃកុលបុត្រ ដែលនឹងកើតជាចំណែកខាងមុខឯពាក្យបុច្ឆាជាបឋមនោះថា តត្ថេវនិព្វានំ ព្រះនិព្វាននោះបុគ្គលឯណានីមួយនឹងបានភប់ប្រសព្វធ្លាប់ឃើញរូបពណ៌សណ្ឋានថា ប្រការដូចម្តេចៗនោះក៏ឥតអត្ថិមាន ពាក្យដែលថា ព្រះនិព្វាននោះកាលបើពីគ្រោះទៅដូចក៏លោកវោហារដែលហៅថាស្នែងទន្សាយៗនោះ ជាពាក្យមិនពិត ពាក្យនេះតើមានឧបមាដូចម្តេច ពាក្យដែលថាព្រះនិព្វានមាននោះ យើងក៏ឃើញថាជាពាក្យមិនពិតទេមានឧបមេយ្យដូច្នោះឯង ឯអធ្យាស្រ័យយើងនេះពិចារណាឃើញថាព្រះនិព្វានគ្មានដូចស្នែងទន្សាយដែរ ។ វិសជ្ជនាថា ដែលអ្នកនឹងយកព្រះនិព្វានមកប្រៀបនឹងស្នែងទន្សាយនេះមិនសមគួរសោះ នឹងយកអធិប្បាយថាស្នែងទន្សាយ មិនមានយ៉ាងណាព្រះនិព្វានមិនមានយ៉ាងនោះ អ្នកនឹងប្រកាន់យកអធិប្បាយយ៉ាងនេះពេញជាខុសណាស់ ព្រោះព្រះនិព្វាននោះបុគ្គលអ្នកជាកល្យាណបុថុជ្ជ-

www.budinst.gov.kh www.elibraryofcambodia.org

នគប្បី ដឹងដោយឧបាយពិត ។ កល្យាណបុថុជ្ជនទាំងឡាយដែលបានស្តាប់ត្រាប់ត្រងរសព្រះធម្មទេសនាចូលចិត្តដោយគំនិតថា ព្រះនិព្វានមានជាពិតដោយន័យព្រះពុទ្ធដីកាដែលព្រះអង្គទ្រង់ប្រោសប្រទានព្រះធម្មទេសនា ហើយមានសេចក្តីឧស្សាហ៍ប្រតិបត្តិក្នុង សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាក្ខន្ធ ដោយសមគួរដល់ពុទ្ធឱវាទនោះក៏មុខគួរជានឹងបានឃើញ នឹងបានសម្រេចនូវព្រះនិព្វានដោយជាក់ច្បាស់ក្នុងសន្តាន ដោយកាលកំណត់ឆាប់ យូរ តាមសមគួរដល់វាសនាបារមីនៃខ្លួនដែលបានសាងសន្សំអប់រំមមក តែថាបើនឹងបានសម្រេចនូវព្រះនិព្វាននោះ បានតែបុគ្គលដែលប្រកបដោយឧបាយ ពោលគឺសេចក្តីឧស្សាហ៍ ប្រតិបត្តិដោយសមគួរតាមពុទ្ធឱវាទនោះដែរ ឯបុគ្គលជាពាលបុថុជ្ជនដែលមិនបានប្រតិបត្តិតាមពុទ្ធឱវាទនោះ ក៏នឹងកន្លងដឹងកន្លងឃើញទៅបាន ព្រះនិព្វាននេះចំពោះឃើញជាក់ច្បាស់ក្នុងសន្តាននៃព្រះអរិយបុគ្គលនោះ ពាលបុថុជ្ជននឹងកន្លងដឹង កន្លងឃើញទៅបាន នឹងដឹងឃើញបានតែលោកដែលជាព្រះអរិយបុគ្គលដែលបានសម្រេចចេតោបរិញ្ញាដូចគ្នា ទុកជាលោកដែលបានសម្រេចតេតោបរិញ្ញាដូចគ្នា ទុកជាលោកដែលបានសម្រេចចេតោបរិញ្ញា ដូចគ្នាក៏មែន តែថាខ្លួនបានសម្រេចមគ្គផលយ៉ាងទាប ក៏មិនអាចនឹងដឹង នឹងឃើញនូវលោកកុត្តរចិត្ត នៃលោកដែលបានសម្រេចមគ្គផលយ៉ាងខ្ពស់ ស្រេចតែថាដឹងវាវរចិត្តគ្នានោះតាមជាន់តាមថ្នាក់ជាលំដាប់ៗគ្នា នឹងបានទូទៅសព្វតែរាល់គ្នានោះក៏ឥតអត្ថិមាន លោកដែលជាព្រះសោតាបន្នបានចេតោបរិញ្ញានោះ ក៏ចំពោះដឹងបានតែចិត្តនៃបុថុជ្ជន នឹងចិត្តនៃលោកដែលសម្រេចសោតាបត្តិផលដូចគ្នាមិនអាចនឹងដឹងរម្លងឡើងទៅដល់ចិត្ត នៃព្រះសកិទាគាមិ ឯព្រះសកិទាគាមិដែលបានសម្រេចចេតោបរិញ្ញានោះ ក៏ដឹងចំពោះតែចិត្តនៃព្រះសោតា

www.budinst.gov.kh www.elibraryofcambodia.org

បន្ទនឹងចិត្តនៃព្រះសកិទាគាមិដូចគ្នា មិនអាចនឹងដឹងរម្លងឡើងទៅដល់ចិត្តនៃព្រះអនាគាមិ ព្រះអរហន្តមានតែព្រះអរហន្តដែលបានសម្រេចចេតោបរិញ្ញានោះឯង ទើបនឹងដឹងច្បាស់នូវលោកុត្តរចិត្ត ព្រះអរិយបុគ្គលទាំងអស់ឥតមានសេសសល់នេះ ឯងហើយបណ្ឌិតកប្បីសន្និដ្ឋានចូលចិត្តចុះ សូម្បីតែព្រះអរិយបុគ្គលនឹងព្រះអរិយបុគ្គលដូចគ្នា គង់ដឹងវារចិត្តគ្នាដោយជាន់ដោយថ្នាក់ដូច្នេះ នឹងបាច់និយាយទៅថ្វី ដល់ពោលបុថុជ្ជនដែលមានបញ្ញាទន់ទាបទៅដោយកិលេសក្រាស់ បុថុជ្ជនណាអាចនឹងដឹងនូវលោកកុត្តរចិត្តៗ នោះដឹងចំពោះតែព្រះអរិយបុគ្គលដែលបានសម្រេចចេតោបរិញ្ញាដូចគ្នានេះ ម្តេចក៏ស្មើរតែនឹងមិនដឹង ព្រះនិព្វានធម៌នោះ ក៏ដឹងចំពោះតែក្នុងចិត្តសន្តាននៃព្រះអរិយបុគ្គលប៉ុណ្ណោះ ដែលមិនបានជួបប្រទះមិនបានដឹងមិនបានយល់ ព្រះនិព្វាននោះតែពាលបុថុជ្ជនដែលក្រាស់ទៅដោយកិលេសនោះឯង កល្យាណបុថុជ្ជនដែលប្រតិបត្តិសមគួរតាមពុទ្ធឱវាទ ហើយក៏អាចនឹងបានសម្រេចនូវព្រះនិព្វានដោយពិត តាមវាសនាបារមីរបស់ខ្លួន អាស្រ័យហេតុដូច្នេះ ដែលអ្នកនឹងប្រកាន់អធិប្បាយថា ពាលបុថុជ្ជនមិនបានព្រះនិព្វានទេ នឹងប្រកាន់យ៉ាងនេះមិនគួរឡើយ**ឧត្តិតិឧចត្តាវុំ** ម្នាលអាចារ្យអ្នកកុំគប្បីពោលថាព្រះនិព្វានមិនមាន បើអ្នកយល់តែតាមអធ្យាស្រ័យរបស់អ្នកថា ពាលបុថុជ្ជនមិនបានព្រះនិព្វានសោះ ព្រះនិព្វានគ្មានសោះ អ្នកឃើញយ៉ាងនេះពេញជាខុសនឹងព្រះពុទ្ធដីកាសម្តេចព្រះបរមសាស្តាចារ្យទ្រង់សម្តែងសរសើរសម្មាប្រតិបត្តិថាជា អនវជ្ជធម៌ សម្មាប្រតិបត្តិទាំង៨ប្រការនោះតាំងអំពីសម្មាទិដ្ឋិជាដើមដរាបដល់សម្មាសមាធិជាទីបំផុត សម្តេចព្រះសុគតទ្រង់ទេសនាសង្គ្រោះចូលក្នុងខន្ធ៣គឺ **សីលក្ខន្ធ សមាធិក្ខន្ធ បញ្ញាក្ខន្ធ** សម្មាទិដ្ឋិនឹងសម្មាសង្កប្បោរាប់ចូលក្នុង **បញ្ញាក្ខន្ធ** សម្មាវាយាមោ

www.budinst.gov.kh www.elibraryofcambodia.org

សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីពរៀបរាប់ចូលក្នុង **សីលក្ខន្ធ** សម្មាសតិ សម្មាសមាធិរាប់ចូល ក្នុងសមាធិក្ខន្ធ សម្មាប្រតិបត្តិទាំង៨ប្រការនេះ សម្តេចព្រះសាស្តាចារ្យទ្រង់សរសើរថាជាអនវជ្ជធម៌ ដោយអំណាចកាត់កិលេសឱ្យសោះសូន្យឱ្យដល់នូវព្រះអមតនិព្វាន បើព្រះនិព្វានមិនមានមែនដូចពាក្យអ្នកថា សម្មាប្រតិបត្តិទាំង៨ប្រការ ក៏មិនបានជាអនវជ្ជធម៌មិនអាចនឹងកំចាត់បង់នូវកិលេសឱ្យសោះសូន្យ ចាកសន្តានបានឯសម្មាប្រតិបត្តិជាអនវជ្ជធម៌នោះដោយអំណាចដែលបាន ឈោងតោងយកព្រះនិព្វានមកជាអារម្មណ៍ សម្លាប់កិលេសមបានហើយទើប ថាអនវជ្ជធម៌បាន ព្រោះតែសម្លាប់នូវកិលេសនោះឯង បើព្រះនិព្វានមិនមាន សម្មាប្រតិបត្តិឥតអ្វីជាទីឈោងប្រតោងសម្លាប់កិលេសបានឡើយ ពាក្យដែលថា សម្មាប្រតិបត្តិជាអនវជ្ជធម៌នោះ ក៏នឹងខុសទៅហើយ អាចារ្យជាអ្នកចោទ្យ បើអ្នកនឹងពោលថាសម្មាប្រតិបត្តិទាំង៨ប្រការជាអនវជ្ជធម៌ ដោយអំណាចជាឧបាយឱ្យផ្តាច់បង់នូវកិលេស ហើយឱ្យដល់នូវកិរិយារំលត់ខន្ធមិនឱ្យមានខន្ធ បញ្ចកតទៅអាស្រ័យហេតុដែលឱ្យដល់នូវសេចក្តីរំលត់ខន្ធនេះឯងហើយ ទើបបានយើងយល់ថាសម្មាប្រតិបត្តិជាអនវជ្ជធម៌ទៅដោយពិតសម្មាប្រតិបត្តិ នឹងបានជាអនវជ្ជធម៌ ដោយអំណាចដែលឱ្យដល់នូវព្រះនិព្វានក៏ឥតអត្ថិមានឡើយ បើអ្នកថាដូច្នេះ ពាក្យអ្នកដែលពោលចោទ្យថា ព្រះនិព្វានមិនមាននោះ នឹងពាក្យក្រោយដែលអ្នកទទួលមកថាសម្មាប្រតិបត្តិជាអនវជ្ជធម៌ ដោយអំណាច ជាឧបាយឱ្យរំលត់កិលេស ហើយសម្រេចកិរិយារំលត់ខន្ធនោះ ពាក្យទាំងពីរនេះ ក៏លុបលាងតែគ្នាឯងពាក្យដែលជាសម្មាប្រតិបត្តិជាអនវជ្ជធម៌ដោយអំណាច ជាឧបាយឱ្យផ្តាច់បង់នូវកិលេសឱ្យស្រេចនូវកិច្ចរំលត់ខន្ធ នេះឯងជាពាក្យ បដិញ្ញាណថាព្រះនិព្វានមានក្នុង

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយរបស់អ្នកបដិញ្ញាណថា "សភាវមិនមានខន្ធបញ្ចកៗ មិនមាននោះជាព្រះនិព្វាន ពាក្យបដិញ្ញាណរបស់អ្នកនេះមិនទាន់គួរនៅឡើយទេ ហេតុអ្វី ហេតុថាអតីតក្ខន្ធអនាគតក្ខន្ធ មិនមានក្នុងបច្ចុប្បន្ននេះ ដែលនឹងចាត់យកជាព្រះនិព្វាននឹងបានឈ្មោះថា ដល់នូវព្រះនិព្វាននោះក៏ទេ ម្នាលអាចារ្យជាអ្នកចោទ្យ កាលបើពិគ្រោះមើលទៅតាមន័យរបស់អ្នកដែលថា ខន្ធបញ្ចក មិនមាននោះ នឹងថាជាខន្ធអតីត ខន្ធអនាគត ខន្ធបច្ចុប្បន្ន បើជា ខន្ធបច្ចុប្បន្ន ហើយក៏នឹងថាមិនមានដូចម្ដេចទៅ ចេញឈ្មោះបច្ចុប្បន្ន ហើយក៏គង់មាននៅជាពិត ទើបបានឈ្មោះថាបច្ចុប្បន្នខន្ធឡើយ ពាក្យដែលថាសម្មាប្រតិបត្តិជាអនវជ្ជធម៌នោះ ក៏នឹងខុសទៅហើយ អាចារ្យជាអ្នកចោទ្យ បើអ្នកនឹងពោលថាសម្មាប្រតិបត្តិទាំង៨ប្រការជាអនវជ្ជធម៌ ដោយអំណាចជាឧបាយ ឱ្យផ្ដាច់បង់នូវកិលេស ហើយឱ្យដល់នូវកិរិយារំលត់ខន្ធមិនឱ្យមានខន្ធ បញ្ចកទៅអាស្រ័យហេតុដែលឱ្យដល់នូវសេចក្ដីរំលត់ខន្ធនេះឯងហើយ ទើបបានយើងយល់ថាសម្មាប្រតិបត្តិជាអនវជ្ជធម៌នៅដោយពិត សម្មាប្រតិបត្តិនឹង បានជាអន-វជ្ជធម៌ ដោយអំណាចដែលឱ្យដល់នូវព្រះនិព្វានក៏ឥតអត្ថិមានឡើយ បើអ្នកថាដូច្នេះពាក្យអ្នកដែលពោលចោទ្យថា ព្រះនិព្វានមិនមាននោះ នឹងពាក្យក្រោយដែលអ្នកទទួលមកថាសម្មាប្រតិបត្តិជាអនវជ្ជធម៌ដោយអំណាច ជាឧបាយឱ្យរំលត់កិលេស ហើយសម្រេចកិរិយារំលត់ខន្ធនោះ ពាក្យទាំងពីរនេះក៏លុបលាងតែគ្នាឯង ពាក្យដែលថាសម្មាប្រតិបត្តិជាអនវជ្ជធម៌ដោយអំណាចជាឧបាយឱ្យផ្ដាច់បង់នូវកិលេសឱ្យស្រេចនូវកិច្ចរំលត់ខន្ធ នេះឯងជាពាក្យបដិ ញ្ញាណថាព្រះនិព្វានមានក្នុងអធិប្បាយរបស់អ្នកបដិញ្ញាណថា សភាវមិនមាន ខន្ធបញ្ចកៗ មិនមាននោះជាព្រះនិព្វាន ពាក្យបដិញ្ញាណរបស់អ្នកនេះមិនទាន់ គួរនៅឡើយ

www.budinst.gov.kh www.elibraryofcambodia.org

ទេ ហេតុអ្វី ហេតុថាអតីតក្ខន្ធអនាគតក្ខន្ធមិនមានក្នុងបច្ចុប្បន្ននេះ ដែលនឹងថាត់យកជាព្រះនិព្វាននឹងបានឈ្មោះថា ដល់នូវព្រះនិព្វាននោះក៏ទេ ម្នាលអាចារ្យជាអ្នកចោទ្យ កាលបើពិគ្រោះមើលទៅតាមន័យរបស់អ្នកដែលថា ខន្ធបញ្ចកមិនមាននោះ នឹងថាជាខន្ធអតីត ខន្ធអនាគត ខន្ធបច្ចុប្បន្ន បើជាខន្ធបច្ចុប្បន្នហើយក៏នឹងថាមិនមានដូចម្តេចទៅ ចេញឈ្មោះបច្ចុប្បន្នហើយក៏តង់មាននៅជាពិត ទើបបានឈ្មោះថាបច្ចុប្បន្ន ខន្ធឯណាមាននៅជាពិតហើយ ខន្ធនោះក៏បានឈ្មោះថា បច្ចុប្បន្នក្ខន្ធ ឯពាក្យអ្នកដែលថាខន្ធមិនមាននោះ ទំនងជាខន្ធអតីតជាខន្ធអនាគត ហេតុអ្វី ហេតុដូច្នោះទើបបានជាខន្ធជាអតីតខន្ធជាអនាគតឈ្មោះខន្ធមិនមាន ។ អធិប្បាយតាមពាក្យដីកាចារ្យថា ខន្ធដែលជាអតីតអនាគតខន្ធមិនមាននោះ ព្រោះហេតុថា មិនមាននៅក្នុងបច្ចុប្បន្នពិត ខន្ធដែលជាអតីតនោះបានឈ្មោះថា មិនមាន ព្រោះហេតុថារលត់កន្លងហួសទៅហើយក្នុងអតីត មិនមាននៅក្នុងបច្ចុប្បន្ន ខន្ធដែលជាអនាគតនោះសោតក៏បានឈ្មោះថាមិនមាន ព្រោះថាមិនទាន់មកកើត សភាវមិនមានយ៉ាងនេះ បើនឹងឃើញថាជាព្រះនិព្វានហើយ ព្រះនិព្វានក៏នឹងបានទូទៅក្នុងសន្តានទៃសត្វទាំងឡាយ ដែលជាអតីតក្ខន្ធអនាគតក្ខន្ធនោះ នឹងមាននៅក្នុងបច្ចុប្បន្ននេះក៏ឥតអត្ថិមានឡើយ ហេតុនេះបណ្ឌិតគប្បីសន្និដ្ឋានចូលចិត្តចុះថា ខន្ធដែលជាអតីតអនាគត ទុកជាគ្មានក្នុងបច្ចុប្បន្ននឹងចាត់ថាជាព្រះនិព្វាន ថាដល់នូវព្រះនិព្វាននោះ ថាមិនបានទេ អាការដែលមិនមានឃើញប្រាកដយ៉ាងនេះ មិនបានឈ្មោះថាដល់នូវព្រះនិព្វាន លុះតែកាលណាខន្ធដែលតាំងនៅក្នុងខន្ធទាំង៣ គឺអតីត អនាគត បច្ចុប្បន្ន មិនមានព្រមទាំង៣ស្ថាន ហើយទើបចាត់ថាជាព្រះនិព្វានបាន ដែលមិនមានខន្ធគ្រាន់តែជាឯកទេសមិនមាន

www.budinst.gov.kh www.elibraryofcambodia.org

នោះនឹងហៅថា ព្រះនិព្វានមិនសមគួរទេ ក្នុងទីនេះពិចារណាឃើញដោយអត្តនោមតិថា ចំណែកអ្នកចោទ្យនោះ កាលបើឃើញគួរតាមពាក្យចម្លើយ ដាច់ស្រេចក្នុងទីដែលឃើញថា ព្រះនិព្វានមានពិតមែន អ្នកចោទ្យប្រកាន់លទ្ធិថា ខន្ធដែលរលត់ហើយកន្លងទៅៗនោះ ទុកជារលត់មិនបានជាអនុប្បត្តិនិរោធរលត់មិនបានដាច់ក៏គង់នៅជាកំញ្ចមកំទេចពូជឱ្យបង្កើតខន្ធដទៃទៀតក្តី អាការដែលរលត់គ្រាន់តែជាខណៈៗ គ្រាន់តែជាឯកទេសក្តី ក៏ចាត់ឈ្មោះថាជាព្រះ-និព្វានបាន ចំណែកអាចារ្យអ្នកឆ្លើយក៏ដោះថា ខន្ធដែលរលត់ហើយនៅគង់កំញ្ចមកំទេចពូជឱ្យបង្កើតខន្ធដទៃជាដំណៅ រលត់មិនបានជាអនុប្បត្តិនិ-រោធរលត់មិនបានដាច់ដូច្នោះ បើនឹងចាត់យកជាព្រះនិព្វាន ហើយព្រះនិព្វានក៏នឹងសម្រេចទូទៅដល់សត្វទាំងពួង ដោយហោចសូម្បីតែសត្វតិរច្ឆានក៏នឹងបានឈ្មោះថា សម្រេចព្រះនិព្វានដែរ ហេតុថាចាត់យកកិរិយាដែលរលត់មិនដាច់ដូច្នោះ អាការដែលរលត់ខន្ធគ្រាន់តែជាខណៈៗ ជាឯកទេសរលត់មិនដាច់ដូច្នោះ បើនឹងចាត់យកជាព្រះនិព្វានហើយ ចិត្តដែលកើតឡើងជាខណៈៗហើយរលត់កន្លងទៅក្នុងសន្តាននៃសត្វទាំងឡាយនេះក្តី ខណៈចិត្តដែលនៅមិនទាន់បង្កើតក្នុងខាងមុខនោះក្តី ក៏នឹងបាននាមបញ្ញត្តិឈ្មោះថា ព្រះនិព្វានទាំងអស់នោះ ព្រោះខណៈចិត្តដែលរលត់កន្លងទៅជាអតីតខណៈនោះ នឹងបានមាននៅក្នុងបច្ចុប្បន្នក្ខន្ធនោះក៏ទេ ខណៈចិត្តដែលនៅមិនទាន់បង្កើតក្នុងខាងមុខនោះសោតនឹងបានមាននៅក្នុងបច្ចុប្បន្ននេះក៏ទេដែរ នេះឯងទើបបានយើងឃើញថាកិរិយាដែលរលត់មិនបានជាអនុប្បត្តិនិរោធរលត់មិនដាច់ រលត់ហើយនៅមានកំញ្ចមពូជឱ្យកើតខន្ធដទៃទៀតនោះ នឹងបានឈ្មោះថាដល់នូវព្រះនិព្វានក៏ទេ ពិចារណាឃើញដោយអត្តនោមតិនៃខ្លួនដោយប្រការដូច្នេះ ។ លំដាប់

www.budinst.gov.kh www.elibraryofcambodia.org

នោះអ្នកឆ្លើយពោលដោះថា ម្នាលអាចារ្យអ្នកចោទ្យបើអ្នកនឹងមានពាក្យឡើង ទៀតថា សភាវរលត់ខន្ធដ៏ជាបច្ចុប្បន្ន មិនមានខន្ធ ជាបច្ចុប្បន្ននោះឯងឈ្មោះ ព្រះនិព្វាន បើអ្នកនឹងមានពាក្យចោទយ៉ាងនេះទៀតក៏មិនគួរហេតុអ្វី ហេតុថា ព្រះនិព្វានកើតអំពីខន្ធជាបច្ចុប្បន្ននោះ បើថាខន្ធជាបច្ចុប្បន្នគ្មានហើយ ព្រះនិព្វានក៏គ្មានដែរ ន័យមួយវិញទៀតថាខន្ធឯណាមិនមាន ខន្ធនោះក៏មិន បានឈ្មោះថាបច្ចុប្បន្ន ស្រេចតែថាខន្ធឯណាជាបច្ចុប្បន្ន ខន្ធនោះមាននៅពិត ឯខន្ធមិនមានហើយ ខន្ធនោះក៏មិនបានជាបច្ចុប្បន្ន តែដំណើរដែលអ្នកថាមិន បានមានខន្ធជាបច្ចុប្បន្នបានឈ្មោះថា ព្រះនិព្វាននោះ ពាក្យអ្នកឯងក៏ទាស់ ពាក្យឯង កាលបើខន្ធជាបច្ចុប្បន្នមាននៅហើយ ដូចម្ដេចហើយក៏មកពោលថា គ្មានទៅវិញ តែថាជាបច្ចុប្បន្នហើយក៏មាននៅជាពិត ទើបនឹងហៅថាជា បច្ចុប្បន្នបាន នេះឯងអ្នកគប្បីចូលចិត្តចុះ ថាពាក្យដែលអ្នកបដិសេធន៍ថា បច្ចុប្បន្នគ្មាននោះបដិសេធន៍ខុសទេ សភាវមានបច្ចុប្បន្នក្ខន្ធនៅនេះទើបឱ្យ សម្រេចព្រះនិព្វានបាន ដែលនឹងត្រាស់ដឹងនូវព្រះនិព្វាននោះក៏អាស្រ័យនឹង បច្ចុប្បន្នក្ខន្ធបើមិនមានបច្ចុប្បន្នជាទីអាស្រ័យហើយក៏មិនបានសម្រេចព្រះនិព្វាន ឡើយ ព្រោះថាព្រះនិព្វាននេះជាអារម្មណ៍នៃព្រះអរិយមគ្គអរិយផល ព្រះអរិយ មគ្គដែលធ្វើព្រះនិព្វានជាអារម្មណ៍មកបង្កើតបាននោះ ក៏អាស្រ័យនៅខន្ធទាំង ៥ ដ៏ជាបច្ចុប្បន្ន ទុកជាបុគ្គលដែលកើតក្នុងអរូបភពគ្មានរូបក្ខន្ធ ក៏នៅមានវេទ នាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធខន្ធដែលជាបច្ចុប្បន្ននោះជាទីអាស្រ័យ ជាទីទទួលទ្រព្រះអរិយមគ្គធ្វើព្រះនិព្វានជាអារម្មណ៍នោះ ទើបព្រះអរិយមគ្គនឹង មកកើតបាន អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ឧបចារជវនទីងអនុលោម ជវន គោ ត្រកូជវនកើតមានក្នុងមគ្គវិថីនោះសុទ្ធតែចាត់ជាបច្ចុប្បន្ន វិញ្ញាណ

www.budinst.gov.kh www.elibraryofcambodia.org

ក្ខន្ធទាំងអស់ ទុកជាមគ្គចិត្តដែលធ្វើព្រះនិព្វានជាអារម្មណ៍នោះសោតក៏ចាត់ឈ្មោះថា វិញ្ញាណក្ខន្ធជាបច្ចុប្បន្ន ហេតុដូច្នេះទើបយើងឃើញថាព្រះនិព្វាននឹងប្រព្រឹត្តទៅបានសម្រេចទៅបាននោះ អាស្រ័យនឹងបច្ចុប្បន្នក្ខន្ធ បើគ្មានបច្ចុប្បន្នក្ខន្ធជាទីអាស្រ័យហើយក៏មិនអាចនឹងបានសម្រេចព្រះនិព្វានបានឡើយ ម្នាលអាចារ្យ ដែលអ្នកនឹងយល់ថាគ្មានបច្ចុប្បន្នក្ខន្ធនោះជានិព្វាននេះមិនគួរ បើអ្នកនៅតែចចេសយល់ដូច្នោះ ពាក្យដែលអ្នកថាព្រះអរិយបុគ្គលដែលបានសម្រេចឧបាទិសេសនិព្វានធាតុ រលត់តែកិលេស បញ្ចក្ខន្ធមិនទានលត់ពាក្យនេះក៏នឹងទៅជាខុស សឧបាទិសេសនិព្វានធាតុក៏នឹងមិនមាននេះមិនដូច្នោះ សឧបាទិសេសនិព្វានធាតុមាននៅព្រះអរិយមគ្គដែលធ្វើព្រះនិព្វានជាអារម្មណ៍ អាស្រ័យនូវបច្ចុប្បន្នក្ខន្ធ ហើយកើតឡើងនោះមាននៅដោយពិត ព្រះអរិយបុគ្គលដែលនឹងសម្រេចឧបាទិសេសនិព្វានធាតុរលត់តែកិលេស បញ្ចក្ខន្ធជាបច្ចុប្បន្នជាបច្ចុប្បន្នមិនទាន់រលត់នៅឡើយ គង់ទ្រទ្រង់នៅប្រោសសត្វទាំងពួងនៅឡើយនេះឯងហើយទើបយើងឃើញច្បាស់ថា ដំណើរដែលអ្នកកាន់យកអធិប្បាយថាសភាវមិនមានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាននោះមិនគួរសោះម្នាលអាចារ្យ ជាអ្នកចោទ្យ បើអ្នកនឹងមានពាក្យសឹកចូលមកទៀតថា ដំណើរដែលថាគ្មានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាននោះពាក្យយើងមិនខុសទេ ហេតុអ្វីហេតុដែលថាបច្ចុប្បន្ននោះយើងពោលដោយកងកិលេសទេតើ រូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធ យើងមិនបានហៅបច្ចុប្បន្នក្ខន្ធទេ ក្នុងខណព្រះអរិយមគ្គធ្វើព្រះនិព្វានជាអារម្មណ៍ ហើយកើតឡើងក្នុងលំដាប់នៃគោត្រភូជវននោះ ព្រះអរិយមគ្គ នឹងបានកំចាត់បង់នូវកិលេសខន្ធដោយខ្លួនឯងក៏ឥតអង្គីមាន លុះតែកិលេសខន្ធនោះអស់ទៅដោយអំណាចអនុលោម ដ៏កើតព្រមដោយអនុលោម

www.budinst.gov.kh www.elibraryofcambodia.org

ទាំង៣នោះ ហើយអាស្រ័យនូវកិលេសខន្ធដែលអស់ទៅមុន មិនមានក្នុងខណៈ ដែលព្រះអរិយមគ្គកើតនេះឯងបានជាយើងយល់អធិប្បាយថា សភាវមិនមាន បច្ចុប្បន្នក្ខន្ធនោះឯងជាព្រះនិព្វាន បើអ្នកឯងនឹងមានពាក្យសឹកច្រៀកចូលមក ទៀត ដូច្នេះថា **ខយុត្តំ** ពាក្យអ្នកក៏នៅមិនទាន់គួរនៅឡើយ ហេតុអ្វីហេតុ ប្រកាន់អធិប្បាយយ៉ាងនេះហើយ ព្រះអរិយមគ្គក៏ដល់នូវភាវឥតប្រយោជន៍ ឯព្រះអរិយមគ្គនេះប្រកបដោយប្រយោជន៍ជាច្រើនណាស់ កាត់ សកាត់គល់ នៃកិលេសធម៌ទាំងពួងផង កិលេសដែលអស់ទៅដោយអំណាចអនុលោម ញាណក្នុងខណអនុលោមជវនទាំង៣នោះ អស់ទាំងកិលេសយ៉ាងគ្រោតគ្រាត យ៉ាងកណ្តាល យ៉ាងល្អិត បណ្តាដែលធ្វើឱ្យល្អក់ឱ្យសៅហ្មងក្នុងគន្លងព្រះអរិយ មគ្គ កិលេសដែលជាមន្ទិលបិទបាំងមិនឃើញនូវព្រះនិព្វាននោះសោត អនុ លោមជវនក៏កំចាត់បង់បានអស់ជាស្រេច នឹងនៅសល់ក៏តែអនុសយៗជាឫស កែវយាងចុះចាក់ស្រេះមាំ អនុលោមជវនមិនអាចនឹងដកបើឡើងបាន អនុលោម ជវនកំចាត់បង់បានតែកិលេសដែលយ៉ាងគ្រោតគ្រាត នឹងយ៉ាងកណ្តាលយ៉ាង ល្អិតនេះ មានគួរនាដូចជាបុគ្គលៗ ពួកទៅបេះផ្លែស្វាយ ពួកមួយជាដម្បូងបេះ យកតែផ្លែធំៗនាំយកទៅ ពួកបន្ទាប់ជាគំរប់ពីរនោះ បើយកតែយ៉ាងកណ្តាលៗ នាំយកទៅ ពួកខាងក្រោយជាគំរប់បីនោះ បេះយកផ្លែតូចៗទាល់តែអស់រលីង ឥតមានសេសសល់សោះ ឯដើមស្វាយនោះឥតមានអ្នកឯណានឹងកាប់រំលំ រំលើង សគល់ ដល់ឆ្នាំក្រោយទៀតដល់កំណត់ទេសកាល ក៏លាស់ត្រួយ បញ្ចេញផ្កាផ្លែមកទៀត នឹងបានដាច់អស់ផុតគ្មានផ្កាគ្មានផ្លែក៏ឥតអង្គីមានឡើយ នេះតើមានឧបមាដូចម្តេចវិញ ផ្លែស្វាយយ៉ាងធំយ៉ាងកណ្តាលយ៉ាងល្អិតនោះ មានឧបមេយ្យដូចកិលេសយ៉ាងគ្រោតគ្រាតយ៉ាងធំៗ យ៉ាងកណ្តាលយ៉ាងល្អិត

www.budinst.gov.kh www.elibraryofcambodia.org

បុគ្គល៣ ពួកដែលរើសផ្លែស្វាយនោះ មានគួរនាដូចអនុលោមជវនទាំង៣ដ៏ កំចាត់បង់នូវកិលេសយ៉ាងថ្លោសគ្រោតគ្រាតយ៉ាងកណ្តាល យ៉ាងល្អិត១ កិលេសដែលខ្ចាត់ចេញចាកសន្តានដោយអំណាចអនុលោមទាំង៣នោះ បើមិនមានព្រះអរិយមគ្គកាត់ផ្តាច់ឫសគល់មូលហេតុ គឺអនុសយធម៌ចេញបានទេ អនុសយមាននៅដរាបណា កិលេសក៏នឹងត្រឡប់មកបង្កើតទៅបានក្នុងសន្តានចិត្តមិនបានដាច់សោះ ជាប់នៅដរាបនេះ មានឧបមាដូចផ្លែស្វាយអស់ទៅ ហើយតែដើមសល់នៅ គង់នឹងត្រឡប់មានផ្កាផ្លែកើតឡើងទៀតមិនខាន អនុលោមញាណដែលកើតព្រមជាមួយ នឹងអនុលោមជវននោះមានសំខតធម៌ជាអារម្មណ៍ដូចវិបស្សនាញាណទាំងពួង មិនអាចនឹងលះបង់កិលេសឱ្យជាសមុច្ឆេទបហានបាន ដែលថាកិលេសនឹងដាច់ស្រឡះមិនត្រឡប់កើតឡើងវិញបាននោះ ដោយអំណាចព្រះអរិយមគ្គៗ ជាអ្នកកាត់ផ្តាច់ឫសផ្តាច់គល់មានសភាពយ៉ាងនេះ ឯអ្នកនឹងឃើញថាព្រះអរិយមគ្គមិនបានកំចាត់បង់នូវកិលេសទាំងអស់នេះមិនគួរទេ ម្នាលអាចារ្យជាអ្នកចោទ្យ ក៏ពាក្យអ្នកពោល «តាំងពីដើមមកថា កាលបុថុជ្ជនមិនអាចនឹងបានព្រះនិព្វានទេ នឹងពាក្យដែលថាមិនមានព្រះនិព្វាននោះក្តី ពាក្យដែលថាសម្មាបដិបត្តិជាអនវជ្ជធម៌ ដោយអំណាចកាត់កិលេស ហើយឱ្យដល់នូវវលត់ខន្ធ នឹងបានជាអនវជ្ជធម៌ដោយអំណាចឱ្យដល់នូវព្រះនិព្វាននោះក្តី ពាក្យដែលអ្នកថាអតីតក្ខន្ធ អនាគតក្ខន្ធជាព្រះនិព្វាននោះក្តី ពាក្យដែលថាគ្មានបច្ចុប្បន្នក្ខន្ធជាព្រះនិព្វាននោះក្តី ពាក្យទាំងអស់នេះអត្ថិហេតុអត្ថិបច្ច័យអត្ថិទីអត្ថិស្ថាន ដែលគួរនឹងជឿស្តាប់យកជាដម្រាប់ត្រាប់តាមជាបែបជាផែន ជាប្រធានបានឡើយ នឹងពោលទៅថ្វីដល់ពាក្យដែលថាកិលេសគ្មានក្នុងខណព្រះអរិយមគ្គកើត ហើយជាព្រះនិព្វាននោះ ពាក្យដែលថាកិលេស

www.budinst.gov.kh www.elibraryofcambodia.org

គ្មានក្នុងខណៈដែលព្រះអរិយមគ្គកើត ពាក្យនេះជាលទ្ធិខុស អត្ថិហេតុអត្ថិបច្ច័យ ម្នាលអាចារ្យ ជាអ្នកចោទ្យ បើថាអ្នកនឹងមានពាក្យច្រៀតឡើងទៀតថា ដែលអស់រាគទោស មោហនោះឯងជាព្រះនិព្វាន ព្រោះមានបាឡីក្នុងជម្ពុខាទកសូត្រ ព្រះធម្មសេនាបតីសារីបុត្តត្ថេរសម្តែង នឹងព្រះសង្ឃទាំងឡាយថាម្នាលអាវុសោទាំងឡាយ សភាវអស់រាគ អស់ទោស អស់មោហនេះឯងឈ្មោះថាព្រះនិព្វាន ម្យ៉ាងទៀត មានព្រះបាឡី ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ ទេសនាក្នុងធម្មាតនវិភង្គថា **កតមោ អសំខតធាតុ** អសំខតធាតុពោលគឺព្រះនិព្វាននោះតើដូចម្តេច ទើបព្រះអង្គទ្រង់វិសជ្ជមនាព្រះអង្គឯងថា **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** អស់រាគអស់ទោស អស់មោហនោះឯងឈ្មោះថាអសំខតធាតុ ពោលគឺព្រះនិព្វាន អាស្រ័យហេតុបាឡីក្នុងជម្ពុខាទកសូត្រ នឹងបាឡីក្នុងធម្មាយតនវិភង្គសម្តែងទុកជាប្រធានដូច្នេះ ទើបយើងឃើញថាអស់រាគ ទោស មោហ នោះឯងជាព្រះនិព្វាន ម្នាលអាចារ្យជាអ្នកចោទ្យ បើអ្នកនឹងមានពាក្យពោលឡើងយ៉ាងនេះក៏មិនគួរ ហេតុការន្រព្រះអរហត្តផល នឹងនាមបញ្ញត្តិឈ្មោះថា អសំខតនោះមានដែរ ម្នាលអាចារ្យជាអ្នកចោទ្យ ពាក្យដែលអ្នកអាងប្លែកទៅរកបាឡីថា **រាគក្ខយោ ទោសក្ខយោ មោហក្ខយោ** នោះហើយប្រកាន់យកតែតាមបាឡីថាអស់រាគ អស់ទោសអស់មោហជាព្រះនិព្វាននោះមិនគួរទេ ព្រោះថាបាឡីក្នុងព្រះសូត្រខ្លះលោកសម្តែងជាឈ្មោះនៃអរហត្តផល នឹងបានសម្តែងជាឈ្មោះនៃព្រះនិព្វានតែមួយក៏ទេ វាវព្រះបាឡីក្នុងជម្ពុខាទកសូត្រ ដែលព្រះធម្មសេនាបតី សារីបុត្តសម្តែងនោះក្តី វាវព្រះបាឡីដែលព្រះសម្មាសម្ពុទ្ធទេសនាក្នុងធម្មាយតនវិភង្គនេះក្តី ព្រះបាឡីទាំង២ អន្លើនេះ បណ្ឌិតគប្បីសន្និដ្ឋានថាជានេយត្ថ គឺប្រកបដោយន័យដ៏គប្បីនឹងវិសជ្ជនាដោះស្រាយចេញទៅជាច្រើន

www.budinst.gov.kh www.elibraryofcambodia.org

ហេតុដូច្នេះព្រះអដ្ឋកថាចារ្យអ្នកដឹងនូវពុទ្ធាធិប្បាយទើបវិសជ្ជនាថា ពាក្យដែលថាមានព្រះបាឡីថារាគក្ខយោ ទោសក្ខយោ មោហក្ខយោនោះគប្បីចូលចិត្តចុះថារាគទោសមោហដែលនឹងអស់ទៅនោះអាស្រ័យនឹងព្រះនិព្វាន ព្រះអរិយមគ្គទាំង៤ ប្រការនោះបានព្រះនិព្វានជាទីអាស្រ័យឈោងតោងយកព្រះនិព្វានហើយ ទើបកំចាត់រាគទោសមោហឱ្យអស់ចេញ បានអំពីសន្តាន ទើបមានពាក្យដីកាចារ្យវិសជ្ជនាទៀតថា កាលគោត្រភូញាណត្រឡប់ចិត្តដែលជាបុថុជ្ជនឱ្យដល់នូវភាវជាអរិយគោត្រហើយ ឱ្យបង្អោនទៅកាន់ព្រះនិព្វាន ឃ្លៀយណាយចាកសំខារធម៌ទាំងពួង ឈោងតោងយកព្រះនិព្វានជាអារម្មណ៍បានហើយលំដាប់នោះ ព្រះអរិយមគ្គក៏អាស្រ័យយកព្រះនិព្វានដែលគោត្រភូញាណធ្វើឱ្យជាក់ច្បាស់នោះ យិតប្រតោងយកជាអារម្មណ៍នៃខ្លួន សំឡឹងយកព្រះនិព្វានដែលប្រាសចាកសំខារនោះ ជាទីឈប់សម្រាកព័ទ្ធព័ន្ធយកជាគតិដ៏ឧត្តមត្រេកអរក្នុងព្រះនិព្វាន ដ៏បង្កើតជាអធិបតិបច្ច័យ ហើយក្នុងកាលឯណា ព្រះអរិយមគ្គនោះ ក៏ញាំងរាគទោសមោហឱ្យអស់ទៅអំពីសន្តានជាសមុច្ឆេទឱ្យរលត់ជាអនុប្បត្តិនិរោធបានក្នុងកាលនោះ ស្រេចតែថាអស់រាគទោសមោហនោះ ក៏អាស្រ័យនឹងព្រះនិព្វានទើបអស់ជាសមុច្ឆេទ ហេតុដូច្នោះព្រះបាឡី រាគក្ខយោ ទោសក្ខយោ មោហក្ខយោនោះ ទើបលោកសម្តែងថាជាឈ្មោះនៃព្រះនិព្វាន បណ្ឌិតមានប្រាជ្ញាគប្បីពិចារណាឱ្យឃើញអធិប្បាយក្នុងជម្ពុខាទកសូត្រនឹងធម្មាយតនវិភង្គដូចអធិប្បាយដែលព្រះអដ្ឋកថា ដីកាចារ្យវិសជ្ជាទុកដូច្នេះនឹងឃើញសេចក្តីថា អស់រាគ ទោស មោហ ជាព្រះនិព្វាននោះយល់ទាស់ណាស់ គប្បីចូលចិត្តចុះថា ជម្ពុខាទកសូត្រក្តីធម្មាយតនវិភង្គក្តី ដូចជាសូត្រតែមួយកាលបើពិចារណាមើលសេចក្តី តាមវារព្រះបាឡីក្នុងជម្ពុខាទកសូត្រនោះ

www.budinst.gov.kh www.elibraryofcambodia.org

ឃើញដូចជាថា លក្ខណៈដែលអស់រាគទោសមោហនោះឯង ជាអរហត្តផល តែថាពុំប្រកាន់អធិប្បាយដូច្នោះឡើយ គប្បីឃើញអធិប្បាយដូច្នេះវិញថា ព្រះអរហត្តមគ្គញាណ ពីព្រះនិព្វានជាអារម្មណ៍កំចាត់បង់នូវអនុសយដែល ជាឫសជាគល់នៃកិលេសឱ្យអស់សូន្យសោះ ជាសមុច្ឆេទមិនឱ្យសេសសល់នៅ បានក្នុងកាលឯណាហើយ ព្រះអរហត្តផលដែលធ្វើព្រះ និព្វានជាអារម្មណ៍នោះ ទើបកើតឡើងក្នុងកាលនោះ ស្រេចតែថាព្រះអរហត្ត ផលនោះកើតក្នុងទីបំផុត នៃកាលដែលអស់កិលេស ហេតុដូច្នេះឯងបានជា ព្រះធម្មសេនាបតិសារិបុត្ត លើកយកបាឡីថា រាគក្ខយោជាដើមនោះមកសម្តែង ជាឈ្មោះនៃអរហត្តផល បណ្ឌិតគប្បីពិចារណាឱ្យយល់អធិប្បាយនេះចុះ ទើបនឹងគួរដែលនឹងប្រកាន់ យកតាមព្រះបាឡីដែលថាអស់រាគទោសមោហជាព្រះអរហត្តផលជាព្រះនិព្វាន នោះមិនគួរទេ ព្រះអរហត្តផលនោះសំដៅយកខន្ធទាំង៤ គឺវេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធដែលជាដើមជា ប្រធាននោះទេតើ អាការ ដែលអស់រាគ ទោស មោហនោះនឹងបានជាព្រះអរហត្តផលក៏ទេ ហេតុដូច្នេះ បណ្ឌិតអ្នកដែលនឹងអធិប្បាយសេចក្តីក្នុងជម្ពុខាទក សូត្រនឹងធម្មាយតវិភង្គនោះ គប្បីអធិប្បាយតាមន័យនៃព្រះអដ្ឋកថាចារ្យដែល លោកសម្តែងមកនេះចុះ នឹងអធិប្បាយយកតាមព្រះបាឡីថា អស់រាគទោស មោហជាព្រះនិព្វាននោះ ខុសនឹងពុទ្ធាអធិប្បាយ អ្នកប្រាជ្ញទាំងឡាយគួរពិចារ ណាមើលឱ្យឃើញតែជិតៗ ដោយអត្តនោមតិទៅចុះថា រាគាទិកិលេសប្រៀប ដូចគំនរភ្លើងព្រះនិព្វាន នោះប្រៀបដូចទឹកសម្រាប់លត់ភ្លើងព្រះអរិយមគ្គនោះ ដូចជាបុរសជាអ្នកនាំ យកទឹកមកលត់ភ្លើង កាលបើគំនរភ្លើងនោះរលត់ដោយព្យាយាមនៃបុរស ដែលយកទឹកមកស្រោចរលត់ភ្លើងនោះយ៉ាងនេះហើយ កាលបើកិលេសរលត់

www.budinst.gov.kh www.elibraryofcambodia.org

ទៅដោយអំណាចព្រះអរិយមគ្គដ៏ធ្វើនូវព្រះនិព្វានជាអារម្មណ៍ ដូច្នោះហើយ នឹងប្រកាន់លទ្ធិថាធម៌ជាអារម្មណ៍នៃព្រះអរិយមគ្គ ដែលជាឧបនិស្ស័យឱ្យលត់កិលេសជាសមុច្ឆេទនោះ នឹងបានឈ្មោះថាព្រះនិព្វានក៏ទេ សភាវដែលអស់រាគ ទោស មោហ នេះវិញបានឈ្មោះថានិព្វាន នឹងប្រកាន់លទ្ធិ យ៉ាងនេះហៅថាប្រកាន់ខុសមិនគួរទេ ប្រការមួយទៀតក្នុងបទថា **ខយោនិព្វានំ** នេះពិចារណាឃើញដោយអត្ថនោមត្យាធិប្បាយថា ចំណែកខាងអាចារ្យអ្នកចោទនោះប្រកាន់លទ្ធិថា អាការដែលអស់នៃរាគាទិកិលេសមែន បើអស់ជាឯកទេសអស់តែមួយខណៈៗ អស់មិនបានជាសមុច្ឆេទ ក៏អាចនឹងហៅថាព្រះនិព្វានបានដោយអត្ថនោមតិ ឃើញថាអ្នកចោទ្យប្រកាន់លទ្ធិយ៉ាងនេះ ហេតុដូច្នោះបានជាមានបទព្រះបាឡីថា **កិញ្ចិតិយេ្យានិព្វានផតរកោ រាគិតោស ឆោ** ម្នាលអាចារ្យជាអ្នកចោទ្យ បើអ្នកប្រកាន់យកអធិប្បាយដូចពាក្យអ្នកថាមកនោះ ព្រះនិព្វានក៏នឹងដល់នូវអាការជាកាមាវចរហើយ ជាសំខតលក្ខណផងព្រោះថាអាការដែលអស់កិលេសគ្រាន់តែជាខណៈៗ យ៉ាងដូច្នោះសម្រេចដោយកាមាវចរចិត្ត សម្រេចដោយហេតុបច្ច័យប្រជុំតាក់តែង ន័យមួយវិញទៀតមានពាក្យដីកាចារ្យវិសជ្ជនាថា បើនឹងប្រកាន់អធិប្បាយថាអស់រាគទោសមោហតែខណៈៗនោះជានិព្វានហើយ បុគ្គលដែលមិនលោភមិនខឹងមិនវង្វេងមានសន្តានរម្ងាប់ស្ងប់ស្ងាត់មួយស្របក់មួយសំកាំងនេះ ក៏នឹងបានឈ្មោះថាសម្រេចព្រះនិព្វានដោយកិច្ចធម្មតាខ្លួនឯង មិនបាច់ខ្វល់ខ្វាយខំព្យាយាមប្រព្រឹត្តនូវសម្មាប្រតិបត្តិទៅទេ ព្រោះហេតុដែលថាបានសម្រេចព្រះនិព្វានដោយធម្មតាចិត្តខ្លួនឯង បើយល់យ៉ាងនេះហើយ បុគ្គលទាំងពួងក៏នឹងបានព្រះនិព្វានទាំងអស់គ្នា ពាក្យដែលថាព្រះនិព្វានជាទីរំលត់ទុក្ខនោះគនឹងខុសពាក្យដែលថា

www.budinst.gov.kh www.elibraryofcambodia.org

ព្រះនិព្វានល្អិតជាអារម្មណ៍នៃគោត្រភូញាណនិងមគ្គញាណនោះក៏នឹងខុសហេតុ ដូច្នោះទើបឃើញថាអាការដែលអស់រាគាទិកិលេសក្នុងខណៗ នោះនឹងបាន ឈ្មោះថា ព្រះនិព្វានក៏ទេ មួយទៀតមានវាក្យព្រះបាឡីដីកាចារ្យវិសជ្ជនាថា អាការដែលអស់រាគទោសមោហនោះផ្សេងៗគ្នាដែរ នឹងបានដូចគ្នាក៏ទេ កាល ណាបើអស់រាគនោះ នឹងហៅថាអស់ទោសមោហក៏ហៅមិនបាន កាលបើអស់ ទោសនោះវិញនឹងហៅថា អស់រាគមោហក៏ថាមិនបាន កាលបើអស់មោហ នោះហៅថា អស់រាគទោសក៏ថាមិនបានអាការដែលអស់រាគ ទោសមោហនោះ ផ្សេងគ្នាយ៉ាងនេះ បើប្រកាន់អធិប្បាយថា អស់រាគទោសមោហថាព្រះនិព្វាន ប្រកាន់យកអធិប្បាយយ៉ាងនោះហើយ ព្រះនិព្វានក៏នឹងបែកញែកចេញទៅ ម្យ៉ាងៗ ដោយខ្លួនពីគ្នា អាការដែលអស់រាគក៏នឹងទៅជានិព្វាន១ អាការដែល អស់ទោសក៏នឹងទៅជានិព្វាន១ អាការដែលអស់មោហក៏នឹងទៅជានិព្វាន១ បែកញែកចេញទៅទីទៃៗ ពីគ្នាដូច្នេះ ព្រោះអាការដែលអស់រាគ អស់ទោស អស់មោហនោះផ្សេងៗគ្នា មិនបានដូចគ្នា កាលបើជាព្រះនិព្វានបែកគ្នាមួយៗ ដោយអស់កិលេសនោះៗដូច្នោះហើយ ព្រះនិព្វានក៏នឹងបែកខ្វែកទៅដោយ ប្រភេទច្រើនជាងរយជាងពាន់ គឺខណអស់ឧបាទាន៤ ព្រះនិព្វានក៏នឹងទៅជា ៤ អស់នីវរណ ៥ ព្រះនិព្វានក៏នឹងទៅជា ៥ អស់តណ្ហាខាងក្នុង ៦ ព្រះនិព្វានក៏ នឹងទៅជា ៦ អស់អនុសយ ៧ ព្រះនិព្វានក៏នឹងទៅជា ៧ អស់មិច្ឆត្តនិយមទាំង ៨ អស់តណ្ហាមូលទាំង ៩ អស់សំយោជនទាំង ១០ ព្រះនិព្វានក៏នឹងទៅជា ៨ យ៉ាងជា ៩ យ៉ាងជា ១០ យ៉ាង តាមលំដាប់កិលេសដែលអស់ទៅដោយកំណត់ ច្រើននឹងតិច ខណដែលកាត់កិលេសទាំង ១៥០០ ព្រះនិព្វានក៏នឹងបែចេញទៅ ជា ១៥០០ នឹងទៅជាផ្សេងៗដោយប្រភេទជាច្រើនយ៉ាង នេះព្រោះឃើញ

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីយកតែតាមបាឡីថា អស់រាគ អស់ទោស អស់មោហនោះជាព្រះនិព្វាន ហេតុដូច្នេះអ្នកមានប្រាជ្ញាគប្បីយល់អធិប្បាយក្នុងបទថា រាគ ទោស មោហ នឹងអស់ទៅជាសមុច្ឆេទនោះ អាស្រ័យនឹងព្រះនិព្វានៗ នោះនឹងបែកខ្ញែកចេញទៅដោយប្រភេទផ្សេងៗ ជាម្យ៉ាងៗច្រើនជារយជាពាន់ដូច្នោះនោះ ក៏ឥតអត្ថិមានឡើយ ព្រះនិព្វានក៏មានតែ ១ ប៉ុណ្ណោះ តែថាជាហេតុរំលត់កិលេសទាំងពួងមានរាគទោសមោហជាដើម អាស្រ័យនឹងព្រះនិព្វានហើយទើបបានអស់ទៅ បានជាលោកសម្តែងថា រាគក្ខយទោសក្ខយមោហក្ខយនោះជាឈ្មោះនៃព្រះនិព្វាន គប្បីឃើញអធិប្បាយយ៉ាងនេះ កុំគ្បីឃើញអធិប្បាយថាអាការដែលអស់រាគ ទោស មោហជាព្រះនិព្វានឡើយមិនគួរទេ កិរិយាដែលអស់កិលេសទៅជាតទង្គបហានក៏នឹងទៅជា ព្រះនិព្វានតែទាំងអស់គ្នា កាលបើថាត់យកកិរិយាដែលអស់កិលេសទៅជាតទង្គបហាននោះជាព្រះនិព្វានហើយ ព្រះនិព្វានក៏នឹងបានទូទៅសព្វក្នុងសន្តានសត្វទាំងពួងមិនរើសមុខ សូម្បីតែថាមនុស្សអន្ធពាលអាប់ឥតប្រាជ្ញា ក៏អាចនឹងបានព្រះនិព្វាន ក្នុងកាលខ្លះម្តងៗដែរ ហេតុសន្តាននៃមនុស្សអន្ធពាលនោះមិន គឺថានឹងមានចិត្តអាក្រក់លាមកល្មក់សៅហ្មងទៅដោយរាគទោសមោហតែរាល់វេលាជានិច្ចទៅក៏ទេ ជួនកាលក៏អស់រាគ ជួនកាលក៏អស់ទោស ជួនកាលក៏អស់មោហ ជាឯកទេសម្តងៗដោយហោចសូម្បីតែសត្វតិរច្ឆានមានដើមថាខ្លា ម្រឹគពានក៏មានកាលកំណត់អស់ រាគ ទោស មោហមួយស្របក់ មួយសម័យខ្លះម្តងៗដែរ បុគ្គលគប្បីសង្កេតមើលបានដោយងាយ បើអស់រាគ ទោស មោហ មួយខណៈ ១ នោះ នឹងជាព្រះនិព្វានបានម្តងៗ ហើយព្រះនិព្វានក៏នឹងទូទៅដល់សត្វតិរច្ឆានដ៏ជាអហេតុបដិសន្ធិ ព្រោះថាអាការដែលអស់កិលេសយ៉ាងដូច្នោះ នឹងបានជាអារម្មណ៍នៃព្រះអរិយ

www.budinst.gov.kh www.elibraryofcambodia.org

មគ្គ ព្រះអរិយផលក៏ទេ ឯណាមាននាមបញ្ញត្តិឈ្មោះថា ព្រះនិព្វាននោះ សំដៅយកធម៌ដែលជាអាម្មណ៍ នៃព្រះអរិយមគ្គអរិយធម៌ផលផ្សេង អាការ ដែលអស់កិលេសយ៉ាងដូច្នោះ មិនបានជាអារម្មណ៍នៃព្រះអរិយមគ្គ អរិយផល បានទេ អាស្រ័យហេតុយ៉ាងនេះនឹងហៅឈ្មោះថា ព្រះនិព្វាននោះមិនសមគួរ ទេ ម្នាលអាចារ្យជាអ្នកចោទ្យ ពិតណាស់កុលបុត្តដែលមានបញ្ញាភិសម្ភារដ៏ទុំ ក្លៀវក្លា ពិចារណាឃើញទោសនៃកាមគុណហើយ លះបង់ឃរាវាសចេញបួស ជាបព្វជិតចំរើនឈានសមាបត្តិជាលោកិយសង្កត់សង្កិននូវរាគកិលេសដោយ អំណាចឈាន មិនបានសាបសូន្យអំពីឈាន លុះទម្លាយបញ្ចក្ខន្ធក៏បានឡើងទៅ ឧបត្តិបង្កើតក្នុងព្រហ្មលោក ស្ថិតនៅក្នុងព្រហ្មលោកនោះ ទាល់តែដរាបអស់ កាលកំណត់នៃអាយុហើយ ចុតិត្រឡប់ចុះមកកើតក្នុងមនុស្សលោកវិញ ក៏ជា សត្វបរិសុទ្ធិមិនបានត្រេកអរក្នុងកិលេសកាម នឹងវត្ថុកាម លះបង់ឃរាវាស ចេញបព្វជ្ជាក្នុងព្រះពុទ្ធសាសនា បានលុះព្រះអរហត្ត ត្រាស់ដឹងនូវព្រះនិព្វាន ក្នុងបច្ឆិមជាតិ ដូចជាបិប្ផលិមាណពតីព្រះមហាកស្សប នឹងនាងភទ្ទាកាបិលា នីមហាថេរីដូច្នោះ ធ្លាក់តែអស់កិលេសមានរាគជាដើម ដោយអំណាចឈាន ជាវិក្ខម្ភនបហានមកអំពីមុន នៅមិនទាន់បានសម្រេចព្រះនិព្វាននៅដល់ពីរបី ជាតិទៀត យ៉ាងនេះកិលេសដែលអស់ទៅដោយអំណាចឈាននោះអស់មិន បានដាច់ ប្រសិនបើទៅជួបប៉ះពាល់ពានទៅលើអារម្មណ៍ឯណាមួយ ដែលគួរ នឹងត្រេកអរប្រព្រឹត្តទៅក្នុងកាមគុណ កិលេសនោះក៏នាំមកកើតវិញទៀតទៅ បានហេតុអ្វី ហេតុថាប្រាជ្ញាដ៏សម្បយុត្តដោយឈានមានបឋមឈានជាដើម នោះមានសម្មតិសត្វជាអារម្មណ៍ មិនអាចនឹងលះកិលេឱ្យជាសមុច្ឆេទបហាន បាន ហេតុដូច្នោះទើបឃើញថាសភាវអស់កិលេសដោយឈាននោះ បើនឹង

www.budinst.gov.kh www.elibraryofcambodia.org

ចាត់ថាជាព្រះនិព្វានហើយ ព្រះនិព្វានក៏នឹងចាត់ថាជាកាមាវចរហើយជាសំខត លក្ខណ ប្រកបទៅដោយទោសផ្សេងៗផង បណ្ឌិតគប្បីសន្និដ្ឋានចុះថា សូម្បី តែបានព្រះអរិយមគ្គ ហើយនឹងត្រឡប់យកឡើងថាជាព្រះនិព្វានក៏នៅថាខុស ចំណង់បើថាគ្រាន់តែអស់រាគទោសមោហប៉ុណ្ណោះ មកថាជាព្រះនិព្វានដូចម្ដេច បាន ពាក្យដែលថាអស់រាគទោសមោហជាព្រះនិព្វាននោះជាលទ្ធិខុស ប្រៀប ដូចបុគ្គលជារោគដោយថ្នាំ ត្រឡប់ជាឃើញថាត្រង់ជារោគនោះជាថ្នាំទៅវិញ ហេតុដូច្នេះបណ្ឌិតគប្បីពិចារណាឱ្យឃើញច្បាស់ថា រាគាទិកិលេសដែលអស់ ទៅជាសមុច្ឆេទ ជាអនុប្បត្តិនិរោធខយនោះ នឹងថាអស់ដោយអរិយមគ្គតែម្យ៉ាង ក៏ថាមិនបាន នឹងថាអស់ទៅដោយព្រះនិព្វានតែម្យ៉ាងក៏ថាមិនបាន ស្រេចតែថា ព្រះនិព្វានជាទីអារម្មណ៍នៃព្រះអរិយមគ្គ ពេទ្យជីវិសេសពោលគឺព្រះអរិយមគ្គ នោះ កាលបើបានឱសថថ្នាំជីវិសេសពោលគឺព្រះនិព្វាន ឈោងតោងយិតយក ព្រះនិព្វានជាអារម្មណ៍បានហើយ ក៏ញាំងរោគាព្យាធិអាពាធទាំងពួង គឺរាគ ទោសមោហកិលេសធម៌ទាំងពួង ឱ្យវិនាសសាបសូន្យទៅជាអនុប្បត្តិនិរោធ ខយ ។ អើក៏កាលព្រះអរិយមគ្គនឹងព្រះនិព្វានធ្វើឱ្យកិលេសសូន្យទៅ ជាអនុ ប្បត្តិនិរោធខយយ៉ាងនេះហើយ ថ្វីហើយក៏មិនបានឃើញថាធម៌ដែលជាអារម្ម ណ៍ បច្ច័យនៃព្រះអរិយមគ្គនោះជាព្រះនិព្វាន ឯអាការដែលអស់រាគទោស មោហដែលមិនបានជាអារម្មណ៍នៃព្រះអរិយមគ្គ ដែលមិនមែនជាព្រះនិព្វាន នោះ ត្រឡប់ឃើញថាជាព្រះនិព្វានវិញ ឃើញយ៉ាងនេះពេញជាខុសមិនគួរទេ ឯព្រះបាឡីថា រាគក្ខយោទោសក្ខយោមោហក្ខយោនោះ លោកក៏សម្ដែងថាជា ឈ្មោះនៃព្រះអរហត្ត ក្នុងសូត្រខ្លះសម្ដែងថាឈ្មោះនៃព្រះនិព្វាន ក្នុងសូត្រខ្លះ សម្ដែងថាជាឈ្មោះនៃព្រះអរិយមគ្គ សម្ដែងខុសៗគ្នាដូច្នេះ បើជាមានពាក្យ

www.budinst.gov.kh www.elibraryofcambodia.org

ចោទឲ្យមកទៀតថា ហេតុធ្វើបានជាអង្គព្រះសព្វញ្ញូសម្មាសម្ពុទ្ធ កាលត្រាស់ទេសនាសម្ដែងព្រះនិព្វាននោះ ក៏មិនបានសម្ដែងដោយសរុប ឯចិត្តនឹងចេតសិកនឹងរូបនោះ ព្រះអង្គសម្ដែងដោយសរុបរួបរួមគ្នាចងទុកជាចំណែកជាចង្កោមៗ តែត្រង់ព្រះនិព្វានមួយនេះ ថ្វីក៏ព្រះអង្គមិនសម្ដែងដោយសរុបរួបរួមគ្នា ចងទុកជាដុំជាចង្កោមដូចជាចិត្តចេតសិករូបធម៌នោះផង អាស្រ័យហេតុផលប្រការដូម្ដេច ។

ពាក្យវិសជ្ជនាដោះថា **អតិសុខុមតា** ដំណើរដែលព្រះអង្គមិនបានសម្ដែងព្រះនិព្វានដោយសរុបនោះ ព្រោះព្រះនិព្វានល្អិតសុខុមក្រៃលែងល្អិតសុខុមណាស់ នឹងរកអ្វីមកប្រៀបផ្ទឹមស្មើពុំបាន ព្រះនិព្វាននេះជាធម៌វិសេសកំពូលធម៌ទាំងពួងជាអារម្មណ៍ នៃព្រះអរិយមគ្គអរិយផលដ៏ល្អិតក្រៃលែងល្អិតផុតវិស័យបុថុជ្ជន នឹងកន្លងដឹងកន្លងឃើញ ចំពោះដឹងឃើញបានតែប្រាជ្ញាព្រះអរិយបុគ្គល ទុកជានឹងសម្ដែងដោយសរុប ពិស្ដារទៅ ក៏ផុតវិស័យបុថុជ្ជននឹងធ្លៀតដឹងដោយប្រាជ្ញា លុះតែកាលណាបើបានសម្រេចមគ្គផលហើយ ក៏អាចនឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបានដោយបញ្ញាចក្ខុ ហេតុដូច្នេះបានជាព្រះអង្គមិនខ្វល់ខ្វាយនឹងសម្ដែងព្រះនិព្វានដោយ សរុបដូចអមតធម៌ទាំងពួង ក្នុងទីនេះមានពាក្យដីកាចារ្យវិសជ្ជនាថា មានពាក្យព្រះអដ្ឋកថាចារ្យសម្ដែងថា ព្រះនិព្វាននោះល្អិតក្រៃលែងល្អិតណាស់ ផុតវិសយ័លបុគ្គលដ៏ជាបុថុជ្ជននឹងចាក់ដឹងយល់ឃើញបាន ចំពោះតែប្រាជ្ញព្រះអរិយបុគ្គលនោះ ទើបនឹងដឹងយល់ឃើញបាន ពាក្យនេះត្រូវណាស់សមនឹងព្រះពុទ្ធភាសិតដែលព្រះករុណាទ្រង់សម្ដែងនឹងមាគណ្ឌិយព្រាហ្មណ៍ថា មាគណ្ឌិយ អរិយចក្ខុំ នត្ថិ យេន ត្វំ **អារោគ្យំ ជានេយ្យាសិ និព្វានំ បស្សេយ្យាសិ** ថាម្នាលមាគណ្ឌិយព្រាហ្មណ៍

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនអ្នកនេះរកអរិយចក្ខុមិនទាន់បានៗ ជាអ្នកនៅមិនទាន់ឃើញនូវព្រះនិព្វាន មិនទាន់ស្គាល់នូវធម៌ដ៏រកហេតុគ្មានពោល គឺព្រះនិព្វានបើអ្នកបានសម្រេចនូវអរិយចក្ខុពោលគឺបាននូវបញ្ញាជារបស់នៃព្រះអរិយបុគ្គលជាក់ច្បាស់ក្នុងសន្តានហើយ អ្នកក៏នឹងបានឃើញនូវព្រះនិព្វាន នឹងស្គាល់នូវធម៌ដ៏រកហេតុគ្មានពោល គឺព្រះនិព្វានក្នុងកាលនោះ ព្រះពុទ្ធភាសិតព្រះអង្គទ្រង់ត្រាស់ទេសនានឹងមាគណ្ឌិយ ព្រាហ្មណ៍ដូច្នេះគួរនឹងពោលថាព្រះនិព្វានល្អិតក្រៃលែងល្អិត ចំពោះឃើញបានតែប្រាជ្ញានៃព្រះអរិយបុគ្គល ។

មួយទៀតសោត មានពាក្យដីកាចារ្យវិសជ្ជនាថា ព្រះអដ្ឋកថាចារ្យអ្នកដឹងពុទ្ធាធិប្បាយលោកឃើញថា អ្នកដែលមានសំនួននោះនឹងសឹកសួរចូលមកថា ព្រះនិព្វាននោះជាសភាវធម៌មិនរាប់ចូលក្នុងសន្តានសត្វទេ គឺថាមិនបានចាត់ក្នុងកងរូបធម៌ នាមធម៌ឯណាមួយសោះ អាការនៃព្រះនិព្វាននោះឃើញហាក់ថានឹងជាសព្វសាធារណ គួរនាដូចរោងជាទីប្រជុំទីចំណតអាស្រ័យដ៏មាននៅផ្លូវបំបែក ៤ រោងនោះជាសព្វសាធារណតាមតែចិត្តមហាជន អ្នកណាចង់អង្គុយក៏អង្គុយ អ្នកណាចង់ដេកក៏ដេកអ្នកណាចង់ឈរក៏ឈរតាមអធ្យាស្រ័យ រោងជាទីប្រជុំនោះជា សាធារណទូទៅដល់មហាជនទាំងពួងដូចម្ដេចមិញ ព្រះនិព្វានក៏ឃើញហាក់ថានឹងទូទៅដល់ជនទាំងពួងដូច្នោះដែរ ព្រះអដ្ឋកាចារ្យលោកពិចារណាឃើញថា នឹងមានពាក្យច្រៀតសួរសឹកយ៉ាងនេះ បានជាលោកពោលបាឡីវិសជ្ជនាដោះថា **មគ្គសមង្គិនានាមគ្គព្វតោសាធារណំចា** ពាក្យដែលថាព្រះនិព្វានមិនបានទូទៅដល់ជនទាំងពួងនោះ ព្រោះថាព្រះនិព្វាននោះបុគ្គលអ្នកព្រមព្រៀងដោយព្រះអរិយមគ្គគប្បីដល់ បុគ្គលដែលជាបុថុជ្ជនមិនទាន់ព្រមព្រៀងដោយព្រះអរិយមគ្គអរិយផលនោះ នឹងបានដល់ព្រះនិព្វានក៏ទេ

BUDDHIST INSTITUTE LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

ស្រេចតែថាឃើញចំពោះជាក់ច្បាស់ ព្រះនិព្វាននោះបានតែព្រះអរិយបុគ្គល មានកំណត់ដូច្នេះ បានជាព្រះនិព្វានជាអសាធារណធម៌ មិនបានទូទៅដល់ជន ទាំងពួង ន័យមួយវិញទៀតថា ព្រះនិព្វាននោះរកដើមកំណើតគ្មាន ព្រោះថា ទីបំផុតខាងដើមមិនមាន នឹងមានកំណត់ថាព្រះនិព្វានមានមកតាំងពីព្រះសាសនា ព្រះសម្មុទ្ធណា នឹងកំណត់ដូច្នេះមិនមាន ឯពាក្យបុច្ឆាសៀតសិកចូលមក ទៀតថា ព្រះនិព្វាននោះមានដើមកំណើតដែរ ចុះព្រះអរិយមគ្គនោះមិនមែន ជាដើមកំណើតព្រះនិព្វានទេ វិសជ្ជនាដោះថា ព្រះអរិយមគ្គនោះនឹងបានជា ដើមកំណើតនៃព្រះនិព្វានក៏ទេ ព្រោះថាព្រះនិព្វានជាអារម្មណ៍នៃព្រះអរិយមគ្គ ទេ តើដែលថាអរិយមគ្គជាដើមកំណើតនៃព្រះអរិយនោះមិនគួរទេ ព្រះនិព្វាន នឹងបានកើតដោយអំណាចព្រះអរិយមគ្គក៏ទេ ឯព្រះអរិយមគ្គនោះនឹងបានជា បច្ច័យឱ្យកើតព្រះនិព្វានក៏ទេ ហេតុដូច្នេះបានជាព្រះនិព្វានបានឈ្មោះថា ធម៌ រកដើមកំណើតរកទីកើតមិនបាន ព្រះនិព្វាននោះរកដើមកំណើតគ្មានហើយ បានជារកជរានឹងមរណចាស់ស្លាប់មិនមានក្នុងព្រះនិព្វាននោះ ព្រះនិព្វាននោះ រកទីកើតគ្មាន រកសេចក្ដីចាស់ជរាគ្មាន រកសេចក្ដីមរណគ្មាន ប្រាកដដូច្នោះ ស្ថិតនៅក្នុងនិច្ចធម៌ជាធម៌ទៀងពិត មិនចេះប្រែប្រួលឡើយ ។

ទើបមានពាក្យបុច្ឆាថា ដំណើរដែលថាព្រះនិព្វានទៀងនោះទៀង ដូចជាអ្វីនឹងជាទៀងដូចជាធូលីដ៏ល្អិតជាបរមាណូ នៅក្នុងអាកាសនោះ ៗ នឹងថាទៀងដូចប្រក្រតីនៃលោក ថាទៀងដូចកាលជាអតីតអនាគតបច្ចុប្បន្ន ថាទៀងដូចភេទស្រី ភេទប្រុសជាដើម យ៉ាងដូម្ដេច ក៏ធូលីដ៏ល្អិតដែល ហុយនៅក្នុងអាកាសឃើញច្បាស់ក្នុងរស្មីនៃព្រះអាទិត្យ ដែលធ្លុះចូលតាម ប្រហោងជញ្ជាំងជាដើម ដែលមានបញ្ញត្តិឈ្មោះថាអណូ នោះយើងឃើញថា

www.budinst.gov.kh www.elibraryofcambodia.org

ទៀងព្រោះហុយទៅជានិច្ច ឯប្រក្រតីនៃលោកគឺផែ្ទប្រថពី នឹងមហាសមុទ្រ ភ្នំព្រះសុមេរុរាជបរិភណ្ឌគីរី នឹងភ្នំកណ្ដាប់ចក្រវាឡជាដើម នោះយើងឃើញថាទៀង ព្រោះថាមានកំណត់ធំតូចប៉ុន្មានក៏នៅជាប្រក្រតីប៉ុណ្ណោះតាមប្រវេណីលោកសណ្ឋាន នឹងបានប្រែប្រួលត្រឡប់ក្លាយទៅជាអ្វីក៏ឥតអត្ថិមានឡើយ ឯកាលជាអតីតអនាគតបច្ចុប្បន្នដែលកំណត់ជាថ្ងៃ ជាយប់ ជាខែ ជាឆ្នាំ តាមប្រវេណីលោកវិស័យនោះសោតយើងក៏ឃើញថាទៀង ព្រោះថាមានជាសម្រាប់លោកតាំងតែអំពីដើមមក នឹងបានវិបរិតប្រែប្រួលទៅក៏ឥតអត្ថិមាន ស្ថិតស្ថេរនៅជាធម្មតា ប្រការមួយវិញទៀតភេទស្រី ភេទប្រុសជាដើមនោះសោត យើងក៏ឃើញថាទៀង ព្រោះស្រីនឹងប្រុសនេះមានមកតាំងអំពីដើម នឹងបានអស់បានហើយផុតទៅនោះក៏ទេ មាននៅទៀងជានិច្ចតាមប្រវេណីលោកវិស័យ ក៏ឯអណ្ហូបរមណ្ហូជាដើម ដែលឃើញថាទៀងដោយន័យដូចពោលមក ហើយដូច្នេះបើនឹងយកមកប្រៀបនឹងព្រះនិព្វាន នឹងឃើញថាទៀងដូចព្រះនិព្វានដែរដូចម្ដេច ។

វិសជ្ជនាដោះថា ដំណើរដែលអ្នកថាអណ្ហូបរមាណ្ហូជាដើមទៀង ដូចព្រះនិព្វាននោះ មិនគួរទេ ហេតុអ្វី ហេតុសភាវនៃព្រះនិព្វាននោះមានឧប្បត្តិសាធារណហេតុ អធិប្បាយថា កុសលអកុសលធម៌ឯណានីមួយដែលនឹងជាហេតុជាបច្ច័យឱ្យសម្រេចឧប្បវត្តិកិច្ចឱ្យកើត ព្រះនិព្វាននោះគ្មានសោះឡើយ កុំគប្បីចូលចិត្តថាកុសលអកុសលធម៌នេះឯង ហើយតាក់តែងព្រះនិព្វានធ្វើឱ្យព្រះនិព្វានកើត កុសលនេះគ្រាន់តែជាអ្នកដឹកនាំ គ្រាន់តែជាអ្នកឧបត្ថម្ភគាំពារជួយឱ្យដល់នូវព្រះនិព្វានទេតើ នឹងបានជាបច្ច័យតាក់តែងឱ្យកើតព្រះនិព្វានក៏ទេ ឯព្រះនិព្វាននេះជាធម៌មិនចេះកើត រកធម៌ឯណានីមួយនឹងជាឧប្បត្តិហេតុ

www.budinst.gov.kh www.elibraryofcambodia.org

ឱ្យកើតព្រះនិព្វានឥតអត្ថិមានឡើយ ក៏ចំណែកឯអណ្ហូបរមាណូនឹងឧកាសលោក នឹងកាលថ្ងៃយប់ខែឆ្នាំ នឹងភេទស្រីភេទប្រុសនោះរមែងតែ។មានឧប្បត្តិសាធារណហេតុនៅឡើយ ធម្មជាតិដែលជាបច្ច័យឱ្យសម្រេចឧប្បត្តិកិច្ចបង្កើតអណ្ហូបរមាណូជាដើម នោះមាននៅដូច្នេះ ដែលនឹងយកអណ្ហូបរមាណូជាដើម ដែលមានឧប្បត្តិសាធារណហេតុនោះ មកប្រៀបផ្ទឹមនឹងព្រះនិព្វានដ៏រកហេតុគ្មានថាទៀងដូចព្រះនិព្វានយ៉ាងនេះមិនសមគួរទេ ម្នាលអាចារ្យជាអ្នកចោទ្យ បើថាអ្នកនឹងមានពាក្យច្រៀតស៊កសួរមកទៀតថា អណ្ហូបមាណូជាដើមនោះ យើងឃើញថានៅមានជានិច្ចសម្រាប់លោក មិនចេះដាច់ ចំណែកខាងព្រះនិព្វាននោះ ក៏ឈ្មោះថាមាននៅជានិច្ចមិនដាច់ដូចគ្នា ដែលនឹងមាននៅតែចំពោះទេសកាលដូចពីជគាមភូតគាម បញ្ចេញផ្កាផ្លែតែតាមរដូវនោះក៏ទេ បើបុគ្គលឯណាប្រកបដោយឧបបាយប្រព្រឹត្តសម្មាប្រតិបត្តិតាមពុទ្ធឱវាទ គឺសីលខន្ធ សមាធិខន្ធ បញ្ញាខន្ធ ដ៏ទំភ្លៀវក្លាក្នុងកាលឯណា បុគ្គលនោះក៏នឹងបានជួបបានប្រទះឃើញយល់ដល់ព្រះនិព្វានដោយបច្ចក្ខសិទ្ធិញាណជាក់ច្បាស់ ក្នុងអត្តភាពក្នុងកាលនោះ ដែលនឹងបានព្រះនិព្វានមានកំណត់ទេសកាលដូចរុក្ខជាតិពីជគាមភូតគាមនោះក៏ទេ ឯព្រះនិព្វានដែលមាននៅជានិច្ចយ៉ាងនេះអ្នកយល់ថាទៀងហើយអណ្ហូបរមាណូជាដើម ដែលមាននៅជានិច្ចមិនដាច់នោះ យើងក៏ឃើញថាទៀងដូចព្រះនិព្វាននោះដែរ បើអ្នកនឹងមានពាក្យស៊កមកយ៉ាងនេះក៏មិនគួរដែរ ហេតុអ្វី ហេតុថាមិនមានហេតុលក្ខណ គឺរកកំណត់កត់សំគាល់នៃហេតុគ្មាន ក៏ធម្មតាថានឹងសម្តែងនូវផលនោះគប្បីឱ្យមានលក្ខណដែលកំណត់កត់សំគាល់សិន បើកំណត់បានថាមានមូលហេតុដូច្នេះ។ អណ្ហូបរមាណូជាដើមដែលមាននៅជានិច្ចទើបបានឈ្មោះថាទៀង ព្រោះមូលហេតុដូច្នោះ ។ បើ

www.budinst.gov.kh www.elibraryofcambodia.org

កំណត់បានដូច្នេះហើយក៏សមគួរនឹងជឿស្តាប់យកជាការបាន ដែលមិនកំណត់បាននូវមូលហេតុនឹងចាប់យកតែចុងហេតុមកថា អណ្ណូបរមាណូជាដើមមាននៅជានិច្ច ហើយក៏បានឈ្មោះថាទៀង នឹងថាយកតែចុងហេតុដូច្នេះមិនគួរនឹងជឿស្តាប់យកជាការបាន ឯពាក្យដែលថាព្រះនិព្វានមាននៅជានិច្ចជាធម៌ទៀងនោះមានលក្ខណមាន កំណត់កត់សំគាល់នៃមូលហេតុជាសំគាល់មានពាក្យដែលថាព្រះនិព្វានរក ហេតុមិនមាននោះ ថាដោយមានឧប្បត្តិហេតុផ្សេងទេតើឧប្បត្តិហេតុដែលនឹង ឱ្យបង្កើតព្រះនិព្វាននោះគ្មានមូលហេតុដែលសម្តែងផលឱ្យឃើញថាព្រះនិព្វាន ទៀងនោះមាននៅជាពិត ឯពាក្យដែលថាព្រះនិព្វានទៀងនោះដោយកិច្ចដែល មិនចេះកើតមិនចេះស្លាប់ នឹងបានទៀងដោយធម្មតាទេ ហេតុអ្វីហេតុមានពាក្យដីកាចារ្យវិសជ្ជនាថា លក្ខណដែលនឹងកំណត់កត់សំគាល់នូវហេតុឱ្យឃើញថា ព្រះនិព្វានទៀងនោះ នឹងបានកំណត់ដោយហេតុដែលជាបច្ចក្ខលក្ខណធម្មតាជាដើម នោះមិនបានអធិប្បាយថាហេតុឯណាមាននៅដោយធម្មតា សត្វមាននៅដោយធម្មតា លោកមាននៅទាំងពីរដូចគ្នានឹងមានចំពោះតែប្រុស មានតែស្រីក៏ទេ ហេតុនោះឯងបានជាឈ្មោះបច្ចក្ខលក្ខណធម្មតា ដូចយ៉ាងធូលីដែល ជាអណ្ណូបរមាណូហុយនៅក្នុងអាកាសផ្ទៃប្រថពីទីដីកល់មិនមានកំណត់ធំប៉ុន គ្មានឹងយ៉ាងដូចមុនទឹកក្នុងមហាសមុទ្រមានរស់ជីប្រែមនុស្សមានខ្លួនវែង ដោយកំពស់សត្វតិរច្ឆានមានខ្លួនវែងទៅដោយទទឹង ហេតុយ៉ាងនេះបានជាឈ្មោះថាបច្ចក្ខធម្មតាហេតុ ឯហេតុដែលសម្តែងផលឱ្យឃើញថា ព្រះនិព្វានទៀងនេះនឹងបានជាបច្ចក្ខធម្មតាហេតុយ៉ាងនេះក៏ទេ ព្រះនិព្វានធម៌ទៀងនោះដោយកិច្ចដែលមិនចេះកើត មិនចេះស្លាប់មិនចេះចាស់ជរា ឯអណ្ណូជាដើម នោះមានកិច្ច មិនចេះកើត មិនចេះស្លាប់

www.budinst.gov.kh www.elibraryofcambodia.org

មិនចេះចាស់ជរាៗដូចព្រះនិព្វានដែរ ដូចម្តេចបានជាអ្នកយកអណូជាដើម មកប្រៀបនឹងព្រះនិព្វានថាទៀងដូចព្រះនិព្វាន ឯនឹងសម្តែងផលថាអណូជាដើមទៀងនោះឱ្យសម្តែងមូលហេតុចេញ មកឱ្យច្បាស់សិនឯនឹងថាចាប់យកតែចុងហេតុ ថាអណូមាននៅជានិច្ចបានជាឈ្មោះថាទៀង នឹងថាយ៉ាងនេះមិនគួរទេបើអ្នកនឹងមានពាក្យច្រៀតសិក ចូលមកទៀតថា ដំណើរដែលយើងយល់អធិប្បាយថាអណូបរមាណូជាដើម ទៀងដូចព្រះនិព្វាន ព្រោះថាអណូបរមាណូជាដើមនោះមិនមានឧប្បាទខណ នឹងឋិតិខណ ភង្គខណ ដូព្រះនិព្វានៗរកឧប្បាទខណ ឋិតិខណ ភង្គខណ គ្មាន យ៉ាងណា អណូបរមាណូជាដើមនោះក៏រកឧប្បាទខណ ឋិតិខណ ភង្គខណ គ្មានដូច្នោះដែរ អាស្រ័យហេតុដូច្នោះដែរបានជាយើងសំដែងផលថាអណូជា ដើមនោះទៀងដូចព្រះនិព្វាន ។ បើអ្នកថាដូច្នេះក៏មិនសមគួរដែរ ព្រោះថាអណូជាដើមនោះ មិនបានសម្រេចនូវភាវនោះទៀង តាមពាក្យសំដីដែលអ្នក បដិញ្ញាណ ពាក្យដែលអ្នកបដិញ្ញាណថា អណូជាដើមទៀងនោះនឹងបានសម្រេច ជាធម្មបដិញ្ញាក៏ទេ បើមិនសម្រេចជាធម្មបដិញ្ញាណហើយ ក៏មិនអាចនឹងឱ្យសម្រេចផល គឺភាវទៀងនោះបានប្រការមួយវិញទៀត ឧប្បទខណនឹងឋិតិ ខណ ភង្គខណនោះសោត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាចំពោះតែចិត្តនឹង ចេតសិកប៉ុណ្ណោះ ក្រៅអំពីចិត្តនឹងចេតសិកនឹងបានមានឧប្បទខណ ឋិតិខណ ភង្គខណក៏ទេ ដែលអ្នកនឹងប្រកាន់យកអធិប្បាយថាអណូជាដើមទៀងដូចព្រះនិព្វាន ព្រោះហេតុដែលរកឧប្បទខណគ្មានដូចគ្នានោះ មិនឃើញមានវិសេស អ្វីទេ មួយវិញទៀត អណូជាដើមនោះតែងវិនាសដោយភ្លើងប្រលៃកល្ប ខ្យល់ ប្រលៃ កល្ប ទឹក ប្រលៃលោកដល់នូវភាវជាអនិច្ចលក្ខណនឹងស្ថិតស្ថេរមាំមួន ទៀងនៅក៏ទេក៏ចំណែកឯព្រះនិព្វាន

www.budinst.gov.kh www.elibraryofcambodia.org

នោះមិនចេះវិនាសដោយភ្លើងដោយខ្យល់ ដោយទឹកប្រលែកល្បទេ មាន លក្ខណៈរម្ងាប់ មានកិច្ចមិនបានកើតមិនបានស្លាប់មិនបានចាស់ជរា ហេតុដូច្នេះ ដែលអ្នកនឹងយកអណ្ដូជាដើមដែលជា ធម្មជាតិតែងនឹងវិនាសប្រលែមកប្រៀប ផ្ទឹមនឹងព្រះនិព្វានដ៏ប្រសើរមិនចេះ វិនាសប្រលែមិនសមគួរទេ ធម្មជាតិទាំង ឡាយមានអណ្ដូជាដើមដែលអ្នក ពោលថាមានមកអំពីដើមនោះ នឹងបានជា ធម្មជាតិដ៏ទៀងមែននោះក៏ទេ ព្រះនិព្វាននេះឯងទើបជាធម៌ទៀងពិតឥតមាន ប្រែប្រួលសោះ ពាក្យដែលថាព្រះនិព្វានទៀងនោះ គួរដោយសភាវសមគួរ នឹងពាក្យដែលពោលមកមុនៗមាន បញ្ញត្តាជាដើមដែលពណ៌នាគុណនៃ ព្រះនិព្វានថា ព្រះនិព្វានរកដើមកំណើត គ្មានព្រះនិព្វានមិនចេះចាស់ជរា ព្រះនិព្វានមិនចេះឈឺចាប់មិនចេះស្លាប់សោះ ពាក្យដែលសរសើរព្រះនិព្វានថា ជាធម៌ទៀង **អរូបំ** ព្រះនិព្វាននេះឈ្មោះជា អរូបធម៌ដោយអត្ថថាគន្លងនូវរូប នឹងបានមានរូបសណ្ឋានពណ៌ប្រតិស្ឋានជាទីលំនៅៗ ក្នុងទិសឯណាមួយក៏ឥត អត្ថិមានឡើយ ព្រះនិព្វាននោះឥតរូបពណ៌សណ្ឋានក៏ពិតមែន តែថាមាននៅ ដោយបរមត្ថ ហេតុអ្វីបានជាឃើញថាមាននៅដោយបរមត្ថអធិប្បាយថា ព្រះអរិយបុគ្គលមានសម្មប្បធានវីរិយ ដ៏មិនបានធូរថយបានសម្រេចញាណ ដ៏វិសេសពោលគឺមគ្គញាណផលញាណ ក្នុងកាលឯណា ហើយក៏បានសម្រេច ព្រះនិព្វានដោយបច្ចក្ខសិទ្ធិញាណក្នុងកាលនោះ ព្រះអរិយបុគ្គលទាំងឡាយ ដែលត្រាស់ដឹងជាក់ច្បាស់នូវព្រះនិព្វាននោះ លោកត្រាស់ដឹងជាក់ច្បាស់ ដោយពិតមិនបានត្រាស់ដឹងដោយអំណាចជឿ ស្ដាប់ពាក្យអ្នកដទៃ ក្រៅអំពី ព្រះអរិយបុគ្គលដែលដឹងថាព្រះនិព្វានមាននោះ ដឹងដោយអំណាចជឿស្ដាប់ យកតាមព្រះពុទ្ធភាសិតដែលសម្ដេចព្រះសាស្ដា ចារ្យទ្រង់ត្រាសទេសនាទុកដឹង

www.budinst.gov.kh www.elibraryofcambodia.org

ដោយអនុមានបញ្ញា ដែលនឹងដឹងច្បាស់ឃើញ ច្បាស់ដូចព្រះអរិយបុគ្គលនោះ ក៏ឥតអន្តិមានអាស្រ័យហេតុដែលព្រះអរិយ បុគ្គលនោះក៏ឥតអន្តិមាន អាស្រ័យហេតុដែលព្រះអរិយបុគ្គលដឹងដោយបច្ចក្ខ សិទ្ធិញ្ញាណបុគ្គលក្រៅអំពីព្រះអរិយបុគ្គលដឹងដោយអនុមានសិទ្ធិញ្ញាណ ឃើញដូចពណ៌នាមកដូច្នេះនឹងបានឃើញច្បាស់ថា ព្រះនិព្វាននោះមាននៅ ដោយបរមត្ថដោយប្រការដូច្នេះ ព្រះមហាករុណាសម្មាសម្ពុទ្ធ មានព្រះពុទ្ធភា សិតប្រោសប្រទានធម្មទេសនាថា ម្នាលភិក្ខុទាំងឡាយ ធមិដែលជាអារម្មណ៍ នៃព្រះអរិយមគ្គអរិយផលដែលព្រះតថាគតហៅថាព្រះនិព្វាននោះមាននៅជា ពិតព្រះនិព្វានធមិនោះ **អជាតំ** មិនបានកើតដោយហេតុបច្ច័យ **អភូតំ** មិនបាន កើតដោយខ្លួនឯង **អកតំ** បុគ្គលទាំងឡាយមានព្រះឥស្សរជាដើម មិនអាចធ្វើ បានដោយកំលាំងឫទ្ធិកំលាំងកាយទុកជានឹងមានឫទ្ធានុភាពច្រើនប្រការ ដូចម្តេចៗក៏មិនអាចនឹងតាក់តែងមិនអាចនឹងនិមិត្តនូវព្រះនិព្វាននោះបាន **អសំខតំ** ព្រះនិព្វាននោះនឹងមានកុសលកុសលធមិប្រជុំតាក់តែងដូចយ៉ាងរូបធមិ នាមធមិទាំងពួងនោះក៏ទេ ព្រះនិព្វាននោះព្រះអង្គទ្រង់ទេសនាថាជាឧបនិស្ស័យ ឱ្យរម្ងាប់បង់នូវសំខារធមិទាំងពួងឱ្យលះបង់នូវឧបកិលេសទាំងពួង **គម្ភិរោ** ព្រះនិព្វាននោះជាធមជ៏សុខុមគម្ភិរភាព **ទុទ្ទសោ** កម្របុគ្គលនឹងត្រាស់ដឹង ឃើញឱ្យជាក់ច្បាស់ **ទុរានុពោធោ** ក្រណាស់ដែលនឹងត្រាស់ដឹងឱ្យច្បាស់នូវ ព្រះនិព្វាន **សន្តោបណីតោ** ព្រះនិព្វាន នោះល្អិតក្រៃលែងល្អិតប្រណីតបញ្ចង់ ក្រៃពេក **អតក្កាវចរោ** បុគ្គលនឹងគិតមិនគប្បី ដឹងដោយតំនិតគិតយកដោយខ្លួនឯង **និបុណោ** ព្រះនិព្វាននោះបរិបូណ៌ទៅដោយគុណដ៏លើសលុប**បណ្ឌិត** **វេទនិយោ** បណ្ឌិតមានប្រាជ្ញា គប្បីប្រតិបត្តិតាមព្រះអដ្ឋង្គិកមគ្គទាំង៨ប្រការ នោះឯង

www.budinst.gov.kh www.elibraryofcambodia.org

ទើបបានដឹងទើបបានឃើញ ព្រះអង្គទ្រង់ទេសនាហៅថានិរោធសច្ច ដោយអត្ថថាជាឧបនិស្ស័យឱ្យរលត់ទុក្ខដោយពិតព្រះនិព្វាននេះជាខុសទៀង មិនបានច្រឡំទៅដោយទុក្ខសោករោគភ័យ ឧបទ្រព្វចង្រៃទាំងពួងនោះៗឡើយ សុខដទៃៗ នឹងសុខទៀង ដូចសុខក្នុងព្រះនិព្វាននេះមិនមានសោះ អាស្រ័យហេតុដូច្នោះ ទើបព្រះនិព្វានជាទីត្រេកអរជាទីប្រាថ្នានៃអរិយសប្បុរសទាំងឡាយ មានព្រះពុទ្ធអង្គជាប្រធាន ព្រះអរិយបុគ្គលដែលបានសម្រេចអនុបាទិសេសនិព្វានធាតុ រំលត់កម្មជរូបនឹងវិបាកខន្ធអស់ស្រេចហើយនោះ ប្រាសចាកជាតិជរាព្យាធិមរណៈ សេចក្តីសោកក្សីកក្សួលអាល័យអស់ឥតមានសល់ដល់នូវសេចក្តីសុខក្សេម ដ៏លើសលុបជាងសម្បត្តិសុខទាំងពួងក្នុងមនុស្ស លោកនឹងទេវលោក ហេតុដូច្នេះសុខក្នុងព្រះនិព្វាននោះសម្តេចព្រះមហាករុណាទ្រង់មានព្រះពុទ្ធភាសិតសរសើរថាជាឯកន្តបរមសុខពិតៗជារបស់នៃព្រះអរិយបុគ្គល ដូចន័យបានពណ៌នាមកនេះ ។

និរោធអរិយសច្ចនេះមានអត្ថ៤ ប្រការដូចគ្នាគឺ **និស្សរណដ្ឋោ** មានអត្ថថាបើខ្លួនចេញចាកភពប្រការ១ **អបលិពោធដ្ឋោ** មានអត្ថថារកកង្វល់រវល់មិនមានប្រការ១ **អសង្ខតដ្ឋោ** មានអត្ថថារកបច្ច័យប្រជុំតាក់តែងមិនមានប្រការ ១ **អមតដ្ឋោ** មានអត្ថថាជាអម្រឹត្យធម៌ គឺសេចក្តីដែលមិនចេះស្លាប់ប្រការ១ ត្រូវជា ៤ប្រការ សម្តែងអត្ថជាបឋមគឺនិស្សរណដ្ឋោ នោះជាលក្ខណៈនៃនិរោធសច្ចពិត នឹងឱ្យឃើញសេចក្តីថា បុគ្គលឯណាបានសម្រេចនិព្វានហើយបុគ្គលនោះនឹងលើកខ្លួនចេញឱ្យផុតចាកវដ្តសង្សារ លែងកើតលែងស្លាប់លែងវិលយកណើតកើតក្នុងភពថ្មីតទៅទៀត ចេញឈ្មោះថាបានសម្រេចព្រះនិព្វានហើយ ទៀងតែនឹងលើកខ្លួនចេញឱ្យផុតអំពីវដ្តសង្សារ សម្តេចព្រះសាស្តា

www.budinst.gov.kh www.elibraryofcambodia.org

ចារ្យ ចំពោះនឹងឱ្យឃើញអធិប្បាយដូច្នេះ ទើបសម្តែងអត្ថជាបឋមគឺនិស្សរណ-ត្ថោ ជាលក្ខណៈនៃនិរោធសច្ចដោយប្រការដូច្នេះ ឯអត្ថជាគំរប់២ គឺអបលិពោធ-ត្ថោ នោះមានអធិប្បាយធ្លុះដល់សមុទយសច្ច ដើម្បីនឹងឱ្យឃើញសេចក្តីថាសត្វទាំងពួងដែលនឹងកង្វល់វល់ដោយកិលេសកាមវត្ថុកាមនោះ កើតព្រោះសន្តានទៅប្រកបដោយតណ្ហា បើបានសម្រេចព្រះនិព្វានផ្តាច់តណ្ហាបង់បានដាច់ចេញពីសន្តានអស់ ហើយក៏នឹងអស់ធុរៈកង្វលល់វល់ទាំងពួង នឹងមិនបានវល់កង្វល់ដោយកិលេសកាមវត្ថុកាមតទៅ ព្រះអង្គទ្រង់សំដៅនឹងឱ្យឃើញសេចក្តីរហូតដល់សមុទយសច្ច ដូច្នេះ ហើយសម្តែងអត្ថគឺ អបលិពោធត្ថោជាអត្ថនៃនិរោធសច្ចជាគំរប់ ២ ឯអត្ថជាគំរប់ ៣ គឺអសំខតត្ថោ នោះមានអត្ថាធិប្បាយធ្លុះរហូតដល់មគ្គសច្ច ដើម្បីនឹងឱ្យឃើញសេចក្តីថា ព្រះយោគាវចរអ្នកមានប្រាជ្ញាពិចារណាឃើញថាជាងផ្ទះ គឺតណ្ហានោះជាអ្នកតាក់តែងគ្រឿងផ្ទះ គឺរូបកាយដល់សត្វទាំងពួងឱ្យសត្វដល់ទុក្ខលំបាកក្នុងផ្ទះរបស់ខ្លួន ដែលនឹងគិតរិះរកឧបាយគេចវេះរត់ចេញអំពីផ្ទះ ដែលតណ្ហាតាក់តែងឱ្យនោះគោងអាស្រ័យសេចក្តីប្រតិបត្តិតាមមគ្គសច្ចនោះៗ ទើបនឹងជាឧបាយរលាស់ខ្លួនឱ្យរួចចេញអំពីផ្ទះនៃតណ្ហានោះបាន នាយជាងផ្ទះគឺតណ្ហាក៏មិនអាចរចនាតាក់តែងផ្ទះ គឺរូបកាយនោះបានតទៅទៀត អាស្រ័យនឹងសេចក្តីប្រតិបត្តិតាមមគ្គសច្ច សម្តេចព្រះមុនីសរពេជ្ញ ទ្រង់ចំពោះនឹងឱ្យឃើញសេចក្តីធ្លុះរហូតដល់មគ្គសច្ចដូច្នេះបានជាសម្តែងអត្ថគឺអសំខតត្ថោ ជាអត្ថនៃនិរោធសច្ចជាគំរប់ ៣ ឯអត្ថជាគំរប់ ៤ គឺអមតត្ថោ នោលមានអត្ថាធិប្បាយធ្លុះរហូតដល់ទុក្ខអរិយសច្ច គឺនឹងឱ្យឃើញថានិរោធសច្ចនោះជាទឹកអម្រិត្យសម្រាប់រម្ងាប់រោគ ពោលគឺកងទុក្ខទាំងពួង បុគ្គលដែលកើតរោគ១២ប្រការ មានរោគវិលស្លាប់កើតវិលយកកំណើត

www.budinst.gov.kh www.elibraryofcambodia.org

ជាដើម ជាប្រធានបើបានគ្រេបផឹកនូវទឹកអម្រិត្យ ពោលគឺនិរោធសច្ចហើយថា ជាវិសេស រោគ១២ប្រការ មានរោគគឺជាតិទុក្ខជាដើមនោះ ក៏នឹងរម្ងាប់សាប សូន្យសោះ ទៅដោយពិតកងទុក្ខទាំងពួងនឹងរម្ងាប់សាបសូន្យទៅនោះអាស្រ័យ នឹងព្រះនិព្វាន សម្តេចព្រះសាក្យមុនីគោតមបរមសម្មាសម្ពុទ្ធជាគ្រូ លោកទ្រង់ ផ្ចង់ ពន្យល់សេចក្តីបំភ្លឺដល់ទុក្ខអរិយសច្ចដូច្នេះ បានជាសម្តែងអត្ថគឺ អមត្យត្ថោ ជាអត្ថនិរោធអរិយសច្ចជាគំរប់៤ សិរិបញ្ចូលផងគ្នា ហើយទើបត្រូវជាអត្ថនិរោធ អរិយសច្ច ៤ ប្រការ សម្តែងមកក្នុងនិរោធអរិយសច្ចក៏ចប់តែប៉ុណ្ណោះ ។

ពីនេះនឹងវិសជ្ជនាក្នុងមគ្គអរិយសច្ចតទៅមានបទវារព្រះបាឡីថា **តត្ថកតមំទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចំអយមេវអរិយោ អដ្ឋង្គិ- កោមគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្ម ន្តោ សម្មា អាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ**

ដំណើរសេចក្តីអង្គសម្តេចព្រះមហាករុណាអនន្តញ្ញាណ កាលប្រោស ប្រទានព្រះធមទេសនាក្នុងទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ទ្រង់ត្រាស់ទេស នា ជាកថេតុកម្យតាបុច្ឆាថា **តត្ថកតមំទុក្ខនិរោធគាមិនីប ដិបទាអរិយសច្ចំ** ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រតិបត្តិដើម្បីនឹងឱ្យដល់នូវកិរិយារំលត់ទុក្ខឱ្យសម្រេច ព្រះនិព្វានសុខនោះ ជាសេចក្តីពិតជាសេចក្តីមែនរបស់ព្រះអរិយបុគ្គលនោះតើ ដូចម្តេច ទើបទ្រង់វិសជ្ជនាដោយព្រះអង្គឯងថា **អយមេវអរិយោអដ្ឋង្គិកោ មគ្គោ** ផ្លូវប្រតិបត្តិគឺអដ្ឋង្គិកមគ្គប្រកបដោយអង្គ៨ប្រការនេះ អាចនឹងរំលត់ទុក្ខ បានឱ្យសម្រេចដល់ព្រះនិព្វាន ជាសេចក្តីពិតរបស់ព្រះអរិយបុគ្គលដោយពិត ឥតមានឃ្លាតព្រះអរិយបុគ្គលទាំងឡាយមានព្រះពុទ្ធជាប្រធាននេះ លោកសឹង

www.budinst.gov.kh www.elibraryofcambodia.org

ប្រតិបត្តិដំណើរតាមផ្លូវ គឺព្រះអដ្ឋង្គិកមគ្គនេះគ្រប់ព្រះអង្គ ព្រោះថាអដ្ឋង្គិកមគ្គនេះជាទីផុតបំផ្លាញរំលាងបង់នូវរាគាទិកិលេស ហើយឱ្យសម្រេចនូវមគ្គញាណផលញាណនឹងព្រះនិព្វានជាបរិយោសានទីបំផុត ។ ប្រការមួយវិញទៀត ព្រះអដ្ឋង្គិកមគ្គនេះឆ្ងាយអំពីសត្រូវគឺកិលេស ដូចជាស្ដេចចក្រពត្រាធិរាជដ៏ឆ្ងាយចាកអរិន្ទរាជបច្ចាមិត្តទាំងពួង ពុំនោះសោត ព្រះអដ្ឋង្គិកមគ្គនេះជាទីហូរមកជាទីប្រជុំនៃពោធិបក្ខិយធម៌ ៣៧ប្រការ ដូចមហាសមុទ្រជាទីហូរមក ជាទីប្រជុំនៃស្ទឹងតូចធំទាំងពួង ថាដូចដួងកែវមណីកំពូលពេជយន្តប្រាសាទ អង្គអមរិន្ទទេវរាជនាពិភពត្រៃត្រឹង្សព្រះអដ្ឋង្គិកមគ្គនេះ តែងឱ្យសម្រេចសេចក្ដីប្រាថ្នាដល់ទេវតានឹងមនុស្សដែលជាពុទ្ធវេនេយ្យសត្វ ដូចជាដួងកែវមណីជោតិ៨ ជ្រុងដ៏ធំអាចឱ្យសម្រេចសេចក្ដីប្រាថ្នាដល់សម្ដេចមហាចក្រពត្តិរាជ ព្រះអដ្ឋង្គិកមគ្គទាំង ៨ប្រការនេះ បើបុគ្គលឯណាប្រតិបត្តិតាមហើយ បុគ្គលនោះនឹងបានរុងរឿងជាងទេវតានឹងមនុស្ស ដូចព្រះបាទកុសរាជដ៏មានរូបអាក្រក់ក្រៃលែង កាលបើបានកែវមកអំពីសម្ដេចអមរិន្ទ្រាធិរាជ ក៏ត្រឡប់ជាមានរូបឆោមល្អឆើតឆាយសោភាឡើងដោយអនុភាពនៃកែវនោះ មួយវិញទៀត វេជយន្តរថអង្គអមរិន្ទកោសីយនោះ ជារថដ៏ប្រសើរកើតដោយអំណាចផលនៃកុសល ដែលបានសាងសន្សំបន្ថែមមកអំពីបុព្វជាតិ ឯពេជយន្តរថនោះដ៏ទឹមដោយសេះសិន្ធពមួយពាន់មានព្រះមាតលើទេវបុត្រជានាយទេព្វសារថី សម្ដេចព្រះសហស្សន័យអង្គទេវរាជនោះ តែងតាំងបរចេញទៅផ្ចាញ់ពួកអសុរនិកាយឱ្យបរាជ័យចាលចាញ់តេជានុភាពនេះបានដូចម្ដេចមិញ ព្រះអដ្ឋង្គិកមគ្គនេះជារថដ៏ប្រសើរ ប្រដាប់ដោយពោធិបក្ខិយធម៌ ៣៧ប្រការ ជាយសបរិវារព្រះអរិយសប្បុរសទាំងពួងដែលជិះបរ គឺប្រតិបត្តិតាម ក៏តែងដឹកនាំព្រះអរិយសប្បុរសទាំងនោះ ឱ្យទៅ

www.budinst.gov.kh www.elibraryofcambodia.org

ផ្ចាញ់នូវពពួកមារ គឺតណ្ហានឹងរាគាទិកិលេសជាដើមឱ្យបរាជ័យចាលចាញ់ វិនាសក្នុងកាលនោះហើយឱ្យឡើងកាន់ប្រាសាទ គឺអមតមហានគរគឺព្រះនិព្វាន ដ៏ជាទីក្សេមក្សាន្ត ប្រាសចាកជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ជាឯកន្ត បរមសុខដោយពិតៗមែន ដូចជាពេជយន្តរថនោះមែន បើបុគ្គលមានប្រាថ្នា នឹងទៅកាន់នគរកែវ ពោលគឺព្រះនិព្វាននោះ១០០នាក់ក្តី ១០០០នាក់ក្តី ១០.០០០នាក់ក្តី ១០០.០០០នាក់ក្តី រថពោលគឺព្រះអដ្ឋង្គិកមគ្គទាំង៨ ប្រការនេះ ក៏អាចធានានឹងបើជញ្ជូនបុគ្គលទាំងអម្បាលនោះទៅដាក់ឱ្យដល់នគរនិព្វាន មិនមានឱ្យសេសសល់ដល់ម្នាក់ឡើយ ព្រះអដ្ឋង្គិកមគ្គនេះមានគុណូបការដ៏ប្រសើរលើសលប់ឥតអ្វីនឹងផ្ទឹមបាន បណ្តាសាធុជនដែលមានកុសលសម្ភារបាន កសាងសន្សំមកជាច្រើន ហើយបានត្រាស់ដឹងព្រះចតុរារិសច្ចទាំង៤ រថពោល គឺព្រះអដ្ឋង្គិកមគ្គនេះ ក៏អាចនឹងដឹកនាំជញ្ជូនសាធុជនទាំងនេះទៅ ឱ្យដល់នគរនិព្វានមួយរំពេច តែមួយខណចិត្តក៏ដល់ដូចជាលើកឡើងឱ្យផុតអំពីប្រថពី ហើយដាក់ឱ្យដល់កំពូលភ្នំសុមេរុរាជ ហើយដឹកលទុកលើកំពូលសុមេរុរាជ ពុំនោះសោត ព្រះអដ្ឋង្គិកមគ្គនេះមានឧបមាដូចសំពៅដ៏ធំបើកលឿនទៅក្នុង មហាសមុទ្រសាគរ ហើយញាំងពួកពាណិជទាំងឡាយឱ្យដល់នូវទីកំពង់ចត ឈ្មោះថាកុសាវតី ពួកពាណិជទាំងឡាយក៏បាននូវសេចក្តីក្សេមក្សាន្ត ប្រាស ចាកភ័យអន្តរាយនោះដូចម្តេច សាធុជនទាំងឡាយកាលបើបានដល់នគរ និព្វាន ហើយក៏ប្រាសចាកកងទុក្ខទាំងពួងមានឧបមេយ្យដូច្នោះឯង ។

សម្តេចព្រះសរពេជ្ញសព្វញ្ញូទ្រង់ត្រាស់បុច្ឆាព្រះអង្គឯងថា **សេយ្យថីទំ** ព្រះអដ្ឋង្គិកមគ្គទាំង៨ប្រការនោះ គឺអ្វីខ្លះទើបទ្រង់វិសជ្ជនាថា ព្រះអដ្ឋង្គិកមគ្គ ៨ ប្រការនោះគឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បោ ១ សម្មាវាចា ១ សម្មាកម្ម

ន្តោ ១ សម្មាអាជីវោ ១ សម្មាវាយាមោ ១ សម្មាសតិ ១ សម្មាសមាធិ ១ ត្រូវ ជា ៨ ប្រការដោយឧទ្ទេសវារ ។

ក្នុងនិទ្ទេសវារនោះទ្រង់សម្តែងថា

**កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ**

**ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ**

**អយំ វុច្ចតិ សម្មាទិដ្ឋិ**

អង្គនៃព្រះអរិយមគ្គឈ្មោះថាសម្មាទិដ្ឋិនោះដូចម្តេច ទ្រង់វិសជ្ជនាថា សម្មាទិដ្ឋិនោះបានខាងបញ្ញាចេតសិកដ៏ក្លាហាន តោងយកព្រះនិព្វានមកជា អារម្មណ៍ ហើយដឹងច្បាស់ក្នុងទុក្ខសច្ច ដឹងច្បាស់ក្នុងទុក្ខសមុទយសច្ចដឹង ច្បាស់ក្នុងទុក្ខនិរោធសច្ច ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទាសច្ច មគ្គ សច្ច ហើយប្រតិបត្តិដករំលើងបង់នូវអវិជ្ជានឹងតណ្ហានេះ ឈ្មោះថា មគ្គសច្ច ហើយប្រតិបត្តិដករំលើងបង់នូវអវិជ្ជានឹងតណ្ហានោះ ឈ្មោះថាសម្មាទិដ្ឋិ ជា អង្គនៃព្រះអរិយមគ្គជាបឋម ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ២ ឈ្មោះថាសម្មាសង្កប្បោនោះតើ ដូចម្តេចថាសម្មាសង្កប្បោនោះបានខាងវិតក្កចេតសិក ដែលជាសភាវ សម្រាប់ដំរិះត្រិះរិះទៅក្នុងការដែលនឹងបំពេញទានរក្សាសីល ចំរើនភាវនាក្នុង អសុភកម្មដ្ឋានក្តី ដំរិះទៅក្នុងការដ៏មិនបានចងព្យាបាទអាឃាដចងពៀរនឹងគ្នា ក្តី ដំរិះទៅក្នុងកិច្ចដែលនឹងចំរើនចតុព្រហ្មវិហារ មានមេត្តាជាដើមនោះក្តី ដំរិះ ទៅក្នុងការដែលមិនបានបៀតបៀននូវសត្វទាំងពួងនោះក្តី ព្រះតថាគតពោល ថាសម្មាសង្កប្បោ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ២ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៣ គឺសម្មាវាចានោះតើដូចម្តេច ព្រះ-

www.budinst.gov.kh www.elibraryofcambodia.org

អរិយមគ្គតំរប់ ៣ នោះ បានខាងឯវចីសុចរិត ៤ ប្រការ មុសាវាទាវេរមណី វៀរចាកមុសាវាទកុហកបញ្ឆោតលលួងឱ្យខូចប្រយោជន៍អ្នកដទៃ១ បេសុញ្ញវាចាវេរមណី វៀរចាកពាក្យស៊កសៀតញុះញង់បំបែកអ្នកដទៃឱ្យគេបានសេចក្តីក្តៅក្រហាយ១ ផរុសវាចាវេរមណី វៀរចាកពាក្យអាក្រក់ ចាក់ដោតត្រចៀកអ្នកដទៃ មាកជេរប្រទេចត្មះតិះដៀលជាដើម១ សម្ផប្បលាវាចាវេមណី វៀរចាកតិរច្ឆានកថាពោលក្រមាច់ចំប្លែងលេងពាក្យឥតប្រយោជន៍ ១ វចីសុចរិត ៤ ប្រការនេះ ព្រះតថាគតពោលថាសម្មាវាចាជាអង្គនៃព្រះអរិយមគ្គជាតំរប់៣ ។

អង្គនៃអរិយមគ្គជាតំរប់៤ គឺសម្មាកម្មន្តោ នោះតើដូចម្តេច សម្មាកម្មន្តោនោះ បានខាងឯកាយសុចរិត៣ប្រការ គឺបាណាតិបាតាវេរមណីវៀរចាកសម្លាប់សត្វដែលមានជីវិតរស់នៅ ឱ្យធ្លាក់បង់ចាកជីវិត១អទិន្នាទានាវេរមណីវៀរចាកលបលាក់លួចយកទ្រព្យអ្នកដទៃ ដែលគេមិនបានអនុញ្ញាតឱ្យដោយកាយវាចាដោយថេយ្យចិត្ត១ កាមេសុមិច្ឆាចារាវេរមណីវៀរចាកប្រព្រឹត្តការកន្លងប្រវេណី ដោយភរិយាអ្នកដទៃនឹងស្រីដែលមិនមែនជាភរិយាអាត្មា១ កាយសុចរិតទាំង៣ប្រការនេះ ព្រះតថាគតពោលថា សម្មាកម្មន្តោ ជាអង្គនៃព្រះអរិយមគ្គជាតំរប់ ៤ ។

អង្គនៃព្រះអរិយមគ្គជាតំរប់ ៥ គឺសម្មាអាជីវោនោះតើដូចម្តេច ទ្រង់វិសជ្ជនាថា ព្រះអរិយសាវកក្នុងព្រះពុទ្ធសាសនានេះ ប្រតិបត្តិលះបង់នូវមិច្ឆាអាជីវ គឺចិញ្ចឹមជីវិតមិនប្រកបដោយធម៌ ប្រកបតែដោយអនេសនមានជង្ឃបេសននឹងវេជ្ជកម្មជាដើម ហើយដំកល់នៅក្នុងសម្មាអាជីវ ចិញ្ចឹមជីវិតប្រកបដោយធម៌ជាទីសរសើរនៃព្រះអរិយបុគ្គលទាំងឡាយ ព្រះតថាគតពោលថា សម្មាអាជីវោ ជាអង្គនៃព្រះអរិយមគ្គជាតំរប់ ៥ ។

www.budinst.gov.kh www.elibraryofcambodia.org

អង្គនៃព្រះអរិយមគ្គជាគំរប់ ៦ គឺសម្មាវាយាមោ នោះតើដូចម្ដេច ទ្រង់វិសជ្ជនាថា អង្គនៃព្រះអរិយមគ្គជាគំរប់ ៦ បានខាងឯសមប្បធាន៤ប្រការ គឺព្រះអរិយសាវកក្នុងព្រះពុទ្ធសាសនា ប្រកបព្យាយាមដើម្បីលះបង់នូវអំពើអកុសលដែលកើតឡើង ហើយឱ្យដាច់ចេញស្រឡះអំពីសន្ដានប្រការ១ គឺព្យាយាមដើម្បីកំចាត់បង់នូវអំពើអកុសល ដែលមិនទាន់បង្កើតឡើងមិនឱ្យកើតឡើងបាន ខំប្រឹងព្យាយាមកំចាត់បង់ឱ្យអស់អំពីសន្ដានប្រការ១ គឺព្យាយាមញ៉ាំងកុសលធម៌បណ្ដាដែលមិនទាន់កើតឡើង ឱ្យកើតឡើងក្នុងសន្ដានឱ្យទាល់តែបានប្រការ១ គឺព្យាយាមរក្សាគងការកុសលធម៌ បណ្ដាដែលកើតមាននៅក្នុងសន្ដាន ហើយមានឱ្យត្រឡប់វិនាសទៅឱ្យរិតតែចំរើនឡើង ឱ្យជាថាវវលនាការឡើងក្នុងសន្ដានឱ្យទាល់តែបានប្រការ១ ព្យាយាមទាំង៤ ប្រការនេះ ព្រះតថាគតពោលថា សម្មាវាយាមោ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៦ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៧ គឺសម្មាសតិនោះតើដូចម្ដេច ទ្រង់វិសជ្ជនាថា អង្គព្រះអរិយមគ្គជាគំរប់៧ គឺសម្មាសតិនោះបានខាងឯសតិបដ្ឋាន៤ប្រការ គឺកាយានុបស្សនាសតិបដ្ឋាន ១ វេទនានុបស្សនាសតិបដ្ឋាន ១ ចិត្តានុបស្សនាសតិបដ្ឋាន១ ធម្មានុបស្សនាសតិបដ្ឋាន១ ត្រូវជា ៤ ប្រការ អធិប្បាយថាសតិដឹកលំនៅក្នុងរូបក្ខន្ធ យករូបជាអារម្មណ៍ ពិចារណាជា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា កាយានុបស្សនាសតិបដ្ឋាន សតិដឹកលំនៅក្នុងវេទនាក្ខន្ធ យកវេទនាជាអារម្មណ៍ ពិចារណាវេទនាជា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា វេទនានុប្បស្សនាសតិបដ្ឋាន សតិដែលដឹកលំនៅក្នុងវិញ្ញាណក្ខន្ធ យកវិញ្ញាណជាអារម្មណ៍ ពិចារណាវិញ្ញាណជា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា ចិត្តានុបស្សសតិបដ្ឋាន សតិដែលដឹកលំនៅក្នុង

www.budinst.gov.kh www.elibraryofcambodia.org

សញ្ញាក្ខន្ធ នឹងសំខារក្ខន្ធយកសញ្ញានឹងសំខារជាអារម្មណ៍ ពិចារណាសញ្ញានឹងសំខារជា អនិច្ចំ ទុក្ខំ អនត្តា នោះហើយបានឈ្មោះថា ធម្មានុស្សនាសតិបដ្ឋាន រូបក្ខន្ធនោះជាទីដឹកល់នៃកាយានុបស្សនាសតិបដ្ឋាន វិញ្ញាណក្ខន្ធជាទីដឹកល់នៃចិត្តានុបស្សនាសតិបដ្ឋាន សញ្ញាក្ខន្ធនឹងសំខារក្ខន្ធនោះជាទីដឹកល់នៃ ធម្មានុបស្សនាសតិបដ្ឋាន ដូចប្រទេសទីជ័យភូមិដីជាទីដឹកល់នៃសេនាដរី សេនាសេះសេនារថសេនា ថ្មើរជើងទាំងពួង អធិប្បាយថាព្រះបរមក្សត្រិយ៍ទ្រង់ប្រាថ្នានឹងធ្វើការសង្គ្រាមដោយអមរិន្ទ្ររាជនោះ កាលបើបានប្រទេសជ័យភូមិល្អ តាំងចតុរង្គសេនាទាំង៤ ទុកក្នុងទីជ័យភូមិហើយក៏អាចនឹងរុករានញាំញីនូវពពួកអមរិន្ទ្ររាជ ឱ្យចាលចាញ់ តេជះឥទ្ធានុភាពអប្បរាជ័យ **សេយ្យថាបិ** នេះមានឧបមាដូចម្ដេច ព្រះមហាក្សត្រិយ៍ពោលគឺព្រះយោគាវចរកុលបុត្រ ប្រាថ្នានឹងតតាំងច្បាំងនឹងកិលេស នោះក៏គប្បីតាំងសេនាពលខន្ធទាំង៤ គឺកាយានុបស្សនាសតិបដ្ឋាន វេទនានុបស្សសតិបដ្ឋាន ចិត្តានុបស្សនាសតិបដ្ឋាន ធម្មានុបស្សនាសតិបដ្ឋានចុះក្នុងទីជ័យភូមិពោល គឺរូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាក្ខន្ធ សំខារក្ខន្ធ វិញ្ញាណក្ខន្ធ តតាំង ច្បាំងផ្ចាញ់កិលេសមារបំបាត់បង់នូវសត្រូវពោល គឺកិលេសមារឱ្យអប្បរាជ័យ ចាលចាញ់វិនាសបាក់បបខ្លបខ្លាចស្ថិតនៅមិនបានមានឧបមេយ្យដូច្នោះឯង បណ្ឌិតគប្បីសន្និដ្ឋានចុះថាសតិតែមួយប៉ុណ្ណោះ ចែកចេញទៅជាសតិបដ្ឋាន៤ប្រការ ដោយអំណាចកាន់យកនូវអារម្មណ៍ផ្សេងៗ គ្នាជាផ្លូវដំណើរនៃព្រះអរិយបុគ្គល ហេតុដូច្នេះសម្ដេចព្រះមហាករុណាទ្រង់ត្រាស់ទេសនាថា កិរិយាដែលព្រះយោគាវចរកុលបុត្រដឹកល់សតិជា៤ស្ថាននេះហៅថា សម្មាសតិ ។

**តត្ថកតមោសម្មាសមាធិ** ព្រះអរិយមគ្គឈ្មោះថា សម្មាសមាធិនោះ

www.budinst.gov.kh www.elibraryofcambodia.org

បឋមជ្ឈានជាដើមជាប្រធាន ចិត្តដែលដឹកលំមាំនៅក្នុងឈានទាំង៤នោះ ឈ្មោះថា អប្បនាសមាធិ អ្នកប្រាជ្ញគប្បីសន្និដ្ឋានចុះថា សមាធិនេះមានលក្ខណៈធ្វើឱ្យចិត្តតាំងនៅមាំមួនក្នុងអារម្មណ៍តែមួយ មិនឱ្យចិត្តនោះរាយមាយរសាប់រសល់វិលវល់ទៅក្នុងអារម្មណ៍ដទៃ ដ៏ជាពាហិរហេតុ សមាធិនេះជាប្រធាននៃការកុសលទាំងពួងៗ នឹងសម្រេចក៏អាស្រ័យនឹងសមាធិចិត្តនេះឯងជាទីប្រជុំនូវកុសលទាំងពួង ដូចជាកំពូលក្ដូជាតារប្រាសាទជាទីប្រជុំនៃគ្រឿងទព្វសម្ភារទាំងពួង គ្រឿងទព្វសម្ភារទាំងនោះប្រជុំក្នុងកំពូលប្រាសាទនោះមានឧបមាដូចម្ដេច គងការកុសលទាំងពួងក៏ប្រជុំចុះក្នុងសមាធិមានឧបមេយ្យដូច្នោះឯងគប្បីចូលចិត្តថា គងការកុសលទាំងអស់ដែលនឹងមានផលច្រើននោះ ក៏អាស្រ័យនឹងសមាធិចិត្ត មួយវិញទៀត ភិក្ខុក្នុងព្រះបវរពុទ្ធសាសនានេះនឹងសម្រេចបឋមជ្ឈាន ទុតិយជ្ឈានតតិយជ្ឈាន ចតុត្ថជ្ឈាន បញ្ចមជ្ឈានក៏តែងតែសម្រេចដោយសមាធិចិត្ត ជាមួយវិញទៀត ព្រះអរិយបុគ្គលទាំងឡាយនឹងសម្រេចមគ្គញាណផលញាណព្រះនិព្វាន ក៏អាស្រ័យនឹងសមាធិចិត្តៗនេះជាទីសរសើរនៃព្រះអរិយបុគ្គលទាំងឡាយ ទាំងពួង ហេតុដូច្នោះព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងថាសម្មាសមាធិនេះ ជាអង្គនៃព្រះអរិយមគ្គជាគំរប់៨ ដូច្នេះ បណ្ឌិតគប្បីពិចារណាមើលចុះថា ព្រះអដ្ឋង្គិកមគ្គទាំង៨ប្រការនេះ តែងកើតក្នុងភូមិទាំង ៤ គឺកាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិ លោកុត្តរភូមិ កាលបើកើតក្នុងលោកុត្តរភូមិ ក៏បានឈ្មោះថាលោកុត្តរមគ្គ ដូចបានពណ៌នាមកហើយ កាលបើកើតក្នុងកាមាវចរភូមិ ក៏បានឈ្មោះថាលោកិយមគ្គ ឯមគ្គជាលោកិយមានក្នុងកាមាវចរនោះ ព្រះយោគាវចរសប្បុរសអ្នកមានសទ្ធា ធ្វើការកុសលប្រតិបត្តិបំពេញទានរក្សាសីលចំរើនមេត្តាភាវនាស្ដាប់ព្រះធម៌ទេសនា ជាប្រធាន

www.budinst.gov.kh www.elibraryofcambodia.org

តើដូម្តេច ទ្រង់វិសជ្ជនាថា ភិក្ខុក្នុងព្រះពុទ្ធសាសនានេះញាំងចិត្តអោយស្ងាត់ចាកកិលេសកាមនឹងវត្ថុកាម ហើយចូលបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ដោយសមាធិចិត្តមានក្នុងឈានទាំង៤នោះអធិប្បាយជា២យ៉ាងជាចតុកន័យម្យ៉ាង ជាបញ្ចកន័យម្យ៉ាង ក្នុងចតុកន័យនោះនិយាយដោយឈាន ៤ គឺបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ក្នុងបឋមជ្ឈាន មានអង្គ ៥ គឺវិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ក្នុងទុតិយជ្ឈានមាន អង្គ៣ គឺ បីតិ ១ សុខ ១ ឯកគ្គតា ១ ក្នុងតតិយជ្ឈានមានអង្គ ២ គឺ សុខ ១ ឯកគ្គតា ១ ក្នុងចតុត្ថជ្ឈានមានអង្គ ២ គឺ ឯកគ្គតា ១ ឧបេក្ខា ១ នេះចាត់ ដោយចតុកន័យ បើនឹងចាត់ដោយបញ្ចកន័យវិញ ក្នុងបឋមជ្ឈាន មានអង្គ៥ ដូចគ្នា ទុតិយជ្ឈាន មានអង្គ ៤ គឺ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ក្នុងតតិយជ្ឈានមានអង្គ ៣ គឺ បីតិ ១ សុខ ១ ឯកគ្គតា ១ ក្នុង ចតុត្ថជ្ឈាន មានអង្គ ២ គឺ សុខ ១ ឯកគ្គតា ១ ក្នុងបញ្ចមជ្ឈានមានអង្គ ២ គឺឯកគ្គតា ១ ឧបេក្ខា ១ ពោលមកទាំងនេះ ដើម្បីនឹងអោយឃើញថា ឯកគ្គតាគឺ សមាធិចិត្ត នោះមាននៅគ្រប់ឈាន ឯសមាធិចិត្តនោះ បើចែកដោយពិស្តារ មាន ៣ ប្រការ គឺខណិកសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ឯខណិក សមាធិនោះបានខាងឯចិត្តយើងរាល់គ្នាដឹកល់មិនបានយូរប៉ុន្មាន បានតែខណចិត្ត ១ គឺមួយសំកាំងគ្រចៀកដីរប៉ុណ្ណោះ ក៏ឈ្មោះថាខណិក សមាធិ ។

ឯឧបចារសមាធិនោះ បានខាងឯចិត្តដឹកល់មាំចះក្នុងខណជិតនឹងបានបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុជ្ឈាន បញ្ចមជ្ឈាន នេះឈ្មោះ ថា ឧបចារសមាធិ ។

ឯអប្បនាសមាធិនោះ បានខាងឯចិត្តដែលបានឈានហើយ មាន

www.budinst.gov.kh www.elibraryofcambodia.org

អធិប្បាយថាព្រះយោគាវចរបំពេញក្នុងកាលឯណា ក៏ឈ្មោះថាប្រតិបត្តិតាម អដ្ឋង្គិកមគ្គក្នុងកាលនោះ បើបានរក្សាសីលក្នុងកាលឯណា ក៏បានឈ្មោះថា ប្រតិបត្តិតាមព្រះអដ្ឋង្គិកមគ្គក្នុងកាលនោះ បើបានចំរើនភាវនាស្តាប់ព្រះធម៌ ទេសនាក្នុងកាលឯណា ក៏បានឈ្មោះថាប្រតិបត្តិតាម ព្រះអដ្ឋង្គិកមគ្គក្នុងកាល នោះ ព្រោះហេតុថាព្រះអដ្ឋង្គិកមគ្គ៨ប្រការនេះ កើតព្រមដោយទានសីលភាវ នាការកុសលទាំងពួងនោះសព្វៗគ្រាបណ្ឌិត គប្បីពិចារណាមើលផលានិសង្ស សីលទានជាដើម ថាកងការកុសលទាំងនេះអាចឱ្យសម្រេចត្រៃពិធសម្បត្តិ៣ ប្រការ កាលបើបញ្ញាចាក់ធ្លុះដឹងយល់ឃើញ ដូច្នោះក៏ចាត់ឈ្មោះថាសម្មាទិដ្ឋិ កើតឡើងក្នុងសន្តាន វិតក្កចេតសិកដែលត្រិះរិះក្នុងកងកុសលមានទានសីលជា ដើមនោះ ក៏ចាត់ឈ្មោះថា សម្មាសង្កប្បោ កើតឡើងក្នុងសន្តានវិរតិត្រ័យចេត សិកដែលវៀរចាកវចីទុច្ចរិតវៀរចាកកាយទុច្ចរិត វៀរចាកមិច្ឆាជីវចិញ្ចឹមជីវិត ខុសធម៌ ក្នុងខណដែលបំពេញទានរក្សាសីលចំរើនភាវនានោះក៏ចាត់ឈ្មោះថា សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោកើតឡើងក្នុងសន្តាន វីរិយចេតសិកព្យា-យាមក្នុងកងការកុសលមានទានសីលជាដើមក៏ចាត់ឈ្មោះថា សម្មាវាយាមោ កើតឡើងក្នុងសន្តាន សតិចេតសិកដែលរពកក្នុងកងការកុសលជានិច្ចនោះ ក៏ ចាត់ឈ្មោះថា សម្មាសតិកើតឡើងក្នុងសន្តាន ឯកគ្គតាចេតសិកដែលញាំង ចិត្តឱ្យដំកល់នឹងមាំមួនមិនបានចុលាចលក្នុងកងការកុសល មានទានសីលជា ដើម ក៏ចាត់ឈ្មោះថា សម្មាសមាធិកើតឡើងក្នុងសន្តាន សំដែងមកទាំងនេះ ដោយអំណាចព្រះអដ្ឋង្គិកមគ្គ កើតក្នុងកាមវចរជាលោកិយមគ្គប្រការ១ ព្រះយោគាវចរចំរើនសមថកម្មដ្ឋានភាវនា លុះបានសម្រេចបឋមជ្ឈានហើយ ចេតសិកទាំង៥ គឺបញ្ញា១វីរិយ ១ សតិ ១ វិតក្ក ១ ឯកគ្គតា ១ ចេតសិកទាំង៥

www.budinst.gov.kh www.elibraryofcambodia.org

នេះកើតដោយបឋមជ្ឈានចិត្តនោះ បានឈ្មោះថាមគ្គប្រកបដោយអង្គ៥ប្រការ ព្រោះថាចេតសិកទាំង៣នេះ គឺសម្មាវាចា សម្មាកម្មន្តា សម្មាអាជីវោទាំង៣ នេះមិនបានកើតដោយរូបាវចរចិត្តទេ ព្រោះកាលចូលឈាននោះរកកាយកម្ម វចីកម្មគ្មាន មានតែមនោទ្វារចិត្តតែ ១បញ្ញាដែលពិចារណានូវឈាននោះឈ្មោះ ថាសម្មាទិដ្ឋិ វិតក្កដែលលើកចិត្តឡើងកាន់អារម្មណ៍នោះឈ្មោះថាសម្មាសង្ក ប្បោ វីរិយចេតសិកដែលជាអ្នកជួយឧបត្ថម្ភឈានចិត្តនោះឈ្មោះថា សម្មាវាយា មោ សតិចេតសិកដែលដំរង់ឈានចិត្តអោយដឹកល់នឹងនៅមិនអោយភ្លេចនោះ ឈ្មោះថា សម្មាសតិ ឯកគ្គតាចេតសិក ដែលញាំងឈានចិត្តអោយដំកល់មាំ មិនបានអោយរំភើបនោះឈ្មោះថា សម្មាសមាធិ ចេតសិកទាំង ៥ នេះបាន ឈ្មោះថាអរិយមគ្គទាំង ៥ កើតដោយរូបាវចរចិត្ត បណ្ឌិតគប្បីដឹងដោយប្រការ ដូច្នេះ មួយវិញទៀតកាលបើព្រះយោគាវចរតាំងចិត្តចំរើនសមថភាវនាបានអរូ បាវចរឈាន ៤ ប្រការ គឺអាកាសានញ្ចាយតនឈាន វិញ្ញាណញ្ចាយតនឈាន អាកិញ្ចញ្ញាយតនឈាននឹងនេវសញ្ញានាសញ្ញាយតនឈាននោះ ចេតសិក ៤ គឺ បញ្ញា១ វីរិយ១ សតិ១ ឯកគ្គតា ១ ចេតសិកនេះកើតដោយអរូបាវចរឈានចិត្ត ទាំង៤នោះ បញ្ញាក៏ពិចារណាដឹងច្បាស់អង្គឈាននោះ ឈ្មោះថាសម្មាទិដ្ឋិវីរិយ ជួយតាំពាំទំនុកបំរុងឈានចិត្តនោះឈ្មោះថា សម្មាវាយាមោសតិដំដំរង់ឈាន ចិត្តនោះឈ្មោះថាសម្មាសតិឯគគ្គតាមចេកសិកញាំងឈាន ចិត្តឱ្យដំកល់មាំ នៅមិនបានរំភើបញាប់ញ័រនោះឈ្មោះថាសម្មាសមាធិត្រូវ ជាព្រះអដ្ឋង្គិកមគ្គ ៨ ដូច្នេះ ព្រោះថាអរូបាវចរឈាននោះ ជាបញ្ចមឈានរកវិតក្កគ្មាន អង្គមគ្គទាំង៤ កើតដោយអរូបាវចរចិត្ត បណ្ឌិតគប្បីដឹងដោយប្រការដូច្នេះចុះ ព្រះអដ្ឋង្គិកមគ្គ ទាំង៨នេះ កាលបើកើតក៏កើតព្រមគ្នាទាំង៨ ដូចព្រះអញ្ញាតកោណ្ឌញ្ញត្ថេរ បាន

www.budinst.gov.kh www.elibraryofcambodia.org

ស្តាប់ព្រះធម៌ទេសនាធម្មចក្កប្បវត្តនសូត្រ បានលុះព្រះសោតាបត្តិផលនោះ ព្រះអដ្ឋង្គិកមគ្គទាំង៨នោះ កើតដោយសោតាបត្តិផលចិត្តព្រមគ្នាទាំង៨ សម្មាទិដ្ឋិ គឺបញ្ញានោះ ត្រាស់ដឹងព្រះអរិយសច្ចទាំង៤ ជាក់ច្បាស់ ដូច្នេះថា ឧបាទានក្ខន្ធទាំង ៥ នោះឈ្មោះទុក្ខអរិយសច្ច ព្រោះជាទីកើតនៃទុក្ខទាំងពួង តណ្ហាដែលប្រាថ្នាឱ្យកើតឧបាទានក្ខន្ធឈ្មោះសមុទយអរិយសច្ច កិរិយាដែលរំលត់តណ្ហាដាច់ស្រឡះមិនបានកើតឡើងទៀត ឈ្មោះទុក្ខនិរោធអរិយសច្ច ព្រះអដ្ឋង្គិកមគ្គទាំង ៨ នោះឈ្មោះទុក្ខនិរោធគាមនីបដិបទាអរិយសច្ច សម្មាសង្កប្បោ គឺវិតក្កនោះក៏លះបង់នូវមិច្ឆាវិតក្កទាំង៣ គឺកាមវិតក្ក ព្យាបាទវិតក្ក វិហឹសាវិតក្ក ឯវិតក្កទាំង៣នេះ លះបង់ជាស្រេច សម្មាវាចានោះក៏លះបង់នូវមិច្ឆាវាចា ៤ ប្រការដូច្នេះ គឺមុសាវាទ ១ បេសុញ្ញវាចា ១ ផរុសវាចា ១ សម្ផប្បលាបវាចា ១ សម្មាកម្មន្តោនោះក៏លះបង់នូវមិច្ឆាកម្មន្តោ ៣ ប្រការ គឺបាណាតិបាត១ អទិន្នាទាន១ កាមេសុមិច្ឆាចារ ១ សម្មាវាយាមោ គឺវីរិយនោះក៏លះបង់នូវមិច្ឆាវាយាមោ ៤ ប្រការ សម្មាសតិដ៏ប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំង៤ប្រការ គឺពិចារណារូបក្ខន្ធ គឺសរីរកាយថាជាអសុភ ពិចារណាឃើញថាវេទនាក្ខន្ធទាំង៣នោះ ថាជាទុក្ខ ពិចារណាឃើញវិញ្ញាណក្ខន្ធនោះថាជាអនិច្ចំមិនទៀង ពិចារណាឃើញសញ្ញាក្ខន្ធ សំខារក្ខន្ធនោះថាជាអនត្តារកខ្លឹមសារគ្មាន សម្មាសមាធិនោះ ញាំងអង្គព្រះអរិយមគ្គទាំង ៧ មានសម្មាទិដ្ឋិជាដើម ដ៏កើតដោយសម្មាសមាធិនោះឱ្យដំកល់នូវក្នុងអារម្មណ៍ គឺព្រះនិព្វានជាមាំ ព្រះអដ្ឋង្គិកមគ្គទាំង ៨ នេះកើតព្រមគ្នាតែម្តងក្នុងសោតាបត្តិមគ្គចិត្ត ហើយធ្វើនូវកិច្ចផ្សេងៗគ្នាដូច្នេះ សម្មាសង្កប្បោនោះជាបច្ច័យដល់សម្មាទិដ្ឋិ មានឧបមាដូចដៃជាបច្ច័យដល់ចក្ខុវិញ្ញាណកាលបើបុគ្គលរេងរើស មើលប្រាក់មាសនោះតោងចាប់យកប្រាក់មាសដោយ

www.budinst.gov.kh www.elibraryofcambodia.org

ដៃក្រឡាស់ ប្រែប្រួលមើល ចក្ខុក្រឡេកមើលក៏ស្គាល់ជាល្អ អាក្រក់ នេះមានឧបមាដូម្តេច សម្មាសង្កប្បោនោះជាបច្ច័យដល់សម្មាទិដ្ឋិ ត្រិះរិះអារម្មណ៍រឿយៗ សម្មាទិដ្ឋិនោះក៏ពិចារណាដឹងនូវអារម្មណ៍នោះថា ធម៌ពួកនេះជាកាមាវចរធម៌ពួកនេះជារូបាវចរ ហើយក៏នាំទៅកាន់អនិច្ចំទុក្ខំអនត្តា សម្មាសង្កប្បោនោះជាភ្នាក់ងារតែខាងជីរះនូវអារម្មណ៍ឱ្យដល់សម្មាទិដ្ឋិ ដូចជាដៃចាប់យកប្រាក់មាសក្រឡាស់ទៅមកឱ្យដល់ចក្ខុនោះ ឯសម្មាវាចា សម្មាកម្មន្តោនោះសោត ក៏ជាបច្ច័យដល់សម្មាអាជីវោ ព្រោះថាកាយកម្មវចីកម្មជាសុចរិតហើយ ចិញ្ចឹមជីវិតក៏ជាសុចរិតដែរ ឯសម្មាវាយាមោសម្មាសតិនោះសោត ក៏ជាបច្ច័យដល់សម្មាសមាធិ មានឧបមាដូចជាបុរស៣នាក់ ជាសំឡាញ់គ្នា នឹងទៅលេងទីណាៗក៏បបួលគ្នាទៅជាមួយគ្នា ថ្ងៃមួយទៅលេងឧទ្យានឃើញផ្កាចម្ប៉ាក៏ប្រាថ្នានឹងបេះ ដើមចម្ប៉ានោះខ្ពស់ឈោងដៃមិនដល់សំឡាញ់ជាគំរប់ ២ ក៏បង្អោរខ្នងទៅឱ្យបុរសនោះជាន់ សំឡាញ់ជាគំរប់ ៣ ក៏បន្ទន់កាយទៅឱ្យចាប់ បុរសនោះក៏ជាន់ខ្នងសំឡាញ់គំរប់ ២ ចាប់ស្មាសំឡាញ់ជាគំរប់ ៣ ទើបបេះយកផ្កាចម្ប៉ានោះបាន នេះមានឧបមាដូចម្តេច សម្មាវាយាមោនោះដូចជាបុរសដែលបង្អោនខ្នងទៅឱ្យជាន់ សម្មាសតិនោះដូចជាបុរសដែលបន្ទន់កាយទៅឱ្យចាប់ សម្មាសមាធិនោះដូចជាបុរសដែលជាន់ខ្នង ហើបបេះផ្កានោះបាន កិរិយាថាសម្មាវាយាមោនឹងសម្មាសតិនោះជាបច្ច័យដល់សម្មាសមាធិ ដែលយកព្រះនិព្វានជាអារម្មណ៍ មានឧបមេយ្យដូចជាបុរ៣នាក់ ដែលជាសំឡាញ់គ្នានោះ ។ មួយវិញទៀតអដ្ឋង្គិកមគ្គទាំង៨ នេះបើនឹងចាត់ដោយខន្ធ សម្មាទិដ្ឋិនឹងសម្មាសង្កប្បោទាំង២ នេះចាត់ជាបញ្ញាក្ខន្ធ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោទាំង៣ នេះចាត់ជាសីលក្ខន្ធ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិទាំង៣ នេះក៏ចាត់

www.budinst.gov.kh www.elibraryofcambodia.org

ជាសមាធិក្ខន្ធ អធិប្បាយថាបុគ្គលឯណាជាអរិយសាវកក៏គប្បីកំចាត់បង់នូវអវិជ្ជាគឺមោហ ដ៏មានលក្ខណឱ្យវង្វេងនោះដោយបញ្ញាក្ខន្ធ កំចាត់បង់នូវទោសគឺព្យាបាទ ដោយសីលក្ខន្ធ កំចាត់បង់នូវលោភនោះដោយសម្មាធិក្ខន្ធ មួយវិញទៀតអង្គមគ្គទាំង៨នេះ បើនឹងចាត់ដោយវិជ្ជានឹងចរណនោះ សម្មាទិដ្ឋិនឹងសម្មាសង្កប្បោទាំង២ នោះចាត់ឈ្មោះជាវិជ្ជា សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិទាំង៦ នេះចាត់ឈ្មោះជាចរណ វិជ្ជានោះដូចជាចក្ខុទាំង២ខាង ចរណនោះដូចជាជើងទាំង២ខាង អធិប្បាយជាបុគ្គលដើរផ្លូវនោះបើមានភ្នែកទាំងពីរបរិសុទ្ធិល្អក្រឡេក មើលទៅឃើញផ្លូវប្រកបដោយភ័យនឹងគ្មានភ័យមានជើងទាំង២ ក៏បរិបូណ៌ទើបនឹងដើរទៅតាមផ្លូវប្រាសចាកភ័យបាន នេះមានឧបមាដូចម្ដេច បើបុគ្គលឯណាបានចំរើនព្រះអដ្ឋង្គិកមគ្គទាំង៨ នេះហើយដំកល់នៅក្នុងទីជាអរិយសាវកនោះ ក៏នឹងក្រឡេកឃើញនូវហេតុផល ថាប្រតិបត្តិដូច្នេះនឹងជាហេតុនឹងឱ្យកើតទុក្ខរកផលរកប្រយោជន៍គ្មាន ប្រតិបត្តិដូច្នេះជាហេតុនឹងឱ្យកើតសុខ ជាផលប្រយោជន៍សំឡឹងឃើញដូច្នេះដោយប្រាជ្ញា គឺសម្មាទិដ្ឋិ សម្មាសង្កប្បោនោះ ព្រះអរិយសាវក ប្រតិបត្តិតាមចរណទាំង ៦ នោះ គឺសម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិដូច្នេះ ជាផ្លូវប្រាសចាកភ័យអន្តរាយទាំងពួង គឺនឹងដល់នូវនគរកែវគឺអមតមហាបុរីនោះជាធាប់ប្រាកដ ដូចជាបុគ្គលដើរផ្លូវមានចក្ខុទាំង ២ ដ៏បរិបូណ៌ ជើងទាំង២មិនបានវិកលវិការ ក៏នឹងដល់ទីប្រទេស ដែលខ្លួនប្រាថ្នានោះធាប់ដូចបំណង ហេតុដូច្នោះសម្ដេចព្រះភគវាទ្រង់ត្រាស់សរសើរព្រះអដ្ឋង្គិកមគ្គទាំង៨ប្រការ ដោយព្រះគាថាដូច្នេះថា **ឧជុកោនាមសោមគ្គោ** ។លេ។ **និព្វានសេ្មទសន្តិកេ** អធិប្បាយថា ព្រះអដ្ឋង្គិក

www.budinst.gov.kh www.elibraryofcambodia.org

មគ្គនេះជាផ្លូវត្រង់ទៅកាន់ទិស គឺព្រះនិព្វានដ៏ប្រាសចាកផ្លូវអន្តរាយទាំងពួង រថគឺព្រះអដ្ឋង្គិកមគ្គនេះមិនបានធ្វើនូវសំឡេងដូចរថយើងធម្មតា រថគឺព្រះអដ្ឋង្គិកមគ្គនេះមិនបានធ្វើនូវសំឡេងដូចរថយើងធម្មតា រថគឺព្រះអដ្ឋង្គិកមគ្គនេះសូម្បីវេនេយ្យសត្វ សែនអសំខេយ្យឡើងជិះព្រមគ្នាតែម្តង ក៏អាចដឹកនាំទៅកាន់នគរកែវគឺព្រះអមតមហានិព្វានបាន ក៏មិនធ្វើនូវសំឡេងដូចរថទាំងពួង រថគឺព្រះអដ្ឋង្គិកមគ្គប្រកបដោយកង់ គឺវីរិយៈដ៏ប្រព្រឹត្តទៅក្នុងកាយនឹងប្រព្រឹត្តទៅក្នុងចិត្តមានហិរិឱត្តប្បៈហាក់ដូចជានឹងដឹកនាំឡើង រថគឺព្រះអដ្ឋង្គិកមគ្គនេះមានលោកុត្តរមគ្គចិត្តជានាយសារថី មានវិបស្សនាសម្មាទិដ្ឋិបញ្ញាក្ខន្ធ នឹងព្រះត្រៃលក្ខណ គឺអនិច្ចំ ទុក្ខំ អនត្តា នោះជាប៉ែកខាងមុខ ព្រះអដ្ឋង្គិកមគ្គនេះស្ថិតនៅក្នុងសន្តានខែបុគ្គលឯណា បុគ្គលនោះក៏ស្ថិតនៅជិតព្រះនិព្វាន ហេតុឯណាហេតុដូច្នោះ អង្គសម្តេចព្រះសព្វញ្ញូព្រះបរមគ្រូ ទ្រង់ត្រាស់ទេសនានឹងភិក្ខុសង្ឃទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ស្ទឹងបញ្ចមហានទីទាំង៥ គឺគង្គា ១ យមុនា ១ អចិរវតី ១ សរភូ ១ មហី ១ ស្ទឹងធំទាំង ៥ នេះតែងហូរទៅកាន់មហាសមុទ្រ នេះតើមានឧបមាដូចម្តេចភិក្ខុឯណា បានចំរើនព្រះអដ្ឋង្គិកមគ្គធ្វើព្រះអដ្ឋង្គិកមគ្គទុកក្នុងសន្តាន ភិក្ខុនោះបានឈ្មោះថា ឱនទៅកាន់ព្រះនិព្វានញោចទៅកាន់ព្រះនិព្វាន ក៏មានឧបមេយ្យដូចមហានទីទាំង ៥ ដែលហូរទៅកាន់មហាសមុទ្រនោះ ។ សម្តែងមកក្នុងព្រះអដ្ឋង្គិកមគ្គជាលោកិយនឹងលោកុត្តរ តាមអដ្ឋកថាវិភង្គ នឹងគម្ពីរព្រះវិសុទ្ធិមគ្គតែប៉ុណ្ណេះ ។

អត្ថនៃមគ្គសច្ច ក៏មានប្រការដូចគ្នា គឺ **និយ្យានដ្ឋោ** មានអធិប្បាយថានាំខ្លួនចេញចាកភពប្រការ១ **ហេត្វដ្ឋោ** អធិប្បាយថាជាហេតុប្រការ១ **ទស្សនដ្ឋោ** អធិប្បាយថាសម្តែងចេញប្រការ១ **អធិបតេយ្យដ្ឋោ** អធិប្បាយថា

www.budinst.gov.kh www.elibraryofcambodia.org

ជាធំប្រការ១ ត្រូវជា ៤ ប្រការ អត្ថជាបឋមគឺនិយ្យានត្ថោ នោះជាលក្ខណៈនៃមគ្គសច្ចពិត ព្រះអង្គប្រាថ្នានឹងឱ្យឃើញសេចក្តីថាបុគ្គលដែលជាសប្បុរសប្រាថ្នានឹងឆ្លងមហាសមុទ្រពោលគឺ វដ្តសង្សារនោះ គោងអាស្រ័យនឹងមគ្គសច្ចនេះ យកមគ្គសច្ចជាសំពៅធមិ ដ៏ធំលើសលប់មិនចេះបៀងមិនចេះឃ្លោង មិនចេះពៀបមិនចេះបែកធ្លុះធ្លាយលិចលង់ក្នុងសមុទ្រសំសារឡើយ នឹងរកសំពៅឯណាឱ្យមាំមួនដូចសំពៅ គឺមគ្គសច្ចនេះមិនមានសោះ សំពៅដទៃមិនអាចនឹងឆ្លងលោកិយសមុទ្របាន ដែលនឹងឆ្លងលោកិយសមុទ្រនេះ មានតែសំពៅគឺមគ្គសច្ចតែមួយទើបអាចឆ្លងបាន លោកិយសមុទ្រនេះមានទឹក ពោលគឺបរិទេវទុក្ខនឹងទោមនស្សទុក្ខ ឧបាយសទុក្ខ លក្ខណៈដែលទួញយំខ្សឹក ខ្សួលចង្អៀតចង្អល់ក្នុងចិត្តសោកអាលោះអាល័យទាំងនោះ ចាត់ជាទឹកក្នុងលោកិយសមុទ្រៗ ប្រកបដោយរលកដ៏ធំកន្លង ពោលគឺជាតិ នឹងជរា ព្យាធិ មរណៈ ដេរដាសដោយខ្មោចទឹកនឹងត្រីសាហាវ ពោលគឺ លោភ ទោស មោហ នឹងមច្ឆរិយធមិ លោកិយសមុទ្រនេះជ្រាលជ្រៅគម្ភីរភាពក្រៃលែងសំពៅដទៃ ក្រៅអំពីសំពៅគឺមគ្គសច្ចហើយមិនអាចនឹងឆ្លងបាន សម្តេចព្រះអនាវរញ្ញាណ ទ្រង់ប្រាថ្នានឹងឱ្យឃើញសេចក្តីដូច្នេះ ទើបសម្តែង អត្ថគឺ និយ្យានត្ថោ ជាអត្ថនៃ មគ្គសច្ចជាបឋមជាលក្ខណៈនៃមគ្គសច្ចពិត ឯអត្ថនៃមគ្គសច្ចជាគំរប់២ គឺហេតុ ត្ថោនោះ មានអធិប្បាយធ្លុះរហូតដល់សមុទសច្ច ដើម្បីនឹងឱ្យឃើញសេចក្តីថាបុគ្គលដែលនឹងឆ្លងទៅឱ្យផុតចាកសមុទ្រពោល គឺវដ្តសង្សារនេះមិនបាន ព្រោះមានសន្តានអាកូលដោយមូលហេតុគឺតណ្ហាៗ នោះមានកំឡាំងក្លាហានណាស់ញាំញីសន្តានចិត្ត សត្វនៅជានិច្ច រកបញ្ញាដែលនឹងពិចារណាទោសនៃតណ្ហានោះមិនបាន ថែមទាំងឧបាទាន ចូលជួយទំនុកបំរុងឱ្យកំឡាំងដល់តណ្ហា ម្លោះ

www.budinst.gov.kh www.elibraryofcambodia.org

ហើយតណ្ហាបានត្រាជាកំឡាំងរឹងរិតតែសង្កត់សង្កិនសត្វឱ្យលិចលង់ចុះ រកអង្គបញ្ញានឹងបំបាត់បំផ្លាញតណ្ហានោះមិនមាន លុះតែរកសំពៅគឺមគ្គសច្ចនេះទើបនឹងឆ្លងរត់ផុតពីលោកិយសមុទ្រផុតអំពីដៃតណ្ហាបាន បើមានអង្គបញ្ញាដ៏ជាសម្មាទិដ្ឋិក្នុងសន្តានពិចារណាឃើញថា តណ្ហានេះជាហេតុឱ្យកើតទុក្ខកើតភ័យឧបទ្រវន្តរាយទាំងពួងផ្សេងៗ ឃើញទោសនៃតណ្ហានេះ ហើយឧស្សាហ៍ខំប្រតិបត្តិតាមផ្លូវគឺមគ្គសច្ច មូលហេតុគឺតណ្ហានឹងសង្កត់សង្កិនញាំញីមិនបាន សម្តេចព្រះសយម្ភូញាណមានប្រាថ្នានឹងឱ្យឃើញសេចក្តីច្បាស់ ធ្លុះរហូតដល់សមុទយសច្ច ដូច្នេះទើបទ្រង់សម្តែងអត្ថគឺហេតុត្ថោជាអត្ថគំរប់ ២ ឯអត្ថជាគំរប់ ៣ គឺនិទស្សន ត្ថោនោះ មានអធិប្បាយធ្លុះរហូតដល់និរោធសច្ច ដើម្បីនឹងបំភ្លឺឱ្យឃើញសេចក្តី ច្បាស់ថាមគ្គសច្ចនេះជាឧបាយឱ្យឃើញជាក់ច្បាស់នូវនិរោធសច្ច កាលបើប្រតិបត្តិ តាមមគ្គសច្ច ហើយក៏អាចនឹងភប់ប្រសប់ជួបប្រទះឃើញនិរោធសច្ច គឺព្រះនិព្វានទៀងប្រាកដណាស់ ព្រះអង្គប្រាថ្នានឹងឱ្យឃើញសេចក្តីភ្លឺធ្លុះរហូតដល់និរោធសច្ចដូច្នេះ ទើបសម្តែងអត្ថគឺនិទស្សនត្ថោ ជាអត្ថនៃមគ្គសច្ច ជាគំរប់៣ ឯអត្ថគំរប់ ៤ គឺអធិបត្យត្ថោនោះ មានអធិប្បាយភ្លឺធ្លុះរហូតដល់ទុក្ខអរិយសច្ច ប្រាថ្នានឹងឱ្យឃើញច្បាស់ សេចក្តីថាមគ្គសច្ចនេះជាធំក្នុងកិច្ចដែលនឹងរម្ងាប់ទុក្ខ ទាំងពួងកងទុក្ខទាំងពួងដែលនឹងរលត់ នឹងស្ងប់នោះអាស្រ័យនឹងប្រតិបត្តិតាមមគ្គសច្ចៗ នេះមានគួរនាដូចជាឱសថនឹងមន្តវិសេសសម្រាប់នឹងរម្ងាប់ពិសទាំងពួង បើពុំនោះសោតដូចជាទឹកភ្លៀងដែលធ្លាក់ចុះស្រួលល្អ ញ៉ាំងពូជស្រូវសំណាបឱ្យមានផលបរិបូណ៌ មគ្គសច្ចនេះជាធំក្នុងកិច្ចដែលនឹងរំងាប់ទុក្ខមាន ជាតិទុក្ខជាដើមជាប្រធាន សម្តេចព្រះទង់ញាណប្រាថ្នានឹងឱ្យឃើញសេចក្តីភ្លឺ ធ្លុះរហូតដល់ទុក្ខអរិយសច្ចដូច្នេះ ទើបទ្រង់សម្តែង

www.budinst.gov.kh www.elibraryofcambodia.org

អត្ថិ អធិបច្ចត្ថោ ជាអត្ថនៃ មគ្គសច្ចជាគំរប់ ៤ សម្តែងអត្ថនៃមគ្គសច្ចចប់តែប៉ុណ្ណេះ ។

ពីនេះ នឹងប៉ែរទៅសម្តែងអានិសង្សព្រះអដ្ឋង្គិកមគ្គជាលោកិយតាមដែលមានក្នុងនិទានជាតកសុត្តន្តបរិយាយ ឱ្យឃើញច្បាស់ក្នុងមគ្គមួយៗ នោះអ្នកប្រាជ្ញគប្បីដឹងដូចជានឹងពោលទៅខាងមុខនេះចុះ សម្មាទិដ្ឋិជាលោកិយនោះ «គឺប្រាជ្ញាដឹងជាក់ច្បាស់នូវគុណព្រះរតនត្រ័យ ដូចជានិទានមានមកក្នុងព្រះធម្មបទថា **ទេ្វកុមារា** មានកុមារពីរនាក់នៅក្នុងនគរសាវត្ថិ កុមារម្នាក់ជាកូនអ្នកសម្មាទិដ្ឋិ កុមារម្នាក់ជាកូនអ្នកមិច្ឆាទិដ្ឋិ កុមារទាំងពីរនាក់តែងលេងល្បែងជាមួយគ្នា មានកាលមួយថ្ងៃកុមារទាំងពីរនាក់ទៅលេងអង្គញ់ជាមួយគ្នា កុមារជាកូនអ្នកសម្មាទិដ្ឋិនោះ កាលបើនឹងបោះអង្គញ់ទៅនោះ រឭកដល់ពុទ្ធគុណថា **ឥតិបិសោភគវា** ជាដើមដូច្នេះ ហើយពោលថា **នមោពុទ្ធស្ស** ហើយក៏បោះអង្គញ់ទៅ ឯកុមារជាកូនអ្នកមិច្ឆាទិដ្ឋិនោះ កាលបើបោះអង្គញ់ទៅក៏រឭកគុណពួកតិរ្ថិយហើយពោលថា **នមោតិត្ថិយានំ** ដូច្នេះហើយក៏បោះអង្គញ់ទៅ កុមារជាកូនអ្នកសម្មាទិដ្ឋិនោះក៏ឈ្នះដរាបតែរាល់គ្រា មានអធិប្បាយថា បុគ្គលជាសម្មាទិដ្ឋិនោះតែងឈ្នះអ្នកប្រកាន់មិច្ឆាទិដ្ឋិ មួយវិញទៀត អ្នកដែលស្ថិតនៅក្នុងសម្មាទិដ្ឋិនោះរមែងតែងផុតចាកអន្តរាយទាំងពួង ដូចមាននិទានថា **ឯកទិវសំ** មានកាលថ្ងៃមួយ បិតាកុមារជាសម្មាទិដ្ឋិនោះក៏នាំកុមារជាកូនដាក់លើរទេះបរចេញទៅព្រៃ រកកាប់ឧស កាប់បានឧសហើយក៏ផ្ទុកលើរទេះ ហើយបរត្រឡប់មកវិញ ដល់ព្រៃសំសានមួយជាខាងក្រៅព្រះនគរ ក៏ដាក់រទេះដោះគោលែងទៅឱ្យស៊ីស្មៅ គោនោះក៏រត់ចូលទៅក្នុងព្រះនគរ បុរសជាបិតាក៏ឱ្យកូននៅចាំរទេះ ខ្លួនក៏រត់ប្រដិតតាមគោចូលទៅក្នុងនគរ លុះចាប់គោបានហើយក៏ត្រឡប់

www.budinst.gov.kh www.elibraryofcambodia.org

ទៅម៉្លឹម្នា ដល់ទ្វារព្រះនគរ ជួនវេលាក៏ព្រលប់ល្មមអ្នករក្សាទ្វារព្រះនគរក៏បិទទ្វារព្រះនគរ បុរសនោះនឹងចេញទៅមិនបាន ឈប់ខាងនៅក្នុងនគរអស់មួយរាត្រី កុមារនោះទន្ទឹងមើលផ្លូវបិតាបាត់ក៏ដេកលក់នៅលើរទេះនោះតែម្នាក់ឯង មានមនុស្ស២នាក់ ម្នាក់ជាកម្មាទិដ្ឋិម្នាក់ជាមិច្ឆាទិដ្ឋិ ជាសំឡាញ់គ្នាអមមនុស្សទាំង២នាក់ នាំគ្នាដើរស្វែងរកអាហារក្នុងវេលារាត្រីនេះ លុះឃើញកុមារដេកលក់នៅលើរទេះ អមនុស្សជាមិច្ឆាទិដ្ឋិ ក៏និយាយទៅនឹងអមនុស្សជាសម្មាទិដ្ឋិថា នែសំឡាញ់ យើងចាប់កុមារនេះបរិភោគជាអាហារចុះ អមនុស្សជាសម្មាទិដ្ឋិឃាត់ថាកុំធ្វើ ដូច្នេះមិនគួរទេ អមនុស្សជាមិច្ឆាទិដ្ឋិមិនស្តាប់ ស្ទុះចូលទៅចាប់កើចជើងកុមារនោះភ្ញាក់ឡើងស្រែកថា **នមោពុទ្ធស្ស** ញាប់មាត់រទេញអមនុស្សនោះភ្ញាក់ភ្លាត់ស្មារតីរបូតជើងពីដៃ ស្ទុះរត់ថយចេញទៅឈរថ្លាយនិយាយាថាអ្វីដូច្នេះ អមនុស្សជាសម្មាទិដ្ឋិនិយាយថា អញឃាត់ថាកុំៗមិនជឿអញមានះមុខរឹង បើដូច្នេះគួរធ្វើទណ្ឌកម្មអ្នកឯង ឥឡូវក្មេងមិនទាន់បរិភោគអាហារត្រូវអ្នកឯងទៅស្វែងរកអាហារមកឱ្យក្មេងនេះបរិភោគ ថាហើយអមនុស្សជាសម្មាទិដ្ឋិក៏នៅចាំរក្សាកុមារនោះ អមនុស្សមិច្ឆាទិដ្ឋិក៏ចូលទៅក្នុងព្រះរាជវាំងយកគ្រឿងសុធាភោជនក្រយាស្ងោយដាក់ក្នុងភាជនមាសនាំយកមក អមនុស្សទាំង២ ប្លែងភេទដូចជាមាតាបិតានៃកុមារនេះ ហើយឱ្យកុមារនោះបរិភោគអាហារ ទើបចារិកអក្សរដាក់នូវភាជន ហើយអធិប្បាយដោយយក្ខានុភាពថាឱ្យតែព្រះមហាក្សត្រឃើញតែមួយព្រះអង្គ បុគ្គលដទៃកុំឱ្យឃើញឡើយ អធិដ្ឋានដូច្នេះហើយ ក៏ភៀសចេញទៅ លុះព្រឹកឡើងមហាជនក៏ផ្អើលឆោឡោថា ចោរលួចព្រះសុវណ្ណភាជនយកទៅបាត់ ចាត់រាជបុរសឱ្យដើររើរកសព្វទីលំនៅមនុស្សក្នុងនគរចេញទៅខាងក្រៅព្រះនគរទៀត ក៏ឃើញព្រះសុវណ្ណភាជននៅ

www.budinst.gov.kh www.elibraryofcambodia.org

លើរទេះនៃកុមារនេះ ក៏នាំយកព្រះសុវណ្ណភាជនទាំងខ្លួនកុមារ នោះចូលទៅថ្វាយដល់ព្រះបរមក្សត្រ ស្តេចទតទៅឃើញអក្សរក៏ជ្រាបច្បាស់ ត្រាស់សួរកុមារៗ ក៏ទូលថា មាតាបិតានាំយកអាហារឱ្យបរិភោគ ព្រះមហាក្សត្រក៏នាំកុមារទាំងបិតាទៅកាន់សម្នាក់ព្រះដ៏មានបុណ្យ ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន អ្នកចំរើនតែពុទ្ធានុស្សតិមួយអាចរក្សាការពារសត្វឱ្យផុតចាកសេចក្តីអន្តរាយបាន ។ ថាធម្មានុស្សតិក៏អាចរក្សាសត្វឱ្យផុតចាកសេចក្តីអន្តរាយបានដែរ ។

សម្តេចព្រះមហាករុណា ទ្រង់មានព្រះពុទ្ធភាសិតថា **មហារាជ** បពិត្រព្រះរាជសម្ភារដ៏ប្រសើរ ចិត្តដែលបុគ្គលចំរើនដោយអនុស្សតិ ៦ ប្រការ ក៏អាចរក្សាបុគ្គលនោះ ឱ្យផុតចាកសេចក្តីអន្តរាយបានខ្លះ ហើយទ្រង់សម្តែងនូវបទគាថា ដូច្នេះថា

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។**

**សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា**

**យេសំ ទិវា ច រត្តោ ច ភាវនាយ រតោ មនោ ។**

អធិប្បាយក្នុងបទគាថានេះថាសតិដ៏រឭកនូវព្រះតថាគតថា ឥតិបិ សោ ភគវា ដូច្នេះជាដើមក្តី សតិដ៏រឭកដល់ព្រះធម្មគុណថា **ស្វាក្ខាតោ ភគវតា ធម្មោ** ដូច្នេះជាដើមក្តី សតិដ៏រឭកដល់ព្រះសង្ឃគុណ **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះជាដើមក្តី សតិរឭកដល់កាយថា**កេសា លោមា** ដូច្នេះ ជាដើមក្តី សតិដ៏រឭកដល់ករុណាភាវនាថា **សព្វេ សត្តា ទុក្ខា បមុច្ចន្តុ**

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះជាដើមក្តី សតិដ៏រឭកដល់មេត្តាភាវនាថា **សព្វេសត្តាអវេរាហោន្តុ** ដូច្នេះជាដើមក្តី អនុស្សតិទាំង ៦ ប្រការនេះសូម្បីតែមួយៗឯណាក្តី ជាប់មាំទៅក្នុងសន្តាននៃបុគ្គលឯណា ហើយថ្ងៃក្តី យប់ក្តី អស់កាលទាំងពួងក្តី សូម្បី១ថ្ងៃតែ៣ដង តែម្តងក្តី បុគ្គលនោះឈ្មោះថាជាសាវកនៃព្រះតថាគត មួយទៀតបុគ្គលទាំងឡាយដេកលក់ក្តី ភ្ញាក់ក្តី ក៏បានឈ្មោះថាភ្ញាក់ដោយប្រពៃជានិច្ចកាលយ៉ាងនេះ ក៏អាចនិងរួចផុតអំពីអន្តរាយទាំងឡាយទាំងពួងនោះ និទាននេះសម្តែងអត្ថថា បុគ្គលអ្នកប្រកបដោយបញ្ញា ស្គាល់គុណព្រះរតនត្រ័យ ហើយចំរើនអនុស្សតិភាវនា ៦ ប្រការដូច្នេះ ឈ្មោះថាដំកល់ទៅក្នុងសម្មាទិដ្ឋិជាលោកិយ ។ មួយវិញទៀត បញ្ញាដែលលះបង់នូវមិច្ឆាទិដ្ឋិ ក៏ឈ្មោះថាសម្មាទិដ្ឋិដែរ ឯមិច្ឆា ទិដ្ឋិនោះ គឺប្រកាន់ខុសថាជាតាប់ ប្រកាន់ថាឱ្យទានគ្មានផលបូជាសក្ការគ្មានផល ប្រកាន់ថាផលនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើល្អធ្វើអាក្រក់គ្មានផល ប្រកាន់ថាលោកនេះក៏គ្មានបរលោកក៏គ្មាន ប្រតិបត្តិមាតាបិតាក៏គ្មានផលប្រយោជន៍ ប្រកាន់យ៉ាងនេះឈ្មោះមិច្ឆាទិដ្ឋិ សមណព្រាហ្មណ៍ដែលរម្ងាប់បាបដោយប្រតិបត្តិល្អ ធ្វើឱ្យជាក់ច្បាស់នូវលោកនេះ នឹងបរលោកដោយបញ្ញា ហើយញាំងអ្នកដទៃឱ្យដឹងផងនោះ ក៏ឥតផលឥតប្រយោជន៍សោះទទេនឹងឱ្យ ដល់សមណព្រាហ្មណ៍ទាំងនេះក៏រកផលប្រយោជន៍គ្មាន បុគ្គលខ្លៅល្ងង់ក្តី បុគ្គលមានប្រាជ្ញាព្រោកប្រាជ្ញក្តី តែស្លាប់ហើយក៏សូន្យសោះតែម្តង នឹងបានទៅកើតទីឯណាទៀតក៏គ្មាន សួគ៌ក៏គ្មាននរកក៏គ្មានបុគ្គលដែលប្រកាន់យ៉ាងនេះឈ្មោះថា មិច្ឆាទិដ្ឋិ «ឯបុគ្គលដែលជឿផលទានផលបូជាសក្ការ ផលប្រតិបត្តិមាតាបិតា នឹងសមណព្រាហ្មណ៍ផលសីល ផលភាវនា ឈ្មោះថាដំកល់ទៅក្នុងសម្មាទិដ្ឋិ វិសជ្ជនាមក្នុងបទសម្មាទិដ្ឋិតែប៉ុណ្ណោះ» ។

www.budinst.gov.kh www.elibraryofcambodia.org

ពីនេះនឹងសម្តែងក្នុងអង្គនៃមគ្គជាគំរប់ ២ គឺ សម្មាសង្កប្បោតទៅ នឹងប្រៀបផ្ទឹមឧបមាសាធកនិទានដែលមានក្នុងសុត្តន្តបរិយាយ លើកមកសម្តែងឱ្យយល់ក្នុងបទសម្មាសង្កប្បោៗនេះ គឺសេចក្តីត្រិះរិះល្អគាប់ប្រពៃក្នុងអារម្មណ៍ទាំង៣ប្រការ គឺនេក្ខមសង្កប្បោ សេចក្តីត្រិះរិះក្នុងអារម្មណ៍ដែលនឹងចេញចាកកាមគុណនោះ១ អព្យាបាទសង្កប្បោ សេចក្តីត្រិះរិះក្នុងអារម្មណ៍ដែលប្រាសចាកចងព្យាបាទអាឃាដក្នុងសត្វទាំងឡាយ ១ អវិហឹសាសង្កប្បោ សេចក្តីត្រិះរិះក្នុងអារម្មណ៍ដែលប្រាសចាកបៀតបៀនសត្វដទៃទាំងពួងនោះ១ វិតក្កក្នុងអារម្មណ៍ទាំង៣ប្រការ នេះឈ្មោះថា សម្មាសង្កប្បោ អ្នកប្រាជ្ញគប្បីដឹងក្នុងមហាជនកជាតកថា កាលព្រះបរមពោធិសត្វជាម្ចាស់នៃយើង កើតជាស្តេចទ្រង់ព្រះនាមមហាជនក សោយរាជសម្បត្តិជាមហាក្សត្រក្នុងនគរមហាមិថិលា មានព្រះជន្មាយុបានមួយម៉ឺនឆ្នាំទ្រង់បំពេញទានបារមី សីលបារមីនៅក្នុងរាជសម្បត្តិនោះអស់មួយពាន់ឆ្នាំ ហើយមានព្រះរាជហឫទ័យនឿយណាយប្រាថ្នានឹងចង់លះបង់រាជសម្បត្តិចេញ ទ្រង់បព្វជ្ជាបំពេញនេក្ខមបារមី ទើបព្រះអង្គប្រារព្ធរាជសម្បត្តិដ៏មានក្នុងនគរមិថិលា ទ្រង់ព្រះបរិវិតក្កថាកាលណាអាត្មានឹងលះបង់នូវមិថិលាមហានគរដ៏រុងរឿងដោយប្រាសាទរាជស្ថានពិត មានកែវនឹងចតុរង្គអង្គ សេនាប្រជាជនទាំងពួងនេះបាន តែទ្រង់ព្រះដំរិះដូច្នេះអស់កាលជាយូរដល់៤ខែ យ៉ាងនេះឈ្មោះថានេក្ខមសង្កប្បោកាលព្រះអង្គចេញទៅទ្រង់ផ្នួសស្តេចទៅនៅក្នុងព្រៃតាំងចំរើនកសិណបរិកម្មភាវនា បានបញ្ចាភិញ្ញាសមាបត្តិកាលណា អព្យាបាទសង្កប្បោក៏បរិបូណ៌ក្នុងកាលនោះ សម្មាសង្កប្បោក៏មានដល់ព្រះមហាជនកដូច្នេះមួយទៀត វិតក្កចេតសិកនេះមាននៅក្នុងពួកបកិណ្ណកចេតសិក វិតក្កដែលកើតដោយអកុសលចិត្តក្តី វិតក្កដែលកើតដោយកុសល

www.budinst.gov.kh www.elibraryofcambodia.org

ចិត្តនោះ គឺត្រិះរិះក្នុងអារម្មណ៍ជាអកុសល ចង់ធ្វើនូវកាយទុច្ចរិត- វចីទុច្ចរិត មនោទុច្ចរិតទាំង៣នេះឈ្មោះថា មិច្ឆាសង្កប្បោ វិតក្កដែលកើតដោយកុសល ចិត្ត ត្រិះរិះក្នុងអារម្មណ៍ជាកុសល នឹងបំពេញកាយសុចរិតវចីសុចរិតមនោ សុចរិតទាំង៣នេះ ឈ្មោះថាសម្មាសង្កប្បោ ដូចព្រះបាទធម្មាសោករាជសោយ រាជសម្បត្តិក្នុងនគរបាតលីបុត្រនោះ មានព្រះអាជ្ញាផ្សាយទៅព្ធដ៏អាកាស១ យោជន៍ ផ្សាយទៅក្នុងផែនទី ១ យោជន៍ដូចគ្នា ទេវតាទាំងឡាយតែងនាំយក ផលាផលនឹងគ្រឿងបរិភោគទាំងពួងមកអំពីហិមវន្តប្រទេសថ្វាយជានិច្ច ទេវ- តា អង្គខ្លះក៏ដងទឹកអំពីស្រះអនោតត្តនាំមកថ្វាយក្នុង១ថ្ងៃ ៧ អម្រែក មានសត្វ បក្សីសេកពាំយកក្បូស្រូវសាលីអំពីស្រះឆទ្ទន្ត មកដាក់ឃ្លាំងថ្វាយក្នុង១ថ្ងៃ៩ពាន់ កេះ ស្តេចមានបុណ្យជាអស្ចារ្យដូច្នេះ ចាប់ដើមអំពីកាលនោះមកព្រះបាទធម្មា សោករាជក៏ទ្រង់ព្រះរាជដំរិះក្នុងកិច្ចដែលនឹងបំពេញទាន ទើបអារាធនាព្រះ សង្ឃចូលទៅទទួលចង្ហាន់ ក្នុងព្រះរាជវាំង ៦ មឺនអង្គ សព្វៗថ្ងៃជានិច្ចៗ ហើយ ទ្រង់ព្រះរាជដំរិះនឹងចង់ឃើញព្រះរូបអង្គ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដើម្បីនឹង បូជា ទើបស្តេចឱ្យយកខ្លួនស្តេចកាលនាគរាជឡើងមក ហើយក៏ឱ្យនិមិត្តអាត្មា ឱ្យដូចអង្គព្រះសម្មាសម្ពុទ្ធ ហើយទ្រង់ធ្វើសក្ការបូជាអស់៧ថ្ងៃ ទ្រង់ព្រះដំរិះចង់ ជ្រាបព្រះសទ្ធម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនាទាំង៨ម៉ឺន ៤ពាន់ព្រះ ធម្មខន្ធ ឱ្យសាងព្រះចេតិយ ៨ ម៉ឺន ៤ពាន់ បញ្ចុះព្រះសារីរិកធាតុ សាងព្រះ វិហារ ៨ ម៉ឺន ៤ពាន់ ក្នុងនគរដទៃៗផង លុះសាងព្រះចេតិយនឹងព្រះវិហារក្នុង អសោការាមស្រេចហើយ ទ្រង់ព្រះដំរិះតែងការឆ្លងព្រះចេតិយនឹងព្រះវិហារ ទាំង៨ ម៉ឺន ៤ ពាន់ព្រមគ្នាតែម្តងក្នុងវិហារមួយ ហើយទ្រង់ព្រះដំរិះចង់ផ្គាប់ ព្រះអង្គជាញាតិក្នុងព្រះពុទ្ធសាសនា ឈ្មោះថា ធម្មទាយាទទើបបំបួសព្រះ

www.budinst.gov.kh www.elibraryofcambodia.org

មហិន្ទកុមារជាព្រះរាជឱរស នឹងនាងសង្ឃមិត្តារាជធីតាឱ្យជាភិក្ខុនឹងភិក្ខុនី ទ្រង់ឧបត្ថម្ភទំនុកបំរុងព្រះពុទ្ធសាសនា ឱ្យព្រះសង្ឃធ្វើតតិយសង្គាយនាព្រះត្រៃបិដក ហើយទ្រង់ព្រះដំរិះនឹងប្តេជ្ញាព្រះអង្គថាជាឧបាសកក្នុងព្រះពុទ្ធសាសនា ព្រះអង្គក៏ខំឧស្សាហ៍ជម្រង់នៅក្នុងព្រះត្រៃសរណគមន៍ តែងព្រះរាជសាសន៍ទៅដល់ព្រះបាទទេវានំបិយតិស្សក្នុងលង្កាទ្វីប ឱ្យដឹកល់នៅក្នុងព្រះត្រៃសរណគមន៍ ហើយឱ្យព្រះមហិន្ទថេរ នាំយកព្រះពុទ្ធសាសនាទៅប្រដិស្ឋានក្នុងលង្កាទ្វីប ឱ្យនិមន្តដើមមហាពោធិទៅដាំក្នុងលង្កាទ្វីប ឱ្យនិមន្តព្រះសារីរិកធាតុទៅបញ្ចុះក្នុងលង្កាទ្វីប នោះទ្រង់ព្រះដំរិះកាកុសលជាច្រើនប្រការណាស់ ក៏សឹងដ៏កើតអំពីកាមាវចរកុសលចិត្ត ឈ្មោះថាសម្មាសង្កប្បោទាំងអស់នោះ ដែលជាលោកិយមគ្គកើតមានដល់ព្រះបាទធម្មាសោករាជដូច្នេះ អ្នកប្រាជ្ញគប្បីពិចារណា មើលតាមដែលពណ៌នាមកនេះចុះ ។

ពីនេះនឹងពណ៌នាក្នុងបទសម្មាវាចាតទៅ សម្មាវាចាដ៏កើតដោយកាមាវចរកុសលចិត្តជាលោកិយក៏មាន ដូចជានាងសុជាតាដ៏ជាប្អូននៃនាងវិសាខាមហាឧបាសិកា នាងសុជាតានោះជាសុនិសានៃអនាថបិណ្ឌកមហាសេដ្ឋី នាងសុជាតានោះប្រកបដោយមានះ ថាខ្លួនជាធីតាមហាត្រកូលមានសម្បត្តិច្រើនមិនសូវកោតក្រែងមេក្មេកបាក្មេកនូវស្វាមី រមែងពោលវាចារឹង រុស-ប្រទុស្តតបជាផរុសវាចាប្រកបដោយវចីទុច្ចរិត គ្រៅធមិគ្រៅគន្លង ជនទាំងពួងក្នុងផ្ទះក៏កើតទៅជាវិវាទឈ្លោះទាស់ទែងគ្នា ទឹងនាងសុជាតាជាកោលាហលវិករខ្លាំង **ឯកទិវសំ** ក៏វេលាថ្ងៃមួយអនាថបិណ្ឌិកសេដ្ឋី និមន្តព្រះសម្ពុទ្ធព្រមទាំងព្រះភិក្ខុសង្ឃទៅធ្វើភត្តកិច្ចឆាន់ក្នុងផ្ទះនោះ ព្រះបរមលោកនាថសាស្តាចារ្យទ្រង់ឮសូរសទ្ទីកគឹកគងជម្លោះដូច្នោះ ក៏មានព្រះពុទ្ធដីកាសួរអនាថ-

www.budinst.gov.kh www.elibraryofcambodia.org

បិណ្ឌិកសេដ្ឋីថា ហេតុអ្វីជនទាំងឡាយពោលពាក្យទុច្ចរិតគឹកកងរំពងដូច្នេះ អនាថបិណ្ឌិកសេដ្ឋីក៏ក្រាបទូលថា ភន្តេបពិត្រព្រះអង្គដ៏ចំរើន នាងសុជាតាជាសុនិសានៃខ្ញុំព្រះករុណានេះ នាងនោះមានមានះរឹងរូសក្រៃពេកណាស់ ព្រោះអាងថាខ្លួនជាធីតាមហាត្រកូលមានសម្បត្តិច្រើន ពោលពាក្យជាផរុសវាចាមិនមានញញើត កោតក្រែងអ្នកឯណាឡើយ បានជាឮសូរសន្ធឹកកងដូច្នេះ ព្រះអង្គបានទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏មានព្រះពុទ្ធដីកាឱ្យហៅរកនាងសុជាតាមកហើយត្រាស់សួរថា នែនាងសុជាតា ចូរនាងស្ដាប់ធម៌ តថាគតនឹងសម្ដែងប្រាប់ថា ភរិយាក្នុងលោកនេះមាន៧ចំពួក គឺវធកាសមាភរិយា១ ចោរីសមាភរិយា១ អយ្យាសមាភរិយា ១ មាតាសមាភរិយា ១ ភគិនីសមាភរិយា ១ សហាយាសមាភរិយា ១ ទាសីសមាភរិយា ១ ត្រូវជា ៧ចំពួក នាងតើជាភរិយាដូចម្ដេច នាងសុជាតាទូលថាភន្តេ បពិត្រព្រះអង្គដ៏ចំរើន ដែលព្រះអង្គទ្រង់មានព្រះពុទ្ធដីកាថា ភរិយាមាន៧ចំពួកនោះ សូមឱ្យព្រះអង្គទ្រង់សម្ដែងដោយពិស្ដារ ជាសណ្ដាប់ក្នុងកាលឥឡូវនេះ ។

ព្រះអង្គទ្រង់មានព្រះពុទ្ធភាសិតថា ហៃនាងសុជាតា ភរិយាណាមានចិត្តប្រទុស្តនឹងស្វាមីអាត្មាឥតមានសេចក្ដីករុណាក្នុងស្វាមី តែងធ្វើនូវអំពើឥតប្រយោជន៍ដល់ស្វាមី មានតែត្រេកត្រអាលដោយបុរសដទៃ មើលងាយស្វាមីអាត្មាខ្វល់ខ្វាយរកវេលាគិតតែឱ្យស្វាមីស្លាប់ ភរិយាមានសភាពយ៉ាងនេះឈ្មោះថា វធកាសមាភរិយា ។

ប្រការ១ទៀត ភរិយាឯណាប្រកបដោយលោភចេតនា ប្រាថ្នានឹងបែចិត្តចេញក្រៅចិត្តស្វាមី បានទ្រព្យអ្វីៗលបលាក់មិនឱ្យស្វាមីដឹង ពុំនោះបើស្វាមីរកទ្រព្យបានមកដោយកសិកម្មវាណិជកម្មក្ដី ដោយសិប្បកម្មក្ដី ក៏លបលួច

www.budinst.gov.kh www.elibraryofcambodia.org

លោក់មិនអោយស្វាមីដឹងទុកជាប្រយោជន៍អាត្មា ភរិយាមានសភាពដូច្នេះ ឈ្មោះថា ចោរីសមាភរិយា ។

មួយទៀតភរិយាអ្នកឯណាប្រកបដោយសេចក្ដីខ្ជិលច្រអូសដេកច្រើន មិនធ្វើការអ្វីទាំងពួង ចិត្តសាហាវពោលវាចាអាក្រក់ជួជាតិ កំហែងប្រើស្វាមីអោយធ្វើការ ចំណែកអាត្មាមិនអោយស្វាមីស្រដីអ្វីបាន ភរិយាមានសភាពដូច្នេះឈ្មោះថា អយ្យាសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា មានចិត្តប្រកបដោយករុណា ស្វាមីភក្តិ មានចិត្តស្មោះស្ម័គ្រ ស្វែងរកផលប្រយោជន៍អោយស្វាមី ឧស្សាហ៍ព្យាបាលថែទាំរក្សាស្វាមីដូចជាមាតារក្សាបុត្រ ភរិយាមានសភាពដូច្នេះឈ្មោះថា មាតាសមាភរិយា ។

មួយទៀតភរិយាឯណា មានសេចក្ដីខ្មាសបាបខ្លាចបាប ហើយគោរពកោតក្រែងស្វាមី ដូចប្អូនស្រីកោតក្រែងបងប្រុស ភរិយាមានសភាពដូច្នេះឈ្មោះថា ភគិនីសមាភរិយា ។

មួយទៀតភរិយាអ្នកឯណា មានចិត្តជាកុសលប្រកបដោយសីលសមាចារ មានចិត្តសុចរិតស្លូតត្រង់មានវត្តប្រតិបត្តិស្វាមី មានចិត្តរាក់ទាក់ស្ម័គ្រស្មោះស្រលាញ់ស្វាមី មិនដែលពោលពាក្យទ្រគោះបោកបោះសំដីមើលងាយស្វាមីអោយអាក់អន់អៀន ភរិយាមានសភាពដូច្នេះឈ្មោះថា សហាយា-សមាភរិយា ។

មួយទៀតភរិយាអ្នកឯណា បើស្វាមីស្រដីជេរថា គំរាមវាយដំមិនមានខឹងតបប្រទុស្តរាយវិញ មានចិត្តអំណត់អត់សង្កត់កំហឹងមិនបានចងគំនុំនឹងស្វាមី ប្រព្រឹត្តប្រតិបត្តិតាមអំណាចស្វាមី ដូចទាសីខ្លាចម្ចាស់ ភរិយាមានសភាព

www.budinst.gov.kh www.elibraryofcambodia.org

ដូច្នេះឈ្មោះថា ទាសីសមាភរិយា ។

ម្នាលនាងសុជាតា ភរិយាទាំង៧ចំពួកនេះតែងនឹងមាននៅក្នុងលោក ភរិយា ៣ ពួងខាងដើម គឺវធកាសមាភរិយា ចោរីសមាភរិយា អយ្យាសមាភរិយាទាំង៣នេះ លុះចុតិរំលាងខន្ធទៅក៏ទៀងតែនឹងទៅសោយទុក្ខក្នុងអបាយភូមិដោយផលនៃកម្មដែលខ្លួនធ្វើមិនគាប់នោះ ភរិយា ៤ ចំពួកខាងក្រោយ គឺមាតាសមាភរិយា ភគិនីសមាភរិយា សហាយាសមាភរិយា ទាសីសមាភរិយាទាំង៤នេះ លុះចុតិរំលាងអត្តភាពអំពីជាតិនេះហើយទៀង តែនឹងបាន ទៅសោយសម្បត្តិក្នុងសុគតិភពគឺមនុស្សសុគតិនឹងទេវសុគតិប្រាសលែងទុក្ខផងទាំងពួង ដោយបុញ្ញាកម្មដែលខ្លួនបានប្រតិបត្តិស្វាមីគួរតាមធម៌តាមគន្លងសុចរិត ។

កាលបើនាងសុជាតា បានស្តាប់ធម៌ទេសនាដូច្នេះហើយ ក៏ក្រាបនមស្សការព្រះបាទយុគលនៃសម្តេចព្រះត្រៃលោកនាថសាស្តាចារ្យ នាងក៏ទូលប្តេជ្ញាខ្លួនថា ភន្តេបពិត្រព្រះអង្គដ៏ចំរើនចាប់ផ្តើមអំពីថ្ងៃនេះជាដើម ទៅខ្ញុំសូមឧទ្ទិស្សចំពោះព្រះពុទ្ធរតន ធម្មរតន សង្ឃរតន ជាទីពឹង ជាទីអាស្រ័យដរាបអស់ជីវិតជាកំណត់ សូមឱ្យព្រះអង្គទ្រទ្រង់នូវខ្ញុំថាជាឧបាសិកាក្នុងព្រះបវរពុទ្ធសាសនានេះ នាងសុជាតាថ្វាយខ្លួនជាឧបាសិកា ដឹកលំនៅក្នុងព្រះត្រៃសរណគមន៍ហើយ ក៏លះបង់នូវមិច្ឆាចារនោះចេញ មិនបានពោលមិច្ឆាវាចា វៀរមិច្ឆាវាចា ដោយកាមាវចរកុសលចិត្ត ដូច្នេះឈ្មោះថាដឹកលំនៅក្នុងសម្មាវាចាដ៏ជាលោកិយមគ្គព្រះអរិយសាវកទាំងឡាយ មានព្រះសោតាបន្នជាដើម លោកវៀរចាកមិច្ឆាវាចាវិរតិចេតសិកក៏កើតដោយសោតាបត្តិមគ្គចិត្តនោះ ឈ្មោះលោកកុត្តរសម្មាវាចាជាសមុច្ឆេទវិរតិ កាន់នូវមិច្ឆាវាចាដាច់ចេញស្រលះមិន

www.budinst.gov.kh www.elibraryofcambodia.org

បានកើតមានតទៅទៀត ដូចព្រះអរិយសាវកទាំងឡាយក្នុងនគរសាវត្ថី កាលបើដល់កាលកំណត់នក្ខត្តឫក្សបុគ្គលពាលទាំងឡាយ ក៏នាំគ្នាលេងមហោស្រពគំរប់ ៧ ថ្ងៃ មនុស្សពាលទាំងឡាយសឹងដីផឹកសុរាជាពួកជាគង ដើរពោលអសប្បុរសវាចា ជាវាចាឥតប្រយោជន៍គ្រប់ទ្វារផ្ទះអ្នកនគរ កាលណាបើអ្នកផ្ទះបានឱ្យទ្រព្យ ១ បាទ ១ កហាបណទើបបានដើរចេញទៅ បណ្តាជនជាអរិយសាវកសឹងដ៏បិទទ្វារ ផ្ទះឱ្យទ្រព្យបន្តិចបន្តួចទៅមនុស្សពាលនេះហើយ ក៏បញ្ជូនឱ្យទៅទីដទៃៗទៅ សម្ងំនៅក្នុងផ្ទះចំពីនពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ អស់ថ្ងៃជាគំរប់៧ លុះរួចស្រេចក៏នាំគ្នាទៅកាន់ព្រះវិហារនមស្សការព្រះពុទ្ធអង្គ ហើយទូលថា មនុស្សពាលទាំងឡាយលេងមហោស្រពសឹងដ៏ពោលនូវអសប្បុរសវាចា មានប្រការផ្សេងៗអស់៧ថ្ងៃ យើងខ្ញុំទាំងឡាយក៏សម្ងំនៅតែក្នុងផ្ទះ ទើបមិនបានមកកាន់សំណាក់ព្រះអង្គអស់ ៧ ទើបសម្តេចព្រះមហាករុណាទ្រង់ត្រាស់ទេសនាជាបទព្រះគាថាដូច្នេះថា

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**

**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ**

អធិប្បាយថា ជនទាំងឡាយជាមនុស្សពាលមិនបានស្គាល់ប្រយោជន៍ក្នុងឥធលោកនឹងបរលោក រកបញ្ញាមិនមាននោះរមែងប្រកបនូវសេចក្តីប្រមាទជានិច្ច ជនទាំងឡាយជាអ្នកមានបញ្ញាស្គាល់ប្រយោជន៍ក្នុងឥធលោក នឹងបរលោក រមែងរក្សានូវអប្បមាទធម៌គឺមិនប្រមាទឱ្យមាំមួនខ្ជាប់នៅក្នុងសន្តានមិនឱ្យវិនាសដូចបុរសរក្សាទ្រព្យដ៏ប្រសើរគឺកែវ៧ប្រការដែលបានតៗ មកអំពីវង្សនៃត្រកូល ដូច្នេះបានឈ្មោះថាព្រះអរិយសាវក រក្សានូវសម្មាវាចាដ៏ជាលោកុត្តរវិសជ្ជនាមកក្នុងកម្មវាចាតែប៉ុណ្ណោះ ។

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងបទសម្មាកម្មន្តោនោះ គឺវិរតិចេតសិកដ៏វៀរចាក បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ វិរតិ ៣ប្រការ គឺសម្បត្តវិរតិ ១ សមាទានវិរតិ ១ សមុច្ឆេទវិរតិ ១ សម្បត្តវិរតិនោះ ដូចជាចក្កនឧបាសក បងប្រុសប្រើឱ្យទៅរកសាច់ទន្សាយស្រស់យកមកឱ្យពេទ្យគេធ្វើថ្នាំឱ្យមាតា ដែលអាពាធចក្កនឧបាសករកចាប់បានទន្សាយរស់មួយ ឮទន្សាយនោះស្រែកក៏គិតសង្វេគថា និមិនគួរសោះ នឹងមកសម្លាប់ជីវិតសត្វដទៃព្រោះតែជីវិតនៃមាតាអាត្មានោះលុះគិតដូច្នោះហើយ ក៏ដោះទន្សាយនោះលែងទៅ យ៉ាងនេះឈ្មោះថាសម្បត្តិវិរត្តិ ចាត់ជាសម្មាកម្មន្តោប្រការ១ ។

មួយវិញទៀតមានបុរសម្នាក់សមាទានសីលក្នុងសម្នាក់ ព្រះមហាថេរ ១ អង្គហើយក៏ទៅធ្វើស្រែ ដល់វេលាលែងគោទៅឱ្យស៊ីស្មៅ គោនោះក៏ដើរចូលទៅបាត់ក្នុងព្រៃបុរសនោះកាន់កំបិតព្រាលីដើរទៅរកគោក្នុងព្រៃឡើង ។ ទៅលើភ្នំឈ្មោះ ទន្តវលមានបពិត មានពស់ថ្លាន់មួយធំមកក្នុងទីនោះ ឃើញបុរសនោះក៏ស្ទុះមកព័ទ្ធជើងរួបតាំងអំពីកជើងឡើងទៅ បុរសនោះក៏គិតថាអញនឹងកាប់ពស់នេះដោយកំបិតព្រា ហើយប្រែត្រឡប់គិតថាអាត្មាបានទទួលសមាទានសីល នឹងមកសម្លាប់សត្វព្រោះតែជីវិតអាត្មាយ៉ាងនេះ មិនគួរសោះគិតដូច្នោះហើយក៏បោះកំបិតព្រាចោលទៅឆ្ងាយដោយគំនិតថា ជីវិតអាត្មាវិនាសទៅចុះ កុំឱ្យវិនាសសីលអាត្មាលៃបានរក្សាមកនេះ ពស់នោះក៏មិនអាចរួចរិតនៅបាន ក៏រសាយលាចេញលូនចូលទៅ បុរសនោះក៏បានរួចជីវិតយ៉ាងនេះឈ្មោះថាសមាទានវិរតិទាំង២នេះ កើតដោយកាមាវចរកុសលចិត្ត បានឈ្មោះថាសម្មាកម្មន្តោជាលោកិយមគ្គ ឯសមុច្ឆេទវិរតិនោះ ដូចជាបុរសម្នាក់ឈ្មោះអរិយជាអ្នកស្លូតត្រីអាស្រ័យជីវិតសព្វថ្ងៃ មានថ្ងៃមួយសម្តេចព្រះសពេជ្ញពុទ្ធ

www.budinst.gov.kh www.elibraryofcambodia.org

បរមគ្រូទ្រង់ពុទ្ធដំណើរទៅត្រង់ ទីដែលបុរសនោះស្ទូច មួយអន្លើដោយភិក្ខុសង្ឃជាច្រើនអង្គ បុរសនោះលុះឃើញព្រះអង្គពីចម្ងាយ ក៏កើតហិរិឱត្តប្បមានសេចក្តីខ្មាសក៏យកសន្ទូចលាក់ទុក្ខ ព្រះអង្គពុទ្ធដំណើរដល់ទីនោះក៏ឈប់បែសួរទៅព្រះសង្ឃសាវកវិញថា អ្នកនេះឈ្មោះអ្វី ព្រះសារិបុត្តក៏ទូលថាខ្ញុំឈ្មោះសារិបុត្ត ព្រះអង្គក៏សួរព្រះសង្ឃជាលំដាប់រៀងទៅ ព្រះសង្ឃក៏ទូលជាលំដាប់ៗទៅតាមនាមអាត្មាទីទៃៗអរិយបុរសក៏គិតថា ព្រះសាស្តាសួរនាមព្រះសង្ឃសាវកហើយមុខជានឹងសួរឈ្មោះអញដែរដឹង អង្គព្រះសព្វញ្ញូទ្រង់ជ្រាបវារចិត្តបុរសនោះទ្រង់ក៏មានព្រះពុទ្ធដីកាសួរថា អ្នកនេះឈ្មោះថាអ្វី បុរសនោះក៏ក្រាបទូលថាខ្ញុំព្រះករុណាឈ្មោះអរិយ ព្រះអង្គក៏ទ្រង់ត្រាស់ទេសនាជាបទព្រះគាថាដូច្នេះថា ។

**ន តេន អរិយោ ហោតិ យេន បាណានិ ហឹសតិ**

**អហឹសា សព្វបាណានំ អរិយោតិ បវុច្ចតិ**

អធិប្បាយថា បុគ្គលឯណាមួយបៀតបៀននូវជីវិតសត្វទាំងឡាយដោយហេតុឯណា បុគ្គលនោះនឹងបានឈ្មោះថាអរិយដោយហេតុបៀតបៀននូវជីវិតនៃសត្វទាំងឡាយនោះឥតអត្ថមានឡើយ ឯពាក្យដែលតថាគតហៅថាអរិយដោយហេតុដែលមិនបានបៀតបៀននូវសត្វទាំងឡាយ អរិយបុរសបានស្តាប់ព្រះធម៌ទេសនាដូច្នោះហើយ ក៏បានលុះសោតាបត្តិផលជាអរិយបុគ្គលវៀរបង់នូវអំពើបាណាតិបាត ដោយអំណាចសម្មាកម្មន្តោដ៏កើតដោយសោតាបត្តិមគ្គចិត្តសោះ ។

ឯសម្មាកម្មន្តោដែលវៀរចាកអទិន្នាទាននោះ ដូចជានាងខុជ្ជុត្តរា ជាស្រីបម្រើនៃនាងសាមាវតីមហេសីព្រះបាទឧទេនរាជ ស្តេចទ្រង់ប្រទានព្រះរាជ

www.budinst.gov.kh www.elibraryofcambodia.org

ទ្រព្យឱ្យនាងសាមាវតី ១ ថ្ងៃ ៨ កហាបណជាថ្លៃផ្កាកម្រងសព្វៗថ្ងៃជានិច្ច នាងសាមាវតីប្រើនាងខុជ្ជុត្តរា ឱ្យបើកទៅទិញផ្កាជាងមាលាការតែសព្វថ្ងៃមិនដែលដាច់ នាងខុជ្ជុត្តរាទិញផ្កាតែ ៤ កហាបណា តែយកជាប្រយោជន៍អាត្មា ៤ កហាបតែរាល់ថ្ងៃ វេលាថ្ងៃមួយជាងមាលាការនិមន្តព្រះសាស្តាព្រមទាំងព្រះភិក្ខុសង្ឃ មកធ្វើភត្តកិច្ចឆាន់នៅផ្ទះអាត្មា ហើយប្រាប់ដល់នាងខុជ្ជុត្តរាថា ថ្ងៃនេះចូរនាងនៅជួយយើងអង្គាសព្រះសង្ឃ មានអង្គព្រះសាស្តាជាប្រធានស្តាប់ព្រះធម៌ទេសនាសិន រួចសឹមយកផ្កាទៅចុះ នាងខុជ្ជុត្តរាក៏នៅជួយអង្គាសព្រះសង្ឃ លុះរួចក៏ស្តាប់ធម៌ទេសនានៃសម្តេចព្រះសាស្តា នាងក៏លុះសោតាបត្តិផល ហើយទិញផ្កាអស់ទាំង ៨ កហាបណ នាំយកទៅថ្វាយនាងសាមាវតី នាងឃើញផ្កាច្រើនទ្វេមួយជាពីរ ក៏សួរថា ថ្ងៃនេះប្រហែលជាទ្រង់ព្រះរាជទានព្រះរាជទ្រព្យឱ្យច្រើនជាងសព្វថ្ងៃ ដូចម្តេច ។ នាងខុជ្ជុត្តរាទូលថាមិនដូច្នោះទេ ព្រះរាជទ្រព្យដែលទ្រង់ព្រះរាជទានសព្វៗថ្ងៃ ៨ កហាបណៗ តែកាលថ្ងៃមុនៗ ខ្ញុំទិញតែ ៤ កហាបណយមកថ្វាយ បានជាផ្កាតិច ថ្ងៃនេះខ្ញុំបានស្តាប់ព្រះធម៌ទេសនាព្រះពុទ្ធជាម្ចាស់ ត្រាស់សម្តែងទោសអទិន្នាទាន ថាមានទោសជាទម្ងន់ ហេតុនោះបានជាខ្ញុំខ្លាចមិនហ៊ានលួចយកដូចថ្ងៃមុនៗ សូមឱ្យព្រះនាងអត់ទោសខ្ញុំនេះចុះ នាងខុជ្ជុត្តរានេះ កាលបើបានដល់ព្រះសោតាបត្តិផលហើយក៏មិនបានពោលមុសាវាទ បែរជាប្រាប់តាមសេចក្តីពិតយ៉ាងនេះក៏ជាអង្គនៃព្រះអរិយមគ្គ គឺសម្មាវាចានឹងសម្មាសង្កប្បោ ប្រាកដដល់នាងខុជ្ជុត្តរាដោយប្រការដូច្នេះ ។

មួយវិញទៀតសម្មាកម្មន្តោដែលវៀរចាកកាមេសុមិច្ឆាចារនោះ បានដូចសេដ្ឋីបុត្តម្នាក់ឈ្មោះខេមក ជាក្មួយអនាថបិណ្ឌិកសេដ្ឋី ឯខេមកនោះកាល

www.budinst.gov.kh www.elibraryofcambodia.org

ជាតិអំពីមុខ បានធ្វើដងទង់មាសដ៏ល្អប្រពៃបូជាព្រះចេតិយបញ្ចុះព្រះសារីរិក-ធាតុព្រះពុទ្ធកស្សប ហើយដឹកលស់សេចក្តីប្រាថ្នាថា សូមតេជះផលានិសង្សដែលខ្ញុំបានធ្វើបូជាដង់មាសនេះ បើសត្រីភាពទាំងពួងវៀរលែងតែញាតិសាលោហិត ថាបើបានឃើញរូបអាត្មានេះកាលណាក៏ឱ្យមានចិត្តចងប្រតិព័ទ្ធស្នេហាកុំឱ្យទប់ទល់អាត្មាបាន ហេតុដោយសម្ភមនោះកាលបើបានមកបង្កើតជាខេមកសេដ្ឋីបុត្តនេះ សត្រីភាពឯណាតែបាន ឃើញហើយក៏សឹងមានចិត្តចងប្រតិព័ទ្ធរត់តាមខេមកជាច្រើន ខេមកក៏ប្រព្រឹត្តធ្វើនូវអំពើកម្មមិច្ឆាចារដោយភរិយាអ្នកដទៃៗរឿយៗ មានកាលថ្ងៃមួយ រាជបុរសចាប់ខ្លួនខេមកបាន នាំយកទៅថ្វាយព្រះបាទបសេនទិកោសលរាជ ស្តេចទ្រង់ជ្រាបថាខេមកជាក្មួយអនាថបិណ្ឌិកសេដ្ឋីជាមហាឧបាសកក្នុងព្រះពុទ្ធសាសនា បើនឹងធ្វើទោសចុះទណ្ឌកម្ម អនាថ-បិណ្ឌិកសេដ្ឋី ក៏នឹងដល់សេចក្តីអៀនខ្មាសអប្បយសដល់ជនទាំងឡាយ ស្តេចទ្រង់ព្រះចិន្តាដូច្នោះក៏មិនបានធ្វើទោសដោះលែងទៅ ខេមកក៏មិនចេះរាងចាលប្រព្រឹត្តធ្វើមិច្ឆាចារដូច្នេះទៀត រាជបុរសចាប់បានយកទៅថ្វាយព្រះមហាក្សត្រៗ ស្តេចក៏ដោះលែងតែយ៉ាងនេះដល់ទៅ៣ដង មកឯក្រោយអនាថបិណ្ឌិកសេដ្ឋីក៏នាំខ្លួនខេមកក្រាបទូលសម្តេចព្រះមហាករុណា ព្រះអង្គទ្រង់ទេសនាជាបទព្រះគាថាដូច្នេះថា **ចត្តារិដ្ឋានានិនរោបមត្តោ** ជាដើមអធិប្បាយថា បុគ្គលឯណារកស្មារតីនឹងពិចារណាកុសលាកុសលគ្មាន ហើយប្រព្រឹត្តសេពគប់នឹងភរិយានៃបុគ្គលដទៃ បុគ្គលនោះរមែងដល់នូវហេតុជាទោសឱ្យកើតទុក្ខ៤ប្រការគឺនឹងឱ្យសោយផលនៃអកុសលនោះជាច្រើនប្រការ១ សេចក្តីព្រួយបរិវិតក្ករលោប់រសល់ដេកមិនលក់មិនស្កប់ដោយភ័យខ្លាចប្រការ១ នឹងបាននូវពាក្យជំណេះជំណៀលឥតមានអ្នកឯណានឹងសរសើរប្រការ ១ លុះចុតិអំពីអត្តភាព

www.budinst.gov.kh www.elibraryofcambodia.org

នេះក៏ទៀង តែនឹងទៅសោយទុក្ខនៅក្នុងនរកទទួលទុក្ខវេទនាជាទម្ងន់ពន់ប្រមាណប្រការ១ នឹងដល់នូវទុក្ខ៤ប្រការដូច្នេះ ។ ខេមកសេដ្ឋី ។ គ្រលុះបានស្តាប់ព្រះធម៌ទេសនា ក៏បានសម្រេចព្រះសោតាបត្តិផលជាអរិយបុគ្គលក្នុងខណនោះមិនបានប្រព្រឹត្តធ្វើនូវអំពើកាមេសុមិច្ឆាចារតទៅនេះ ក៏ជាអង្គនៃព្រះអរិយមគ្គ គឺសម្មាកម្មន្តោដ៏កើតដោយសោតាបត្តិមគ្គចិត្ត ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៥ គឺសម្មាអាជីវោនោះ គឺរិយាដែលវៀរចាកការលក់ដូរជួញប្រែ រកចិញ្ចឹមជីវិតក្រៅក្រិត្យក្រៅគន្លងធម៌ គឺជួញប្រែដោយជំនួញ៥ប្រការ **សត្តវណិជ្ជា** គឺជួញសត្វមានជីវិតជួញមនុស្សជួញគោក្របីជាដើម ១ **សត្ថវណិជ្ជា** ជួញគ្រឿងសាស្ត្រាវុធមានដាវលំពែងជាដើម ដ៏សម្រាប់នឹងប្រហារជីវិតសត្វទាំងពួងមានមនុស្សជាដើម ១ **មំសវណិជ្ជា** ចិញ្ចឹមសត្វមានមាន់ទាជាដើម ហើយសម្លាប់ខ្លួនឯងក្តី ឱ្យអ្នកដទៃសម្លាប់ក្តីយកសាច់នោះលក់ចិញ្ចឹមជីវិតប្រការ ១ **មជ្ជវណិជ្ជា** ជួញទឹកស្រវឹង គឺសុរាមេរយប្រការ១ **វិសវណិជ្ជ** ប្រកបថ្នាំពិសសម្រាប់សម្លាប់ជីវិតសត្វមានមនុស្សជាដើម លក់ដូរចិញ្ចឹមជីវិតប្រការ ១ ជំនួញទាំង ៥ ប្រការនេះធ្វើតែប្រការឯណាមួយក៏ជាមិច្ឆាអាជីវ ឈ្មោះថាចិញ្ចឹមជីវិតខុសធម៌ ។ ប្រការមួយទៀតបើបុគ្គលឯណារកស៊ីលក់ដូរ បំបាត់ដោយភ្នែកជញ្ជីងស្រាល ដោយរង្វាល់ខើចយ៉ាងនេះក៏ឈ្មោះថា មិច្ឆាអាជីវដែរ គឺរិយាប្រព្រឹត្តចិញ្ចឹមជីវិតវៀរចាកមិច្ឆា-អាជីវនេះឈ្មោះថាសម្មាអាជីវោ ជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៥ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៦ គឺសម្មាវាយាមោនោះ គឺធ្វើកិច្ច ៤ ប្រការ គឺព្យាយាមមិនឱ្យអកុសលធម៌កើតឡើងបានប្រការ១ ព្យាយាមលះបង់នូវអកុសលធម៌ដែលកើតឡើងហើយ ឱ្យបាត់ទៅវិញប្រការ ១ ព្យាយាមញ៉ាំង

www.budinst.gov.kh www.elibraryofcambodia.org

កុសលធម៌ដែលមិនទាន់កើតមាន ឱ្យកើតមានឡើងប្រការ១ ព្យាយាមចំរើនកុសលធម៌ដែលកើតមានឡើងហើយ ឱ្យរិតតែចំរើនឡើងមិនឱ្យវិនាសបាត់ទៅវិញប្រការ ១ ត្រូវជា ៤ ប្រការដូច្នេះ ។

ព្យាយាមមិនឱ្យអកុសលធម៌ដែលមិនទាន់កើត មិនឱ្យកើតឡើងបាននោះ ដូចកាលព្រះបរមពោធិសត្វកើតជាក្ងោកមាស ជាបក្សីដ៏ធំមានភ្នែកទាំង ២ ដ៏ក្រហមដូចគ្រាប់អង្ក្រែមអង្ក្រម មានចំពុះមាត់ដូចកែវប្រវាឡ មានវង់គ្រាក្រហមវិលវង់ជុំខ្លួន ល្អប្លែកជាងក្ងោកទាំងពួងជាស្តេចនៃក្ងោកមានកាលថ្ងៃមួយព្រះពោធិសត្វ នាំពួកក្ងោកជាបរិវារទៅរកគោចរហើរទៅចុះផឹកទឹកនៅស្រះមួយ ក៏ប្រមើលមើលរូបអាត្មាឃើញរូបល្អក៏បរិវិតក្កព្រួយថា បើអាត្មានឹងទៅជាមួយហ្វូងក្ងោកនេះទៅ ក្រែងភ័យនឹងមានដល់អាត្មាៗ នឹងគៀសទៅនៅក្នុងព្រៃហិមពាន្តតែម្នាក់ឯង ឱ្យជាសុខ កាលបើដល់វេលារាត្រីស្ងាត់ ព្រះពោធិ-សត្វមិនឱ្យក្ងោកដទៃដឹង ក៏លបហើរចេញឆ្ពោះទៅសំដៅព្រៃហិមពាន្ត វិលងព្រៃភ្នំធំៗ ប្រមាណ៣ជាន់ចូលទៅដល់ភ្នំជាគំរប់ ៤ ឃើញស្រះធំមួយដេរដាសដោយបទុមជាតិនឹងសេវាលជាតិមាន ព្រឹក្សាលតាវល្លិ៍ចោមរោមជិតជុំជារម្មណីយស្ថានមានដើមជ្រៃ ១ ធំត្រសុំសាខានៅលើភ្នំនោះ ព្រះពោធិសត្វក៏ទៅចុះចាប់ អាស្រ័យនៅដើមជ្រៃនោះ សត្វដទៃមិនអាចនឹងឡើងទៅទីនោះបានផុតចកាភ័យអន្តរាយទាំងពួង តែព្រឹកឡើងព្រះអាទិត្យឧទៃទ័យរះឡើង ព្រះ-ពោធិសត្វបែមុខ ឆ្ពោះទៅបុព្វទិស ចំកាងស្លាបនមស្សការចំរើនព្រះបរិត្តថា **ឧទេតយញ្ចក្ខុមាឯករាជាហរិស្សវណ្ណោ** ជាដើមដូច្នេះ ដើម្បីនឹងរក្សាអាត្មាក្នុងវេលាថ្ងៃ ហើយហើរទៅរកគោចរក លុះវេលាល្ងាចហើរត្រឡប់មកទីលំនៅវិញ ក្រឡេកមើលទៅបរិមណ្ឌលព្រះច័ន្ទ ហើយក៏នមស្សការពោលនូវបទ

www.budinst.gov.kh www.elibraryofcambodia.org

ព្រះគាថាដូច្នេះថា **អយោគយោឡាក្កុទាងកកាជាបរិស្សេចឆ្នោ** ជាដើមដូច្នេះ ហើយក៏នៅក្នុងវេលារាត្រីនោះ ដែលថាព្រះពោធិសត្វប្រតិបត្តិព្យាយាមយ៉ាងនេះ ជានិច្ចរាល់ថ្ងៃ គឺញាំងអកុសលធម៌ទាំងពួងមិនឱ្យកើតឡើងបានក្នុងសន្តាន អស់កាលដរាបអស់ជីវិត យ៉ាងនេះក៏ចាត់ឈ្មោះថាសម្មាវាយាមោ ជាលោកិយមគ្គកើត ដោយកាមាវចរកុសលចិត្ត ។

ឯព្យាយាមលះបង់នូវអកុសលដែលកើតឡើងហើយនោះ ឱ្យវិនាសបាត់ទៅវិញ ដូចមានក្នុងបញ្ចកឧបោសថជាតក ក្នុងបកិណ្ណកនិបាតថា សម័យមួយព្រះពោធិសត្វយកព្រះជាតិកើតក្នុងត្រកូលព្រាហ្មណ៍ មានសម្បត្តិច្រើន ក៏លះបង់សម្បត្តិចេញទៅបួសជាតាបសឬសី អាស្រ័យនៅក្នុងព្រៃព្នំស្ថានទីគួរជាទីជម្រេកចិត្ត ដ៏មាននៅក្នុងចន្លោះនគរទាំង៣ មាននគរគន្ធារជាដើម មានសត្វព្រាបមួយនិងភរិយាអាស្រ័យនៅគុម្ពឫស្សី ជិតអាស្រមបទព្រះតាបសនោះ មានពស់វែកមួយនៅក្នុងរន្ធដម្បូកជិតអាស្រមបទ មានសត្វចចកមួយអាស្រ័យនៅក្នុងស៊ុំទ្រុមព្រៃ ជិតអាស្រមបទនោះដែរ មានខ្លាឃ្មុំមួយអាស្រ័យនៅក្នុងទីនោះផង មានការមួយថ្ងៃសត្វព្រាបនាំគ្នារកចំណី ខ្លែងមួយហើរមកឃើញក៏ឆាបយកមេព្រាបនោះយកទៅធ្វើចំណី ព្រាបឈ្មោលកាលណាបើប្រាសភរិយា រាគធុតដាលខ្លាំង ក៏ចូលទៅកាន់សំណាក់ព្រះតាបស សមាទានឧបោសថសីលក្នុងសំណាក់ព្រះតាបស ដើម្បីសង្កត់សង្កិនរាគនោះ ។ ឯពស់វែកក៏ចេញទៅរកចំណី មានគោឧសុភមួយសសុទ្ធជាគោមង្គលរបស់នាយគោបាល គោនោះដើរទៅរកអាហារជិតដម្បូកដែលពស់នោះនៅ ក៏ដើរទៅជាន់កពស់ៗត្រឡប់ចឹកគោឧសុភនោះស្លាប់មួយរំពេចទៅ នាយគោបាលដើររកគោ ទៅឃើញគោនោះស្លាប់ ក៏យំស្ដាយគោ ឯពស់នោះកាលបើចឹកគោស្លាប់ហើយក៏គិតថា

www.budinst.gov.kh www.elibraryofcambodia.org

អាត្មាលុះអំណាចទោសចឹកគោសម្លាប់ ជនទាំងឡាយកើតទុក្ខសោកព្រោះតែអាត្មាបំបាត់ទោសនោះចេញ គិតដូច្នេះហើយ ក៏លូនទៅកាន់អាស្រមបទតាំងសមាទាន ឧបោសថសីលក្នុងសំណាក់ព្រះតាបស គិតថាទោសនេះមិនទាន់រម្ងាប់ដរាបណា អាត្មាក៏មិនទៅស្វែងរកអាហារដរាបនោះ បើទោសនេះរម្ងាប់ហើយទើបអាត្មានឹងទៅស្វែងរកអាហារ ។ ចំណែកឯសត្វចចកចេញដើរទៅស្វែងរកអាហារឃើញដំរីមួយស្លាប់ ចចកក៏ខាំត្រង់ទ្វារឧច្ចារដំរីនោះធ្លុះជាប្រហោង ចចកក៏មមុលចូលទៅក្នុងពោះដំរីនោះ ស៊ីហើយសំងំដេកនៅក្នុងពោះដំរីរំលងពីរបីថ្ងៃ សាកសពដំរីនោះត្រូវខ្យល់កំដៅក៏ស្វិតក្រៀមចុះទៅទ្វារឧច្ចារក៏ខ្ទប់ជាប់ជិត ចចកនោះក៏នៅក្នុងពោះដំរីទ្រាំទុក្ខវេទនាជាទម្ងន់ មានកាលថ្ងៃមួយមានភ្លៀងរំលាធំធ្លាក់ចុះមក ឯទ្វារឧច្ចារដំរីត្រូវទឹកភ្លៀងទទឹកជោកក៏របើកប្រហោងបន្តិចឡើង ចចកក៏ប្រឹងខំមមុលចេញតាមប្រហោងនោះរួចចេញមកបាន ចចកក៏គិតថា អាត្មាបានទុក្ខទាំងនេះព្រោះតែសេចក្ដីលោភអាត្មាសង្កត់សង្កិនសេចក្ដីលោភ នេះមិនទាន់បានដរាបណាអាត្មាក៏មិនទៅរកអាហារដរាបនោះ ចចកក៏ទៅកាន់អាស្រមបទហើយ សមាទាននៅឧបោសថ-សីលក្នុងសំណាក់នៃព្រះតាបស ហើយដេកនៅទីដ៏សមគួរ ឯខ្លាឃ្មុំសោតក៏មានសេចក្ដីប្រាថ្នាក្នុងអាហារគ្រប់សង្កត់ក្រលែង ចេញអំពីទីលំនៅទៅដើរស្វែងរកអាហារក្នុងព្រៃ មនុស្សទាំងឡាយក៏ក្រឡេកឃើញ ក៏កាន់ធន្ធូស្នាឈើដំបងដេញខ្លាឃ្មុំនោះទៅសំពងបែកក្បាលខ្លាឃ្មុំៗ ក៏រត់រួចទៅបានហើយគិតថាអាត្មាដល់នូវទុក្ខទាំងនេះមិនពីព្រោះអ្វី ពីព្រោះតែមោហ៍នាំឱ្យវង្វេងដោយអាហារអាត្មាអត់សង្កត់មោហមិនទាន់បាន ដរាបណាអាត្មាក៏មិនបានទៅស្វែងរកអាហារដរាបនោះគិតហើយក៏ចូលទៅកាន់អាស្រមបទព្រះតាបស ហើយសមា

www.budinst.gov.kh www.elibraryofcambodia.org

ទានសីលនូវឧបោសថសីលក្នុង សំណាក់នៃព្រះតាបសនោះ ឯព្រះតាបសវិញ សោតក៏ប្រកាន់មានះថា អាត្មានេះជាព្រាហ្មណជាតិដ៏ប្រសើរជាងជនដទៃ គិតដូច្នេះហើយក៏មិនអាចនឹង ញាំងឈានសមាបត្តិឱ្យកើតឡើងបាន ចម្លេរមក កាលជាខាងក្រោយ មានព្រះបច្ចេកពុទ្ធមួយអង្គ ជ្រាបថាព្រះតាបសនេះជា ពន្លកពុទ្ធង្កូលនឹងបានត្រាស់ជាព្រះពុទ្ធ គួរអាត្មាអញនឹងញាំងព្រះតាសនេះ ឱ្យលះបង់នូវមានះចេញក្នុងការឥឡូវនេះ ព្រះបច្ចេក ពុទ្ធទ្រង់ពិចារណាដូច្នោះ ហើយក៏និមន្តទៅគង់លើផែន សិលាដ៏ជាអាសន អង្គុយនៃព្រះតាបសៗចេញ មកឃើញព្រះបច្ចេកពុទ្ធ ក៏មិនបានថ្វាយបង្គំមនស្សការ ទើបព្រះបច្ចេកពុទ្ធ មានព្រះពុទ្ធដីកាថា ម្នាលមហាបុរសដ៏ប្រសើរ អាត្មាភាពនេះបានត្រាស់ជាបច្ចេ កពោធិញ្ញាណ ឯអង្គអ្នកនេះមិនគឺអ្នកដទៃ គឺជាអង្គពុទ្ធង្កូលនឹងបានត្រាស់ជា ព្រះពុទ្ធក្នុងអនាគតកាលពិត ប្រាកដមិនទេឡើយ ដូចម្តេចហើយក៏មកលុះ អំណាចមានះដូច្នេះមិនគួរទេ សូម្បីតែព្រះបច្ចេកពុទ្ធមានព្រះពុទ្ធដីការដូច្នោះ ព្រះតាបសក៏នៅតែប្រកាន់មានះថា ខ្លួនប្រសើរជាងក៏មានវាចាទៅនឹងព្រះ បច្ចេកពុទ្ធថា អើបើអ្នកប្រសើរ ជាងយើង ចូលអ្នកហោះទៅមើល ព្រះបច្ចេក ពុទ្ធក៏ហោះទៅដោយអាកាស ហាក់ដូចជារោយល្អងធូលីព្រះបាទលើជដាផ្នួង សក់នៃព្រះតាបស ហើយក៏ហោះឆ្ពោះទៅកាន់ភ្នំគន្ធមាទបពតិ ឯព្រះតាបស បានឃើញអានុភាពព្រះបច្ចេកពុទ្ធដូច្នោះ ក៏បង្កើតចម្ងល់សង្វេគថា ព្រះសមណ នេះមានគុណវិសេសប្រសើរណាស់ តើលោកអាចហោះទៅដោយអាកាស ប៉ុងដូចជាសំឡីត្រូវខ្យល់ ឯអាត្មាមកកាន់មានះរឹងរុសយ៉ាងនេះ នឹងជា ប្រយោជន៍អ្វី គិតដូច្នោះហើយក៏ ព្យាយាមសង្កត់សង្កិនមានះមិនឱ្យកើតឡើង បាន ក៏តាំងកសិណភាវនាឱ្យបង្កើតអភិញ្ញាសមាបត្តិហើយ ចេញមកអង្គុយ

www.budinst.gov.kh www.elibraryofcambodia.org

លើផែនថ្មសិលាក្នុងទីបំផុតនៃទីចង្ក្រមនោះៗ ឯសត្វព្រាបក៏តាំងព្យាយាមបំបាត់រាគពស់ក៏ព្យាយាមបំបាត់ទោស សត្វចចកក៏ព្យាយាមបំបាតលោភ ខ្លាឃ្មុំក៏ព្យាយាមបំបាត់មោហ សេចក្តីព្យាយាមទាំង៥នេះ ក៏ឈ្មោះថា សម្មាវាយាមោជាលោកិយមគ្គ កើតដោយកាមាវចរកុសលចិត្ត ។

ព្យាយាមដែលនឹងញ៉ាំងកុសលធម៌ ដ៏មិនទាន់កើតឡើងឱ្យកើតមានឡើងនោះ ដូចនិទានមានក្នុងព្រះធម្មបទថា មានព្រាហ្មណ៍ម្នាក់បានឃើញព្រះភិក្ខុសង្ឃ រៀបចេញទៅបិណ្ឌបាតឈរឃ្លុំចីវរ នៅក្នុងស្ថានទីមួយជាយចីវរត្រូវលើទឹកសន្សើមដែលជាប់នៅលើស្មៅ ជាយចីវរក៏ទទឹកជោកទៅដោយទឹកសន្សើមដូច្នោះហើយ ព្រាហ្មណ៍នោះបង្កើតកាមាវចរកុសលចិត្តផុលចុះឡើងក៏គិតថាអាត្មានឹងជំរះស្មៅក្នុងទីនេះ គិតដូច្នោះហើយក៏កាន់ចបទៅជំរះទីនោះវាលស្អាតប្រាសចាកស្មៅនូវមន្ទិលទាំងពួងថ្ងៃមួយឯក្រោយព្រាហ្មណ៍ ឃើញជាយចីវរព្រះភិក្ខុសង្ឃប្រឡាក់ដោយផង់ធូលីដីក្នុងទីនោះ ព្រាហ្មណ៍ក៏យកដីខ្សាច់មកចាក់រោយរាយស្អាតល្អ ថ្ងៃឯក្រោយទៀតព្រាហ្មណ៍ឃើញព្រះភិក្ខុសង្ឃឈរឃ្លុំចីវរនៅទីនោះ ត្រូវកំដៅព្រះអាទិត្យមានសរីរកាយប្រកបទៅដោយញើសព្រាហ្មណ៍ក៏ធ្វើជាមណ្ឌបបាំងទីនោះឱ្យគត់ថ្ងៃ ថ្ងៃមួយឯក្រោយទៀតព្រាហ្មណ៍ឃើញព្រះភិក្ខុសង្ឃឃ្លុំចីវរនៅទីនោះ មានភ្លៀងវិលាព្រឹកព្រះហាមទទឹកចីវរព្រះភិក្ខុសង្ឃ ព្រាហ្មណ៍ក៏ធ្វើសាលាឱ្យជាទីការពារកំដៅថ្ងៃនឹងទឹកភ្លៀងជាទីមាំមួន ព្រះភិក្ខុសង្ឃក៏បានសេចក្តីស្រួលក្នុងទីនោះព្រាហ្មណ៍រៀបនឹងឆ្លងសាលាក៏និមិត្តព្រះសាស្តាព្រមទាំង ព្រះភិក្ខុសង្ឃមកធ្វើភត្តកិច្ចឆាន់នៅសលានោះហើយព្រាហ្មណ៍ក៏ក្រាបទូលហេតុគ្រប់ប្រការ សម្តេចព្រះសាស្តាក៏ទ្រង់ទេសនាជាបទព្រះគាថាដូច្នេះ ។

www.budinst.gov.kh www.elibraryofcambodia.org

**អនុប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ**

អធិប្បាយថា ជាងមាសដែលនឹងលាងមាសដុតលាងតែម្តងក៏មិនអាចនឹងដេញមន្ទិលមាសនោះឱ្យអស់បាន លុះតែដុតដំរឿយៗជាច្រើនដងទើបដេញអស់មន្ទិលមាសនោះបាន អាចនឹងធ្វើជាគ្រឿងអលង្ការផ្សេងៗបាននេះមានឧបមាដូចម្តេចវិញ បុគ្គលជាអ្នកប្រាជ្ញអាចមានប្រាជ្ញពិចារណានូវធម៌មន្ទិលមានលោភមច្ឆរិយជាដើម ដ៏កើតមានក្នុងសន្តានចិត្ត ជំរះម្តងបន្តិចៗក្នុងឱកាសនោះៗដោយលំដាប់ៗក៏ធ្វើឱ្យប្រាសចាកមន្ទិលទាំងពួង មានឧបមេយ្យដូច្នោះ ព្រាហ្មណ៍បានស្តាប់ព្រះធម៌ទេសនាក៏បានសម្រេចសោតាបត្តិផល ជាអរិយបុគ្គលក្នុងព្រះពុទ្ធសាសនា ព្រាហ្មណ៍ក៏ខំព្យាយាមធ្វើការកុសលទាំងពួងយ៉ាងនេះឈ្មោះថាសម្មាវាយាមោ ជាលោកិយមគ្គកើតដោយកាមាវចរកុសលចិត្តនោះ កាលបើព្រាហ្មណ៍បានសម្រេចព្រះសោតាហើយ សម្មាវាយាមោជាលោកុត្តរក៏កើតព្រមដោយសោតាបត្តិមគ្គចិត្ត ។

ព្យាយាមញាំងកុសលធម៌ដែលកើតឡើង ហើយកុំឱ្យវិនាសបាត់ទៅវិញឱ្យរឹតតែចំរើនឡើងទៀតនោះ ក៏មាននិទានដូចឧបាសក៥០០នាក់ បបួលគ្នារក្សាសីល ៥ ប្រការ ហើយប្រាថ្នានឹងឱ្យសីលនោះចំរើនឡើង ក៏សមាទានសីល ៨ ហើយសមាទានសីល ១០ ហើយបួសជាសាមណេរ ប្រតិបត្តិអភិសមាចារិកវត្ត ហើយឧបសម្បទជាភិក្ខុទ្រទ្រង់ចតុបារិសុទ្ធសីល ឯព្យាយាមយ៉ាងនេះឈ្មោះថា សម្មាវាយាមោ ជាលោកកិយមគ្គកើតដោយកាមាវចរកុសលចិត្តនោះជាព្យាយាមញាំងកុសលដែលកើតឡើងកុំឱ្យ វិនាសបាត់ទៅវិញឱ្យរឹងរិតតែចំរើនឡើងទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

អង្គនៃព្រះអរិយមគ្គជាគំរប់ ៧ គឺ សម្មាសតិនោះ បានខាងឯសតិដែលប្រកបដោយអារម្មណ៍ ៤ប្រការ គឺតាំងសតិយកសរីរកាយជាអារម្មណ៍ ហើយចំរើនសមថវិបស្សនានោះ ១ គឺតាំងដំកល់សតិយកវេទនាជាអារម្មណ៍ ហើយចំរើនសមថវិបស្សនានោះ ១ គឺតាំងដំកល់សតិយកចិត្តជាអារម្មណ៍ ហើយចំរើនសមថវិបស្សនានោះ ១ គឺតាំងដំកល់សតិយកធម៌ គឺសញ្ញាចេតសិក នឹងសំខារចេតសិកជាអាម្មណ៍ ហើយចំរើនសមថវិបស្សនានោះ១ សតិដ៏មានអារម្មណ៍ ៤ (ប្រការដូច្នេះ មានលក្ខណ២ប្រការ គឺអបិលាបនលក្ខណាសតិ ១ ឧបរិគហណលក្ខណាសតិ ១ អបិលាបនលក្ខណាសតិនោះ ញាំងព្រះយោគាវចរកុលបុត្រឱ្យចេះចង់កុសលធម៌ទុកយប់ព្រឹករាល់វេលាមិនឱ្យភ្លេច កុសលធម៌នោះមានឧបមាដូចភណ្ឌាគារិក គឺនាយឃ្លាំង របស់សម្តេចព្រះបរមចក្រពត្រាធិរាជ ថ្វាយបញ្ជីព្រឹកល្ងាចរាល់វេលាជានិច្ចនិរន្តថា ដំរីមានប៉ុណ្ណោះសេះ នឹងរថពលនិកាយមានប៉ុណ្ណោះៗជាដើម យ៉ាងនេះមានឧបមាដូចម្តេច អបិលាបនលក្ខណាសតិនោះ ក៏ញាំងព្រះយោគាវចរឱ្យរឭកដល់គុណកុសលធម៌ដូច្នេះថា **ឥមេចត្តារោសតិបដ្ឋានា** ធម៌ទាំងឡាយ ៤ប្រការនេះឈ្មោះសតិបដ្ឋាន **ឥមេចត្តារោសម្មប្បធានា** ធម៌ទាំងឡាយ៤ប្រការនេះ ឈ្មោះសម្មប្បធាន **ឥមេចត្តារោឥទ្ធិបាទា** ធម៌ទាំងឡាយ៤ប្រការ នេះឈ្មោះឥទ្ធិបាទ ធម៌ទាំងឡាយ៥ប្រការនេះឈ្មោះឥន្ទ្រីយ៍ ធម៌ទាំងឡាយ៥ប្រការនេះឈ្មោះពល ធម៌ទាំងឡាយ ៧ប្រការនេះឈ្មោះពោជ្ឈង្គ ធម៌ទាំងឡាយ៨ប្រការនេះឈ្មោះអរិយមគ្គមានអង្គ ៨ ប្រការ ធម៌ទាំងឡាយពួកនេះឈ្មោះសមថ ធម៌ទាំងឡាយពួកនេះឈ្មោះវិបស្សនា ធម៌ទាំងឡាយពួកនេះឈ្មោះសច្ច ធម៌ទាំងឡាយពួកនេះឈ្មោះវិមុត្តិ ធម៌ទាំងឡាយពួកនេះជាលោកុត្តរ អបិលាបនលក្ខណាសតិនោះ

www.budinst.gov.kh www.elibraryofcambodia.org

មានឧបមេយ្យដូចជានាយឃ្លាំងនៃស្ដេចបរមចក្រពត្រាធិរាជដូច្នោះឯង ឯឧប-វិគហណលក្ខណាសតិនោះ មានឧបមាដូចបរិនាយកមន្ត្រីយរតន៍ស្ដេចបរមចក្រពត្តិរាជដ៏ពិចារណាមើលនូវពពួកជនទាំងពួង ដឹងថាជនទាំងឡាយនេះមិនធ្វើនូវអំពើជាប្រយោជន៍ដល់ព្រះមហាក្សត្រក៏ញាំងជនទាំងឡាយនោះ ឱ្យចៀសចេញទៅ ជនទាំងឡាយឯណាធ្វើនូវអំពើជាប្រយោជន៍ដល់ព្រះមហាក្សត្រ ក៏ញាំងជនទាំងឡាយនោះឱ្យចូលទៅជិតព្រះមហាក្សត្រ នេះមានឧបមាដូចម្ដេច ឧបរិគហណលក្ខណាសតិនោះក៏ស្វែងរកគតិនៃធម៌ទាំងឡាយថា ធម៌ទាំងឡាយមានកាយទុច្ចរិតជាដើមដ៏រកប្រយោជន៍គ្មាន ក៏បន្ទោរបង់ចោល ធម៌ទាំងឡាយមានកាយសុចរិតជាដើម ជាប្រយោជន៍ហើយក៏កាន់យក ក៏មានឧបមេយ្យដូចបរិនាយកមន្ត្រីរតន៍នៃព្រះមហាក្សត្របរមចក្រពត្តិរាជ នោះជាអង្គនៃព្រះអរិយមគ្គជាគំរប់ ៧ ប្រការ ។

អង្គនៃព្រះអរិយមគ្គជាគំរប់ ៨ គឺសម្មាសមាធិនោះមានលក្ខណា២ប្រការគឺបាមោក្ខលក្ខណា១ អវិក្ខេបនលក្ខណា ១ បាមោក្ខលក្ខណាសមាធិនោះជាប្រធានដល់កុសលធម៌ទាំងឡាយ ឧបមាដូចកំពូលកូដាគារប្រាសាទ ជាប្រធានដល់បង្កន់ទាំងឡាយ ហេតុដូច្នោះព្រះនាគសេនថេរលោកឧបមាថ្វាយសម្ដេចព្រះមិលិន្ទ្រាធិរាជថា បពិត្រព្រះរាជសម្ភារ បង្កង់ទាំងឡាយនៃកូដាគារប្រាសាទទាំងប៉ុន្មាន មានកំពូលជាប្រធាន កំពូលជាទីប្រជុំនៃបង្កង់ទាំងឡាយកំពូលប្រសើរជាងបង្កង់ទាំងឡាយ នោះមានឧបមាដូចម្ដេច កុសលធម៌ទាំងឡាយទាំងប៉ុន្មាននោះ ក៏ឱនញោចទន់ទៅក្នុងសម្មាសមាធិទាំងអស់ សម្មាសមាធិនេះជាទីប្រជុំនៃកុសលធម៌ទាំងឡាយ មានឧបមេយ្យដូច្នោះ ។

អវិក្ខេបនលក្ខណាសមាធិនោះ មានសភាវញាំងធម៌ទាំងឡាយឱ្យកើត

www.budinst.gov.kh www.elibraryofcambodia.org

ដោយសម្មាសមាធិនោះ មិនឱ្យរាយមាយខ្ចាត់ខ្ចាយដោយឧទ្ធច្ច ហើយឱ្យដឹកលំ មាំនឹងនៅក្នុងអារម្មណ៍តែ ១ ហេតុដូច្នោះទើបលោកឧបមាយ៉ាងនេះ ធម្មតា ព្រះមហាក្សត្រចូលកាន់សង្គ្រាមយុទ្ធ ក៏ទតមើលសេនាយោធាទាំងពួង បើ ឃើញសេនាក្នុងទីស្ថានខាងណាអន់ថយកំលាំង ស្តេចក៏យាងទៅត្រង់ស្ថានទី នោះញាំងសេនាយោធាឱ្យបរិបូណ៌ ហើយញាំងសេនាយោធាបច្ចាមិត្តឱ្យអប រាជ័យចាលចាញ់បែកខ្ចាត់ខ្ចាយ នេះមានឧបមានដូចម្តេច សម្មាសមាធិដែល ឈ្មោះថាអវិក្ខេបនលក្ខណសមាធិ ព្រោះថាសម្មាសមាធិនោះមិនឱ្យកុសលធម៌ ទាំងឡាយដែលកើតឡើង ហើយរោយរាយខ្ចាតខ្ចាយទៅដោយឧទ្ធច្ច ឱ្យគ្រប សង្កត់បំបាត់បង់នូវនូវឧទ្ធច្ចមិនឱ្យឧទ្ធច្ចកើតឡើង ហើយឱ្យដឹកលំនៅក្នុង អារម្មណ៍តែ ១ តាមអំណាចនៃសម្មាសមាធិ មានឧបមេយ្យដូចជាព្រះមហា ក្សត្រនោះ សម្មាសមាធិនោះមានប្រការ ១ ដោយអំណាចនៃសភាវមិនបាន រាយមាយទៅ សម្មាសមាធិនោះមានប្រការ២ ដោយអំណាចនៃឧបចារសមាធិ នឹងអប្បនាសមាធិសម្មាសមាធិមានប្រការ៣ ដោយអំណាចនៃហីនសម្មាសមា ធិ នឹងមជ្ឈិមសម្មាសមាធិនឹងបណីតសម្មាសមាធិ សម្មាសមាធិមានប្រកា៤ ដោយអំណាចនៃទុក្ខាបដិបទាទន្ធាភិញ្ញា ១ ទុក្ខាបដិបទាខិប្បាភិញ្ញា ១ សុខាប ដិបទាទន្ធាភិញ្ញា ១ សុខាបដិទាខិប្បភិញ្ញា ១ សម្មាសមាធិមានប្រការ ៥ ដោយ អំណាចនៃបឋមជ្ឈានសមាធិ ១ ទុតិយជ្ឈានសមាធិ ១ តតិយជ្ឈានសមាធិ ១ ចតុត្ថជ្ឈានសមាធិ ១ បញ្ចមជ្ឈានសមាធិ ១ ប្រភេទនៃសមាធិមាន ៥ ប្រការ ដោយប្រការដូច្នេះ អង្គនៃព្រះអរិយមគ្គជាគំរប់ ៨ ចប់តែប៉ុណ្ណោះ ។

សម្តេចព្រះសព្វញ្ញូទ្រង់ព្រះមហាករុណាត្រាស់ទេសនា ព្រះ ធម្មចក្កប្បវត្តនសូត្រនោះ គឺសម្តែងពោធិបក្ខយធម៌ នឹងបដិច្ចសមុប្បទធម៌

www.budinst.gov.kh www.elibraryofcambodia.org

នឯចតុរារិយសច្ចធម៌ មានអត្ថដ៏ជ្រួតជ្រាបផ្សះភ្លឺផ្សះរហូតដល់គ្នា មានឧបមាដូចដុំរទេះនិងកាំរទេះនិងកង់រទេះ យ៉ាងនេះឈ្មោះថាជាធម៌ចក្រ ប្រការ១ទៀតព្រះធម៌ចក្រនោះមាន២ប្រការ គឺបដិវេធញាណធម៌ចក្រប្រការ១ ទេសនាញាណធម៌ចក្រប្រការ១ ត្រូវជា២ប្រការ ដូច្នេះបដិវេធញាណធម៌ចក្រនោះបានខាងឯញាណដ៏ត្រាស់ដឹងនូវព្រះចតុរារិយសច្ចមានបរិវដ្ដ៣ មានអាការ១២សម្លាប់នូវសត្រូវ គឺកិលេសជាសមុច្ឆេទបហានដាច់ចេញស្រឡះអំពីសន្ដានហើយនាំមកនូវអរិយផល កាលដែលព្រះអង្គគង់លើអបរាជិតបល្ល័ង្គ ក្រោមដើមមហាពោធិព្រឹក្ស ឯទេសនាញាណធម៌ចក្រនោះ បានខាងព្រះញាណដ៏អប់រំដោយព្រះមហាករុណាទិគុណព្រះអង្គទេសនាចតុរារិយសច្ច មានបរិវដ្ដ ៣ប្រការ មានអាការ ១២ ញុំាងសាវ័កទាំងឡាយមានព្រះអញ្ញាតកោណ្ឌញ្ញត្ថេរជាប្រធានឱ្យបានសំរេចព្រះអរិយមគ្គអរិយផលកាត់កិលេសជាសមុច្ឆេទបហានឯព្រះធម៌ចក្រទាំង២ មានន័យដូចបានពណ៌នាមកដូច្នេះ ប្រាថ្នានឹងលើកឡើងសម្ដែងក្នុងទីក តែទេសនាញាណធម៌ចក្រដែលមានបរិវដ្ដ៣ អាការ ១២ នោះដូច្នេះ ។ មានពាក្យវិសជ្ជនាថា បរិវដ្ដ៣ ប្រការនោះបានខាងឯបញ្ញា ៣ប្រការគឺសច្ចញាណប្រការ១ កិច្ចញាណប្រការ១ កតញាណប្រការ១ សច្ចញាណនោះគឺប្រាជ្ញាត្រាស់ដឹងនូវព្រះចតុរារិយសច្ចដោយព្រះអង្គឯង រកបុគ្គលឯណាមួយជាគ្រូអាចារ្យព្រះអង្គគ្មាន កិច្ចញាណនោះគឺប្រាជ្ញាដ៏ចាក់ធ្លុះរហូតទៅក្នុងចតុសច្ចកិច្ចត្រាស់ជាក់ច្បាស់ថា **ទុក្ខំបរិញ្ញេយ្យំ** ទុក្ខសច្ចនេះសមគួរព្រះអរិយបុគ្គលគប្បីនឹងកំណត់កត់សំគាល់យកជាអារម្មណ៍ **ទុក្ខសមុទយោបហាតព្វោ** ទុក្ខសមុទយអរិយសច្ចនេះសមគួរព្រះអរិយបុគ្គលគប្បីនឹងលះបង់ **ទុក្ខនិរោធោសច្ឆិកាតព្វោ** ទុក្ខនិរោធសច្ចគឺព្រះនិព្វាននេះសមគួរព្រះអរិយបុគ្គលគប្បីនឹងធ្វើឱ្យជាក់ច្បាស់ក្នុងខន្ធសន្ដាន **ទុក្ខនិរោធគាមិនីបដិបទាភាវេតព្វា**មគ្គសច្ចដ៏ជាផ្លូវប្រតិបត្តិឱ្យដល់នូវទីរំលត់ទុក្ខគឺ ព្រះនិព្វាននោះ

www.budinst.gov.kh www.elibraryofcambodia.org

សមគួរព្រះអរិយបុគ្គលគប្បីនឹងចំរើនទុកក្នុងសន្តាន ព្រះប្រាជ្ញាដ៏ត្រាស់ដឹងក្នុងកិច្ចដែលគប្បីនឹងធ្វើក្នុងព្រះចតុរារិយសច្ចទាំង៤ ប្រការដូចបានពណ៌នាមកនេះ កតញ្ញាណ នោះគឺប្រាជ្ញាដ៏ដឹង ច្បាស់ចតុសច្ចកិច្ចដ៏សម្រេចហើយ ៗ ដឹងថា **ទុក្ខំបរិញ្ញាតំ ទុក្ខសច្ច** នេះអាត្មាបានកំណត់យកជាអារម្មណ៍ហើយ **ទុក្ខសមុទយោបហីនោ** សមុទយសច្ច គឺតណ្ហាអាត្មាក៏បានលះបង់ចេញដាច់ស្រឡះអំពីសន្តានហើយ **ទុក្ខនិរោធោសច្ឆិកតោ** ទុក្ខនិរោធសច្ចគឺព្រះនិព្វានធម៌នោះ អាត្មាក៏បានធ្វើឱ្យជាក់ច្បាស់ក្នុងសន្តានហើយ **ទុក្ខនិរោធគាមិនីបដិបទា** មគ្គសច្ចដ៏ជាផ្លូវប្រតិបត្តិឱ្យដល់នូវទីរំលត់ទុកនោះ អាត្មាក៏បានចំរើនបរិបូណ៌ហើយ ប្រាជ្ញាដែលដឹងជាក់ឃើញច្បាស់ដឹងប្រាកដឃើញពិតកិច្ចក្នុងចតុរារិយសច្ចនោះបានធ្វើហើយស្រេច គ្រប់ប្រការដូចបានពណ៌នាមកនេះឈ្មោះថា កតញ្ញាណ ។

សច្ចញ្ញាណ១ កិច្ចញ្ញាណ១ កតញ្ញាណ១ ទាំង៣ប្រការនេះឯងចាត់ជាបរិវដ្ត ៣ ប្រការ ឯអាការ ១២ ប្រការនោះឱ្យតាំងអរិយសច្ច ៤ ចុះ ហើយទើបយកញ្ញាណទាំង៣ គឺ សច្ចញ្ញាណ កិច្ចញ្ញាណ កតញ្ញាណ មកគុណជាមួយគ្នាបួន ៣ ដង ត្រូវជាអាការ ១២ ព្រះប្រាជ្ញាដ៏ប្រកបដោយបរិវដ្ត ៣ និងអាការ ១២ នេះឈ្មោះថាព្រះធម៌ចក្រ ដោយអត្ថថា វិលបក់កំចាត់សត្រូវគឺ កិលេសដ៏មុតលើសលែងប្រសើជាងវជីរាវុធសម្តេចអមរិន្ទទេវរាជ ធម៌ចក្រនេះមុតក្រៃលែងមុត រកអ្វីនឹងប្រៀបពុំបានឡើយ ព្រះបរមសាស្តាចារ្យសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះចតុរារិយសច្ច គឺព្រះធម្មចក្កប្បវត្តនសូត្រចប់ស្រេចកាលណាបញ្ចវគ្គិយភិក្ខុទាំង ៥ អង្គព្រះអញ្ញាតកោណ្ឌញ្ញជាដើម នឹងពួកព្រហ្មទាំង ១៨ កោដិបានសម្រេចមគ្គផលទាំងអស់ សម្តែងមកក្នុងសច្ចទាំង ៤ ក៏ចប់បរិបូណ៌តែប៉ុណ្ណោះហោង ។

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org